ឆ្នាំទី ៤

លេខ ៦

C. 370/05/82/597/A
C. 305/370/597/A
D- 37.05
REGIE DU DEPOT LEGAL

# ទស្សនាវដ្ដី សាស្ត្រាចារ្យ

ផ្សាយចេញរាល់ត្រីមាស



ផ្សាយចេញ
ពីសមាគម សាស្ត្រាចារ្យ

ទីចាត់ការបណ្ដោះអាសន្ន
៦០, ផ្លូវអូរឫស្សី

ភ្នំពេញ

ស.ស. ថ្ងៃ ១៨-៧-៦៦

# មាតិការឿង


| | ទំព័រ |
|---|---|
| កថាមុខ | |
| បិត្ត–គរុកោសល្យ | |
| –វិទ្យាសាស្ត្រធម្មជាតិដោយដើរលេង . . . | ១ |
| –សាស្ត្រាចារ្យយើងត្រូវធ្វើយ៉ាងណា ដើម្បីឲ្យសិស្សយើងចាប់ចិត្តចំពោះមុខវិជ្ជាខ្មែរ ? . . . | ៥ |
| –ប្រវត្តិសាស្ត្រពន្យល់ជាភាសាខ្មែរ . . . | ៩ |
| –ជំងឺ «ប្រឡងនិយម» . . . . . | ១៣ |
| –ម៉ោង គឺ ម៉ោង . . . . . | ១៥ |
| វិទ្យាសាស្ត្រនឹងវិប្បធម៌ | |
| –ធម្មជាតិនៃផ្កាយ . . . . . | ៧១ |
| –ទស្សនាភាពយន្ត រឿង «ក្បួនជីវិត» . . . | ២១ |
| ដំណើរទស្សនកិច្ច | |
| - គណប្រតិភូសាស្ត្រាចារ្យនៅសាធារណរដ្ឋចិនប្រជាមានិត | ២៦ |
| –ដំណើរខ្ញុំទៅកាន់ប្រទេសជប៉ុន . . . . | ៣៥ |
| ប្រអប់សំបុត្រ | |
| –ញត្តិសមាគមសាស្ត្រាចារ្យ . . . . | ៤៣ |
| –ជុំវិញការផ្លាស់លោក ទីវ អុល . . . . | ៤៥ |
| ល្បែងនឹងកីឡា | |
| ជីវភាពមិត្តយើង | |
| –ដំណឹងខ្លីៗ . . . . . . | ៥២ |
| អំពីសៀវភៅ | |
| ពរឆ្នាំថ្មី | |

# សមត្ថភាពសិស្សសព្វថ្ងៃនិងពីដើម

តាមការធៀបប្រៀបដោយបន្ទាន់នឹងសើៗ អ្នកខ្លះវិនិច្ឆ័យភ្លាមថា សិស្សសព្វថ្ងៃខ្សោយជាងសិស្សពីដើមឆ្ងាយណាស់ ។ មតិនេះបានធ្វើឲ្យឪពុកម្ដាយសិស្សព្រួយបារម្ភជាច្រើន និងបានធ្វើឲ្យអ្នកបង្រៀនទាំងឡាយក៏ក្រៀមក្រំចិត្តបន្តិចដែរក្នុងរឿងនេះ ។ តើសិស្សសព្វថ្ងៃខ្សោយមែនឬទេ ? មុននឹងឆ្លើយតបនឹងសំនួរនេះ គួរពិចារណានូវចំណុចសំខាន់ៗ ដូចខាងក្រោមនេះសិន ៖

## អំពីសមត្ថភាពពីកំណើត

ប្រាជ្ញាស្មារតីសិស្សសព្វថ្ងៃមិនមែនចាញ់សិស្សជំនាន់ដើមទេ ។ ក្មេងឥឡូវក៏មានសមត្ថភាពនឹងត្រិះរិះគិតគូរ និងរៀនចងចាំដូចតែក្មេងពីដើមដែរ ហើយវាស្រេកឃ្លាន ចង់ចេះចង់ដឹងជាងក្មេងពីដើមផង ។ វាយំតែមករៀនសាលា មិនបាច់គេទៅអូសដៃពីផ្ទះដូចពីដើមទេ ។

ចុះហេតុម្ដេចក៏ក្មេងថ្នាក់ទី ៦ ឥឡូវ ខុសគ្នាពីក្មេងថ្នាក់ទី ៦ ពីដើម ? បុព្វហេតុមួយដែលគួរយកមកគិត គឺមកពីអាយុខុសគ្នា ។ ឥឡូវនេះក្មេងចូលវិទ្យាល័យច្រើនអាយុ ១២-១៣ ឆ្នាំ ។ ឯជំនាន់ដើមវិញ សិស្សចូលវិទ្យាល័យច្រើនចាស់ៗបន្តិចហើយ ខ្លះលួចបន្ថយអាយុ ខ្លះធ្វើឪគេក៏សឹងតែបាន ។ ម្លោះហើយ ឃើញថាក្មេងឥឡូវហាក់ដូចជាខ្ចីប្រាជ្ញា មិនប្រសព្វត្រិះរិះពិចារណាដូចក្មេងពីដើម ។ រឿងនេះមិនមានអ្វីគួរឲ្យភ័យឡើយ ពីព្រោះថាវាខ្ចីប្រាជ្ញាមែនពិត ប៉ុន្តែវាមានលទ្ធភាពរៀនបានយូរបានឆ្ងាយ រហូតដល់ឧត្តមសិក្សា ។ ចំណែកសិស្សអាយុច្រើន ទោះជាពូកែរិះគិតក៏ដោយ ទៅដល់ត្រឹមសញ្ញាប័ត្រ (ឌីប្លូម) ក៏ចង់អស់សមត្ថភាពលែងលូតលាស់ទៅទៀត ហើយក៏អល់ឯករគេចេញធ្វើការទៅហើយ ។ យើងមិនអាចតាមទារឲ្យសិស្សទី ៦ ទំនើបជំនាន់ឥឡូវ ចាស់ចិត្តចាស់គំនិតជាងក្មេងថ្នាក់បរិវេចនដ្ឋានជំនាន់ដើមទេ បើអាយុវាប្រហែលតែគ្នា ខុសគ្នាតែត្រង់ជំរះមួយខ្ពស់និងច្រើនជាងជំរះមួយប៉ុណ្ណោះៗ

## អំពីច្បាប់បរិមាណ

តាមធម្មតា ធ្វើអ្វីក៏ដោយ តែចង់បានច្រើនវាមែងតែខូចខាតខ្លះខាងគុណសម្បត្តិ ។ យ៉ាងហោចក៏ខូចលើកដំបូងដែរ ទំរាំគេឃើញវិធីលើកគុណសម្បត្តិឡើងវិញៗ ឧបមាដូចចុងភៅដែលធ្លាប់ស្ងួតបាញ់ក្នុងឆ្នាំងតូច លុះទៅស្លក្នុងខ្ទះគ្នាត មុនដំ-

ប្អូន គឺលែងធ្លាក់អស់ ។ សព្វថ្ងៃ ចំនួនសិស្សក្នុងស្រុកខ្មែរកើនឡើងហួសណាស់ រាជរដ្ឋាភិបាលក៏បានខំចំណាយ ថវិកាជាតិសំរាប់សិក្សាធិការជាអតិបរមា យ៉ាងនេះហើយនៅតែផ្តល់សាលានិងគ្រូឲ្យស្ទើរតែមិនទាន់ ។ នៅប្រទេសដទៃ មានប្រទេសបារាំងជាដើម ក៏ជំរះសិស្សចុះខ្សោយជាងពីដើម ដោយសារ តែចំនួនសិស្សកើនឡើងហួសពេកដែរ ក្រោយចំបាំងសាកលលោកលើកទី២ ។ នេះជាវិបត្តិក្នុងដំណើរលូតលាស់ (Crise de croissance) ដែលពិបាកនឹងជៀសវាងរួច ក្នុងមួយរយៈមុនដំបូង ។

សភាពការណ៍សាលារៀនយើងសព្វថ្ងៃ គឺមានសិស្សណែនណាន់ក្នុងថ្នាក់និមួយៗ ។ ក្នុងមធ្យមសិក្សា ច្បាប់តំរូវឲ្យទទួលសិស្សតិចជាង ៣៥នាក់ក្នុងមួយថ្នាក់ ។ ប៉ុន្តែសព្វថ្ងៃក្នុងវិទ្យាល័យ-អនុវិទ្យាល័យរាជការ មានសិស្សដល់ទៅ៤៥ជួនកាលឡើងជាង ៥០ នាក់ផងក្នុងថ្នាក់ខ្លះ ហើយនៅក្នុងអនុវិទ្យាល័យឯកជនខ្លះ មានសិស្សឡើងដល់ ៦០ នាក់ក្នុងមួយថ្នាក់ ។ ក្នុងបឋមសិក្សា ថ្នាក់ក្រោមៗខ្លះទទួលសិស្ស ២ក្រុម ក្រុមមួយរៀនបានតែព្រឹក ក្រុមមួយរៀនបានតែល្ងាច ក្នុងថ្នាក់តែមួយដដែល; បានសេចក្តីថា គ្រូម្នាក់ត្រូវមើលសិស្សប្រហែល ១០០នាក់ ។ ដូច្នេះគ្រូនេះពុំអាចស្គាល់និងយកចិត្តដាក់លើសិស្សម្នាក់ៗ ឲ្យបានសព្វគ្រប់ទេ ។ ធ្វើយ៉ាងនេះ មានការខុសឆ្គងខ្លាំងណាស់ខាងផ្នែកគរុកោសល្យ ។ ប៉ុន្តែ បើយកសិស្សត្រឹមត្រូវតាមចំនួនច្បាប់បញ្ញត្តិ តើឲ្យអ្នកឯទៀតទៅរៀនឯណា បើឪពុកម្តាយសិស្សតាមអង្វរដាច់ៗម៉្លេះ? បើសុខចិត្ត "ញាត់" សិស្សឲ្យហៀរៗថ្នាក់ វាខូចខាតគុណសម្បត្តិអប់រំ; តើគរុកោសល្យនៅឯណា? នេះជាបញ្ហាដែលចាងហ្វាងសាលាម្នាក់ៗ គិតសឹងតែបែកក្បាលទៅហើយ ។

កាលពីដើម អាណានិគមបារាំងយកសិស្សចូលវិទ្យាល័យមួយឆ្នាំមិនបាន ១០០ នាក់ទេ ប្រឡង "ឌីប្លូម" ជាប់បាន ៣០-៤០ នាក់មួយឆ្នាំ ប្រឡងមធ្យមសិក្សាប័ត្រទី២ បាន ៣ ឬ ៤ នាក់មួយឆ្នាំៗ សភាពការណ៍ជំនាន់នោះ និងឥឡូវខុសគ្នាដូចមេឃនឹងដី យើងប្រដូចពុំបានទេ ។ ជាពិសេសសូមប្រយ័ត្នផ្ដាយសរសើរអាណានិគមជំនាន់នោះ ថាវាចេះបង្រៀនកូនខ្មែរ "គ្រាន់បើ!" ។

## អំពីកម្មវិធី

គោលបំណងនៃ ការសិក្សាពីដើមនិងសព្វថ្ងៃខុសគ្នា ។ ពីដើមគេ "ចាប់" សិស្សប្រួនដប់នាក់មក

បង្រៀន ដើម្បីឲ្យចេះត្រឹមតែធ្វើស្មៀនចម្លង ធ្វើជីបកប្រែល្មមភាសាណានិតមបារាំងប្រើបាន គ្មានបង្រៀនឲ្យចេះដឹកនាំខ្លួនឯងកើតទេ ។ ឥឡូវនេះការសិក្សាសំដៅផ្ដល់វិជ្ជាទូទៅឲ្យពលរដ្ឋគ្រប់រូបជាបឋម; តទៅក្រោយ ម្នាក់ៗមានលទ្ធភាពលូតលាស់នឹងបែកប្រាជ្ញាយកស្កាត់ជំនាញ ក្នុងមុខវិជ្ជាអ្វីមួយទៅតាមសមត្ថភាពខ្លួនទៅទៀត ។

កម្មវិធីកសាងឡើង ត្រូវអនុលោមទៅតាមសេចក្ដីត្រូវការរបស់ប្រទេសជាតិ ទៅតាមផលប្រយោជន៍អនាគតនៃយុវជនយើង ទៅតាមលក្ខណសម្បត្តិក្នុងស្រុកយើង និងទៅតាមការវិវត្តន៍ក្នុងសាកលលោក ដូចខាងវិទ្យាសាស្ត្រនិងខាងនយោបាយជាដើម ។ តើយើងអាចបង្រៀនសិស្សយើងអំពីភូមិសាស្ត្រស្រុកចិន ថា ,,ចិនទុកកំប៉ោយ រុំជើង ដើរស្លូមទាន,, ដូចគេនិយាយក្នុងសៀវភៅបារាំងពីដើមបានឬទេ នៅក្នុងកាលៈទេសៈសព្វថ្ងៃនេះ ? បើស្រុកយើងត្រូវការអ្នកបច្ចេកទេសច្រើន កម្មវិធីគោងសង្កត់ធ្ងន់លើវិទ្យាសាស្ត្រ ។ បើស្រុកយើងត្រូវការជំរើនវប្បធម៌ជាតិ កម្មវិធីគោងសង្កត់ធ្ងន់លើអក្សរសាស្ត្រខ្មែរ- ។ល ។ កន្លែងណាមិនសូវមានប្រយោជន៍ ដែលចាស់ហួសសម័យ ដែលនាំឲ្យធ្ងន់ក្បាលសិស្សឥតអំពើ គួរជំរុះចោលខ្លះ ដើម្បីសំរាលកម្មវិធី ។ កន្លែងណាដែលជាបច្ចុប្បន្នភាពមានប្រយោជន៍ទៅអនាគត គួរយកមកបន្ថែម ។ ទាំងនេះបញ្ជាក់ថា ការកែប្រែកម្មវិធីជាការចាំបាច់ ប្រទេសណាក៏គេធ្វើដែរ ។ យើងមិនថាឲ្យកែប្រែកម្មវិធីតែរាល់ឆ្នាំនោះទេ ប៉ុន្តែយូរៗត្រូវកែប្រែម្ដងឲ្យទាន់សភាពការណ៍ថ្មី ។

កម្មវិធីដែលក្រសួងអប់រំជាតិបានរៀបចំជាថ្មីក្នុងឆ្នាំ១៩៥៨ អាចចាត់ទុកជាជំហានមួយទៅមុខបានដែរ ថ្វីបើជំហាននេះធ្វើដោយស្ទាប ៗ ប្រយ័ត្នមុខប្រយ័ត្នក្រោយជាទីបំផុត ។ ប៉ុន្តែទោះជាកម្មវិធីល្អក៏ដោយ បើគ្រូអ្នកត្រូវបង្រៀនមិនចេះ ឬមួយមិនចង់អនុវត្ត ក៏លទ្ធផលមិនបានប៉ុន្មានដែរ ។ តាមដែលពិសោធមក កម្មវិធីយើងសព្វថ្ងៃដែលបានអនុវត្តតាំង១៩៥៨ មានចំណុចល្អច្រើន ប៉ុន្តែចំណុចខ្វះខាតក៏មានខ្លះដែរ ។ ដល់សម័យមួយជាចាំបាច់ គណៈឧត្ដមប្រឹក្សាខាងអប់រំ ច្បាស់ជាប្រជុំគ្នាមើលហេតុផល តំរែតំរង់កម្មវិធីនេះឲ្យត្រូវតាមសភាពការណ៍ពុំខាន ។ គ្មានកម្មវិធីណា នៅថិតថេរបេរកាលមួយអាយុបានទេ ។

មិនមែនការកែប្រែកម្មវិធីទេដែលនាំឲ្យសិស្សចុះខ្សោយ ។ គប្បីរកបុព្វហេតុនៅលើកត្តាផ្សេងៗ

ទៀត ដូចជាចំនួនសិស្សច្រើនដូចបាននិយាយរួចខាងលើជាដើម ។ បើសិនយើងទុកកម្មវិធីដូចជំនាន់អាណានិគមបារាំង យើងក៏មិនជឿជាសមត្ថភាពសិស្សយើងឡើងលើសពីសព្វថ្ងៃនេះដែរ ។

## អំពីវិធីបង្រៀន

កាលពីសមាជជាតិលើកទី ១២ កន្លងទៅ សម្ដេចព្រះប្រមុខរដ្ឋ ទ្រង់ព្រះតំរិះផ្ដាំផ្ញើឲ្យប្រគល់មុខវិជ្ជាផ្សេងៗ ឲ្យសាស្ត្រាចារ្យខ្មែរបង្រៀនហើយ ទ្រង់ព្រះរាជានុញ្ញាតឲ្យពន្យល់មេរៀនជាភាសាខ្មែរ ប្រយោជន៍ឲ្យសិស្សងាយយល់ ។ មានតែមុខវិជ្ជាភាសាបារាំងមួយទេ ដែលទ្រង់យល់ថាគួរទុកឲ្យសាស្ត្រាចារ្យបារាំងជាប់មុខ ពីព្រោះគេជំនាញក្នុងការនិយាយនិងអានភាសាគេស្រាប់ ។ ព្រះតំរិះនេះបានធ្វើឲ្យសាស្ត្រាចារ្យទាំងឡាយ ធូរដៃធូរជើងគ្រប់គ្នាក្នុងការបង្រៀន ពីព្រោះភាសាពន្យល់នេះជារបងមួយធ្ងន់មិនផុតនាំឲ្យសិស្ស មិនយល់មេរៀន ហើយជាកត្តាមួយដែលនាំឲ្យសិស្ស កាន់តែខ្សោយទៅៗដូចលោកគិម ស៊ុយ៉ុង សាស្ត្រាចារ្យនៅព្រៃល្វា បានអធិប្បាយក្នុងអត្ថបទអំពីប្រវត្តិសាស្ត្រចុះក្នុងលេខនេះស្រាប់(នៅទំព័រទី៩) ។ ការដែលពន្យល់មេរៀនជាភាសាខ្មែរ ដោយទុកពាក្យបារាំងនិងពាក្យបច្ចេកទេសអន្តរជាតិលាយជាមួយឃ្លាខ្មែរ ក៏មានលក្ខណៈ "ប្រល័យកាត់",បន្តិច ប៉ុន្តែវាងាយនឹងយល់ ងាយនឹងធ្វើយ៉ាងធូរល្ហុយមិនចាំងគិតផងៗ ពីមុនៗ មានសាស្ត្រាចារ្យខ្លះប្រថុយប្រើវិធីនេះម្ដងៗ ទៅហើយ ប៉ុន្តែធ្វើដោយលួចលាក់ ព្រោះគ្មានការអនុញ្ញាតជាផ្លូវការ ។

ខាងសម្ភារៈបង្រៀន យើងមិនទាន់មានសៀវភៅជាភាសាខ្មែរគ្រប់គ្រាន់នៅឡើយទេ សម្រាប់សិស្សយកទៅអានស្រាវជ្រាវម្នាក់ឯងក្រៅម៉ោងរៀន ។ រីឯសៀវភៅបារាំងមើលមិនយល់វាយមិនបែក ។ សៀវភៅសិក្សាតិចតួចដែលមានបោះពុម្ពហើយ មិនទាន់ត្រឹមត្រូវតាមគោលការណ៍កម្មវិធី ឬក៏នៅកំរិតទាប ប្រើបានតែក្នុងថ្នាក់តូចៗ ហើយសំបូរណ៍តែខាងផ្នែកអក្សរសាស្ត្រជាតិផង ។ ខាងមុខវិជ្ជាឯទៀតៗ មិនសូវមាន ។ សព្វថ្ងៃ យើងមិនទាន់មាន គណៈកម្មការសាស្ត្រាចារ្យ ទទួលភារៈបកប្រែនិងតែងសៀវភៅជាភាសាខ្មែរ សំរាប់មុខវិជ្ជានិមួយៗ នៅឡើយ ។

ម្យ៉ាងទៀត ដើម្បីឲ្យសិស្សពូកែ តោងតែសាស្ត្រាចារ្យពូកែជាមុនសិន ។ យើងមិននិយមវិធីសំឡុតស្មារតី ដូចគ្រូបារាំងជំនាន់អាណានិគម (មៀវរ៉ូឡង់ជាដើម) កៀបសិស្សចាស់ៗ ឲ្យ

លេបមេរៀនទាំងដុលៗ នោះទេ ។ គប្បីរកមធ្យោបាយបង្កើនសមត្ថភាពសាស្ត្រាចារ្យ ឲ្យចេះវិធីសាស្ត្រច្រើនទៅវិញ ដោយបើកវគ្គសិក្សាវិសិដ្ឋការ ( cours de perfectionnement ) ដោយឲ្យមានអធិការទៅត្រួតពិនិត្យរបៀបបង្រៀនក្នុងវិទ្យាល័យនានា ណែនាំ និងដកស្រង់ពិសោធន៍អំពីសាស្ត្រាចារ្យគ្រប់មុខវិជ្ជាៗ សព្វថ្ងៃ យើងមិនទាន់មានក្របខ័ណ្ឌអធិការមធ្យមសិក្សានៅឡើយទេ ហើយសាស្ត្រាចារ្យម្នាក់ៗចេះតែខំរៀវតែជាមួយសិស្សរៀងៗខ្លួនៗ

## ឆ្លើយនឹងសំនួរដើម

បើយ៉ាងដូច្នេះសិស្សសព្វថ្ងៃចុះខ្សោយមែនឬទេ? បើនិយាយឲ្យចំទៅសិស្សចុះខ្សោយតែចំពោះមុខវិជ្ជាខ្លះទេ មានខ្សោយខាងភាសាបារាំងជាពិសេស ឯខាងគណិតសាស្ត្រនឹងវិទ្យាសាស្ត្រក៏រឹតសិស្សនៅដដែល ខាងអក្សរសាស្ត្រជាតិក៏រឹតឡើងច្បាស់ណាស់ ។

ក្នុងក្របខ័ណ្ឌអត្ថបទនេះ មិនអាចនិយាយពីវិធីដោះស្រាយល្អិតល្អន់បានទេ ដើម្បីកុំឲ្យវែងពេក ៗ យើងគ្រាន់តែលើកបញ្ហាខ្លះឲ្យឃើញទំហំៗ សូមមិត្តសាស្ត្រាចារ្យ បង្ហាញទំហំបញ្ហានេះជូនជាទីសណ្ដាប់ដល់ឪពុកម្ដាយសិស្សផង ដើម្បីឲ្យលោកឃើញថាលក្ខណសម្បត្តិ នៃការសិក្សាពីដើមនឹងសព្វថ្ងៃខុសគ្នាស្រឡះ ។ ការប្រដូចសិស្សសព្វថ្ងៃទៅនឹងសិស្សជំនាន់ដើម មិនសូវសមហេតុសមផលទេ ហើយការវិនិច្ឆ័យថាសិស្សសព្វថ្ងៃ "ខោលម្សៀតគ្មានចេះអ្វី" រឹតតែមិនសមណាស់ទៅទៀតៗ




## វិទ្យាសាស្ត្រធម្មជាតិដោយដើរលេង

បង្រៀនវិទ្យាសាស្ត្រធម្មជាតិនៅតែក្នុងបន្ទប់ តាំងពីដើមឆ្នាំដល់ចុងឆ្នាំហាក់ដូចជាគ្មានន័យសោះ ៗ សិស្សមុខជាធុញទ្រាន់មិនខានចំពោះមុខវិជ្ជានេះ ទោះជាសាលានោះមានសម្ភារៈ សំរាប់ពិសោធនឹងបង្ហាញគ្រប់គ្រាន់យ៉ាងណាក៏ដោយ ៗ ដើម្បីឲ្យវិទ្យាសាស្ត្រធម្មជាតិ ទាក់ទងនឹងធម្មជាតិមែនៗ គប្បីសាស្ត្រាចារ្យនាំឲ្យសិស្សចេញក្រៅយ៉ាងហោចឲ្យបានពីរបីដងក្នុងមួយឆ្នាំ ៗ

### ផលប្រយោជន៍នៃការចេញទស្សនាធម្មជាតិ

សិស្សសប្បាយចិត្តជានិច្ច តែកាលណាឮថា លោកគ្រូនាំ "ដើរលេង" ដោយវាបានផុតអំពីការធុញថប់អផ្សុក ស្ងាប់នៅក្នុងថ្នាក់ ៗ ប៉ុន្តែមុននឹងចេញ ត្រូវទាំងអស់គ្នាយល់ថា មិនមែនជាការ "ដើរលេង" ធម្មតាទេ ៗ ទាំងសិស្ស ទាំងគ្រូ ទាំងចាងហ្វាងសាលា ទាំងឪពុកម្ដាយសិស្ស ត្រូវយល់យ៉ាងនេះឲ្យស្រេច ៗ បើគ្រាន់តែចេញដើម្បីលំហើយកាយលំហែចិត្តប៉ុណ្ណោះទេ នោះមិនបាច់សាស្ត្រាចារ្យជូនទៅទេ ៗ

### ការរៀបចំចេញទស្សនាធម្មជាតិ

ការចេញដើរយ៉ាងនេះ ត្រូវឲ្យប្រើពេលមួយថ្ងៃ ឬ កន្លះថ្ងៃ ជាហេតុនាំឲ្យសាស្ត្រាចារ្យវិទ្យាសាស្ត្រធម្មជាតិពិបាកសូម "ខ្ចី" ម៉ោងពីសាស្ត្រាចារ្យឯទៀត ឬមួយយកថ្ងៃឈប់ណាមួយតែម្ដង ៗ សាស្ត្រាចារ្យត្រូវពិគ្រោះ នឹងបានសេចក្ដីយល់ព្រមពីចាងហ្វាងសាលា ហើយបើសិស្សទៅជាមួយច្រើនលើសពី ៤០ នាក់ទៅ គប្បីសូមអនុរក្សម្នាក់ទៅមួយផង ៗ កុំនាំសិស្សលើសពីមួយថ្នាក់ឲ្យសោះ ពុំនោះសោត, ការរៀនសូត្រពុំបានការទេ ៗ

សាស្ត្រាចារ្យត្រូវទៅស្គាល់ទីកន្លែងដែលបំរុងនាំសិស្សទៅមើលជាច្រើនថ្ងៃមុន ត្រូវស្គាល់វត្ថុនានាដែលមាននៅទីនោះ ដែលគួរឲ្យសិស្សស្រាវជ្រាវឃើញខ្លួនឯង ៗ សាស្ត្រាចារ្យកំណត់សម្ភារៈដែលម្នាក់ៗ ត្រូវយកទៅជាមួយ ដូចជាញញួរ (បើចង់រៀនពីថ្ម) បន្ទះកាំបិតកោរពុកមាត់

ប្រអប់ឬថបសំរាប់ទុកដាក់វត្ថុដែលរកឃើញ តែវពន្លឹកពីរបី(ដែលសាស្ត្រាចារ្យត្រូវតែមាន)...ៗលៗ

ម្យ៉ាងទៀត សាស្ត្រាចារ្យត្រូវគិតគូរផ្ដាល់នូវបញ្ហាដទៃពីការបង្រៀន ដូចជាសូមច្បាប់ម្ចាស់ដី, ម្ចាស់កន្លែងដែលបំរុងទៅមើល បញ្ហាដឹកនាំតាមគោចក្រយាន ឬរថយន្ត បញ្ហាបាយទឹកថ្ងៃត្រង់ បញ្ហាប្រអប់ថ្នាំសង្គ្រោះជាដើម ៗ

ប្រធានដែលអាចយកទៅបង្រៀនក្នុងការចេញទស្សនាមានយ៉ាងនេះ ៗ នាំសិស្សទៅមើលស្រែដែលគេទើបភ្ជួរហើយថ្មី ៗ ហើយដាក់ភារៈឲ្យរើសសត្វល្អិតៗគ្រប់យ៉ាង ដែលមាននៅក្នុង អាចម៍បំណាស់យកមកដាក់ក្នុងប្រអប់ ៗ គ្រាន់តែក្នុងការស្រាវជ្រាវនេះ សិស្សអាចប្រទះរូបភាពផ្សេងៗដែលដង្កូវដូងវិវត្តទៅជាសត្វកំពូលអាចម៍ៗ សាស្ត្រាចារ្យអាចនាំសិស្សទៅលេងភ្នំ មើលកន្លែងគេបាញ់ថ្ម រើសបំណែកថ្មយកមកពិនិត្យ តាមឈ្មោះថ្ម រៀបចែកថ្មតាំងនោះទៅតាមដើមកំណើត តាមគ្រួសារវា ៗលៗ បើវិទ្យាល័យនៅជិតសមុទ្រ ក៏គួរនាំសិស្សទៅរើសសាកយ ខ្ចង ខ្ចៅ ផ្កាថ្ម និងពិនិត្យសមាសភាពដីខ្សាច់ ៗ ការរើសនិងផ្ចែប្រធាន ស្រេចតែលទ្ធភាពដំបន់និមួយៗ និងការប៉ិនប្រសប់របស់សាស្ត្រាចារ្យទេ ៗ

និយាយមកប៉ុណ្ណេះ ឃើញថាការនាំសិស្ស "ដើរលេង" នេះនាំឲ្យសាស្ត្រាចារ្យនឿយហត់ជាងបង្រៀនក្នុងថ្នាក់ ១ជា១០ ប៉ុន្តែលទ្ធផលល្អ បើចេះណែនាំត្រឹមត្រូវក៏បាន ១ជា១០ លើសពីក្នុងថ្នាក់ដែរ ៗ

## គប្បីមានវិន័យបន្តិចបន្តួច

ការនាំចេញបែបនេះ ច្រើនធ្វើឲ្យសិស្សគិតខាងផ្នែកសប្បាយច្រើនជាង ផ្នែកខ្លឹមសាររៀនសូត្រ; ម្ល៉ោះហើយសិស្សច្រើនតែរាយមាយរហេតរហូត និយាយមិនស្ដាប់ ៗ ពិតមែនហើយ ក្នុងដំណើរនេះ បរិយាកាសត្រូវរីករាយមិនត្រូវសង្រ្គមដូចនៅក្នុងថ្នាក់ទេ ប៉ុន្តែសាស្ត្រាចារ្យគួររំលឹកសិស្សឲ្យមានវិន័យបន្តិចបន្តួច គឺថាម្នាក់ៗ ជៀសវាងកុំឲ្យរំខានដល់អ្នកឯទៀត ៗ គួរកំណត់ ឲ្យមកជួបជុំនឹងកន្លែងទាន់ពេលវេលា កុំដើរទៅណាឆ្ងាយដាច់ពីក្រុម ដោយមិនប្រាប់គេ ស្លៀកពាក់យកប្រដាប់ប្រដាឲ្យសមនឹងកាលៈទេសៈដើរលេង ៗ ជួនកាលគ្រាន់តែប្រាប់ថា "កុំឲ្យអត់របៀបរបបខ្មាសអ្នកស្រុកដៀលឈ្មោះសាលា" តែប៉ុណ្ណេះសិស្សក៏អាចយល់បាន ៗ

## ការចាប់អារម្មណ៍របស់សិស្សមានប្លែកៗ

នៅកណ្តាលធម្មជាតិ មានវត្ថុច្រើនណាស់ ដែលអូសទាញអារម្មណ៍សិស្សឲ្យ «ចាប់នេះចាប់នោះ មិនដោះត្រង់ណា» ។ មុខងារសាស្ត្រាចារ្យ ត្រូវបេះទាញអារម្មណ៍សិស្សទាំងអស់ មកលើវត្ថុដែលត្រូវរៀនគឺបេះណែនាំឲ្យពិនិត្យម៉ត់ចត់ ឲ្យមានការឆ្ងល់ ឲ្យមានការដេញដោលស្រាវជ្រាវ ៗ ។ ឧទាហរណ៍៖ ដាក់ការៈឲ្យសិស្ស ៥នាក់ពិនិត្យឈើពុក ឬគល់ឫស្សីពុកមួយដុំ តើសត្វអ្វីស៊ីឈើ ? វាជីករូងយ៉ាងណាក្នុងសាច់ឈើ ? វាដញ្ជូនកំទេចឈើទៅចោលឯណា ?... ។ល។ ដាក់ការៈឲ្យសិស្ស៣នាក់ពិនិត្យអាចម៍គោមួយដុំ មានសត្វអ្វីខ្លះនៅក្នុងនោះ? ( ចាប់សត្វទាំងនោះឲ្យបានទាំងអស់ដាក់ប្រអប់ ) ហេតុអ្វីក៏អាចម៍មួយចំនួនក្លាយទៅជាដី ? នៅក្រោមអាចម៍គោ មានរូងតូច ៗ ចុះទៅក្នុងដី តាមមើលតើរូងនោះជារូងអ្វី ? . . . ។ល។

ក្នុងពេល «ដើរលេង» បែបនេះ គេសង្កេតឃើញសិស្ស ៣ បែប ៖

— បែបទី ១ គឺសិស្សដែលរពឹសចូលចិត្តឆ្កើសកកាយ រកឃើញខ្លួនឯងហើយពិនិត្យ ៗ

— បែបទី ២ គឺសិស្សដែលចាំតែគេរកឃើញ ហើយបានតែទៅមើល ប៉ុន្តែមើលហើយបេះពិចារណា ទីងឲ្យមតិត្រឹមត្រូវ ៗ

— បែបទី ៣ គឺសិស្សដែលមិនរវីរវល់ទីងការងារនេះ ចាប់គាន់ដោយច្បិចបៀម ខ្លាចប្រឡាក់ដៃជើង ចាំតែមើលគេហើយកត់តាមគេ ៗ

សាស្ត្រាចារ្យមិនបាច់បង្ខំឲ្យសិស្សទាំងអស់ដុតដៃដុតជើងដូចគ្នាទេ គប្បីនិយមទៅតាមចំណង់ខ្លះទៅចុះ ៗ កាលណាសិស្សបានវត្ថុអ្វីយកមកសួរដេញដោល សាស្ត្រាចារ្យត្រូវជៀសវាងកុំអាលឆ្លើយប្រាប់ចំភ្លាម កុំអាលតបទីងការឆ្ងល់ដោយប្រាប់តែមួយម៉ាត់ឲ្យក្មួយស្គាល់ទាំងអស់នោះឲ្យសោះ ៗ ម្យ៉ាងទៀត កុំភ័យថាសិស្សដៀលថាលោកគ្រូពាល់ប្រាជ្ញ ៗ មុខងារសាស្ត្រាចារ្យ គឺនាំឲ្យគិត នាំឲ្យរក មិនមែនចោទបញ្ហាឲ្យសិស្សហើយដោះស្រាយជួសសិស្សភ្លាម ៗ ឲ្យទាន់ចិត្តសិស្សនោះទេ ៗ រឿងនេះពិតក្នុងវិទ្យាសាស្ត្រធម្មជាតិ ក៏ដូចក្នុងមុខវិជ្ជាឲ្យបេះកត់លើក្រដាសគូររូបទុក ទីងស្រង់យកវត្ថុណា កាត់គាស់យកផ្នែកណា ទៅសាលាវិញ ៗ

## របាយការណ៍ជាការចាំបាច់

ត្រឡប់មកសាលាវិញ សាស្ត្រាចារ្យត្រូវណែនាំសិស្សម្នាក់ ៗ ឲ្យធ្វើសេចក្តីរបាយការណ៍ជាលាយលក្ខណ៍អក្សរ ៗ មិនមែនធ្វើតែសេចក្តីពីរឿង

ដើរលេងទេ គឺយកកំណត់ដែលកត់បានប៉ុន្មាន យកវត្ថុដែលខ្លួនបានប្រមូលទាំងប៉ុន្មាន មកពិនិត្យរំលឹកឡើងវិញ ហើយសរសេរយ៉ាងងាយយល់បំផុត ។ សាស្ត្រាចារ្យជួយឲ្យអត្ថសេចក្តី មានលក្ខណៈនឹងខ្លឹមសារវិទ្យាសាស្ត្រខ្លះៗផង ។

វត្ថុដែលប្រមូលបានទាំងអស់គ្នា ដូចជាដុំថ្មផ្សេងៗ ស្លឹក,ផ្កា,សំបកឈើ, សត្វល្អិត និងសត្វឯទៀតៗត្រូវបានជ្រើសរើសយកមកតាបឲ្យស្ងួតក្នុងសៀវភៅ ឬត្រាំស្រា បិទស្លាកដាក់ឈ្មោះនិងទីកន្លែងដែលគេឃើញ ហើយលើកទុកជាសម្បត្តិនៃសារៈមន្ទីរបស់សាលា ។

សេចក្តីសន្និដ្ឋាន

ក្នុងក្របខណ្ឌកម្មវិធី នៃមធ្យមសិក្សាសព្វថ្ងៃ សាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រធម្មជាតិ អាចនាំសិស្ស «ដើរលេង» របៀបដូចយើងបានអធិប្បាយខាងលើជាពិតប្រាកដ ទោះសិស្សនោះនៅថ្នាក់ទី៦, ទី៥, ទី៤, ទី៣ ឬនៅថ្នាក់ទីបញ្ចប់ក៏ដោយៗ បើសាស្ត្រាចារ្យ រៀបចំការទស្សនាបានម៉ត់ចត់សិស្សនឹងកត់ចាំក្នុងចិត្តមួយជីវិតហើយនឹកគុណគ្រូមិនភ្លេច ដែលបាននាំខ្លួនឲ្យជ្រួតជ្រាបវិធីពិនិត្យពិចារណា ជាប់ចិត្តនឹងវិជ្ជាមួយដែលពីដើមខ្លួនធុញទ្រាន់ជាទីបំផុត ។ រីឯសាស្ត្រាចារ្យក៏បានឱកាសមួយល្អ នឹងប្រទះសិស្សម្នាក់ឬពីរនាក់ដែលមានសមត្ថភាពខាងស្រាវជ្រាវហើយដែលមានអនាគតទៅជាគ្រូបណ្ឌិតបានខាងវិទ្យាសាស្ត្រធម្មជាតិ ។

ពិសេសទៅទៀត ឱកាស ដើរលេង បែបនេះនាំឲ្យគ្រូបានស្និទ្ធស្នាលនឹងសិស្ស ជាងនៅក្នុងសាលា ។ សិស្សមិនឃើញគាត់ជាអាចារ្យពាក់មុខមាំដូចធ្លាប់ស្គាល់ វាត្រឡប់ជាឃើញជនម្នាក់ស្រោះស្រាយគួរចូលចិត្ត ទទួលទានបាយកញ្ចប់ដូចគ្នា ពាក់មួកកន្ទេលដូចគ្នា លាត់ជើងខោលុយទឹកដូចគ្នា ហើយនិយាយកំប្លែងសើចក្អាកក្អាយអស់ពីពោះជាមួយគ្នា ។ វាស្រឡាញ់និងនឹករឭកជននោះមួយជីវិត ។

(អនុលោមតាមសៀវភៅគរុកោសល្យ លេខ ២៧ ខែមេសា ១៩៦១)

## អភ័យទោស

គណៈកម្មាធិការនិពន្ធ សូមអភ័យទោសពីសំណាក់មិត្តអ្នកអានទាំងឡាយ ហើយជាពិសេសពីសំណាក់មិត្តព្រំសុផ្សារ ដោយនៅក្នុងទស្សនាវដ្តីលេខ៥ របស់យើង យើងបានផ្សាយអត្ថបទរបស់មិត្តដោយធ្លាំធ្លង ច្រឡូកច្រឡំ ជាការនាំឲ្យបាត់អត្ថរសខ្លះ ។ កំហុសដ៏អចេតនានេះបានបណ្តាលមកពីពេលពុម្ព ។ តទៅអនាគត យើងនឹងចៀសវាងឲ្យបានជាអតិបរមា ។

# សាស្ត្រាចារ្យយើង ត្រូវធ្វើយ៉ាងណា ដើម្បីឱ្យសិស្សយើង ចាប់ចិត្តចំពោះមុខវិជ្ជាខ្មែរ ? (១)

## ១-ទំហំនៃបញ្ហា

នេះជាបញ្ហាមួយ ដែលមើលពីចំងាយទៅហាក់ដូចជាងាយសោះ ព្រោះថាជាបញ្ហាអចិន្ត្រៃយ៍មួយ ដែលមិត្តយើងបានបំពេញរាល់តែថ្ងៃ ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ តែបើយើងពិនិត្យឱ្យជ្រៅបន្តិចទៅ នោះយើងនឹងឃើញច្បាស់នូវទិដ្ឋភាពពិតរបស់វា គឺថាបញ្ហានេះវាពិបាក ។ កស្តុតាង គឺរហូតមកទល់នឹងថ្ងៃនេះ មិនទាន់មានសាស្ត្រាចារ្យយើងណាម្នាក់ ហ៊ានអះអាងថាខ្លួនមានសម្បទាពេញលេញក្នុងចំណុចនេះនៅឡើយទេ លើកលែងតែសាស្ត្រាចារ្យពីរ-បីនាក់ចេញ ដែលគេស្គាល់ឈ្មោះទាំងអស់ ។

ហើយការដែលយើងយកបញ្ហាដ៏ពិបាកនេះមកចោទ គឺក្នុងបំណងនឹងបបួលមិត្តយើងឱ្យត្រិះរិះដល់បញ្ហានេះ ហើយនឹងបំផុសមតិ,ពិភាក្សារកផ្លូវចេញទាំងអស់គ្នា ឆ្ពោះទៅលើកតម្លៃអក្សរសាស្ត្រយើង ដោយបានសិស្សទាំងអស់ចាប់ចិត្ត នឹងខំយកចិត្តទុកដាក់ ដល់ការបង្រៀនរបស់យើង ។

## ២-សភាពការណ៍បញ្ហា

ឯសភាពការណ៍នៃបញ្ហានេះ ក្នុងពេលសព្វថ្ងៃគឺដូចនេះ ៗ មួយចំណែកយើងសង្កេតឃើញថា បច្ចុប្បន្ននេះ,មានសិស្សចូលចិត្តសិក្សានឹងត្រិះរិះពីអក្សរសាស្ត្រជាតិ ជាងមុនៗឆ្ងាយណាស់ ៗ យើងអាចបញ្ជាក់ខនេះបាន ដោយគ្រាន់តែមើលសិស្ស ៗ ដែលខំអានសៀវភៅក្នុងកម្មវិធី, សៀវភៅអត្ថាធិប្បាយផ្សេង ៗ លក់តាមបណ្ណាគារ, សិស្សៗ ដែលប្រជ្រៀតគ្នាយ៉ាងកកកុញទៅរៀននៅពេលយប់ (cours du soir ) ដែលពីដើមមានតែខាងគណិតសាស្ត្រ ហើយនឹងសិស្សៗ ដែលខ្វល់ខ្វាយក្នុងចិត្តជាពិសេស ចំពោះសាស្ត្រាចារ្យខាងអក្សរសាស្ត្រខ្មែរណាដែល“បង្រៀនមិនល្អ„ហើយដែលពីដើមសិស្សៗតែងយល់ថា“យ៉ាងម៉េចក៏បានដែរ„នោះ ៗ បើតាមយោបល់យើង ការប្រែប្រួលសភាពការណ៍យ៉ាងនេះ គឺអាស្រ័យស្មារតីនៃការកែទំរង់កម្មវិធីសិក្សា ១៩៥៨ ដែលសំដៅទៅធ្វើខេមរូបនីយកម្មការសិក្សា ព្រមទាំង

(១)យើងសំដៅបរមាធិប្បាយអក្សរសាស្ត្រជាពិសេស

បានតម្កើងមេគុណនៃវិញ្ញាសា ខាងបរមាធិប្បាយ (dissertation) ខ្ពស់ដល់ទៅ៣, នៅពេលប្រឡងផង, ម្យ៉ាង ហើយម្យ៉ាងទៀតក៏មកពីស្មារតីភ្ញាក់រលឹកស្នេហាជាតិនៃយុវជនយើងផង ។ ប៉ុន្តែ ទិដ្ឋភាពមួយទៀតនៃសភាពការណ៍ ដែលយើងចង់គូសបញ្ជាក់ក្នុងទីនេះ ហើយដែលជាកម្មវត្ថុនៃអត្ថបទផងនោះ គឺមានសិស្សមួយចំនួនមិនមែនតិចតួចបានចាប់ផ្ដើមសឹងតែនឿយណាយ នឹងការបង្រៀនអក្សរសាស្ត្រ របស់សាស្ត្រាចារ្យយើងខ្លះៗនៅក្នុងអាគារខ្លះៗ ។ កស្តាង គឺដល់ “ម៉ោងនោះ„ មានសិស្សឈប់ច្រើន ខ្លះមានច្បាប់ ខ្លះឥតច្បាប់ ខ្លះ“ឈឺ” ។ នេះយើងក៏អាចនិយាយបានដែរថា មកពីវិន័យរបស់សាលានោះមិនតឹងរឹង ឬក៏មកពីសតិអារម្មណ៍របស់សិស្សនោះនៅទាបពេក ។ ប្រហែលជាមែន! ប៉ុន្តែបើយើងហើយ គិតតែពីទំលាក់មូលហេតុនេះទាំងស្រុងទៅលើសិស្សហើយដកខ្លួនយើងចេញឲ្យផុតស្រឡះនោះ យើងក៏មិនអាចនឹងធ្វើវិសិដ្ឋការខ្លួនយើង (se perfectionner) បានឡើយ ហើយយើងមិនតាំងសត្យានុមតិ (objectif) ទៀតផង! ព្រោះថា សិស្សដែលនៅសល់ក្នុងថ្នាក់តាំងប៉ុន្មានដែលសុទ្ធតែជាអ្នកចេះគិតមុខគិតក្រោយ ជាសិស្សល្អចេះគោរពគ្រូ ជាអ្នកមានគំនិតជាតិគ្រាន់បើនោះក៏ហាក់ដូចជាតានតឹងក្នុងចិត្តដែរ បើឃើញថាការបង្រៀនរបស់យើង មាននិន្នាការ (tendance) ទៅរកសភាពដដែល ៗ ហើយមិនជ្រៅជ្រះ វែងឆ្ងាយ មិនក្បោះក្បាយ មិនពិស្ដារ រួចមើលទៅឃើញយើងហាក់ដូចជា ចំបញ្ចេញអស់ពីក្នុងខ្លួនតែប៉ុណ្ណឹងហើយ ៗ ហើយបើយើងយកឧទាហរណ៍មួយទៀតមកបញ្ជាក់ នោះកាន់តែជាក់ស្ដែងមែនទែន! យើងមើលសាស្ត្រាចារ្យអក្សរសាស្ត្របារាំងបង្រៀនសិស្សថ្នាក់ទី ៣ ឬ ទី២ – យើងនិយាយក្នុងទីនេះតែពីសាស្ត្រាចារ្យត្រឹមត្រូវ ៗ ឃើញថាសិស្សដូចជាជាប់ចិត្តណាស់ ហើយចំប្រុងស្ដាប់យ៉ាងសកម្ម ។ ហើយអក្សរសាស្ត្រនោះនឹងថាងាយយល់ទៅក៏មិនមែនដែរ ដូចជាភាសារបស់វ៉ុលទែរ, ហ៊ុយហ្គោ, គរណី, រ៉ាស៊ីន, ម៉ូលីយែរ, ម៉ុងតេះស្គីយើ . . ។ តើមកពីអ្វីក៏ដូចនេះ? បើតាមយោបល់យើងទៀត នេះគឺមកពីសាស្ត្រាចារ្យចេះវិធីសាស្ត្រ (technique) ក្នុងការធ្វើអត្ថាធិប្បាយម្យ៉ាង, ស្គាល់អក្សរសាស្ត្រនោះច្បាស់លាស់ម្យ៉ាង ហើយម្យ៉ាងទៀតដែលជាចំសំខាន់នោះ គឺមកពីសាស្ត្រាចារ្យនោះមានវប្បធម៌ទៅទូលំទូលាយ ។ សាស្ត្រាចារ្យណាដែលបំពេញលក្ខណៈសម្បត្តិទាំង៣នេះ

បានច្បាស់ជាអាចបង្រៀនបានដោយសក្តិសិទ្ធិ ។

៣- ដូចនេះតើសាស្ត្រាចារ្យយើងត្រូវធ្វើយ៉ាងណា ដើម្បីឱ្យសិស្សយើងចាប់ចិត្តចំពោះមុខវិជ្ជាខ្មែរ ?

ក) បើតាមយោបល់យើង សាស្ត្រាចារ្យគង់តែចេះរៀនទាំងអស់ដែលនៅក្នុងកម្មវិធីថ្នាក់របស់ខ្លួនឲ្យបានច្បាស់លាស់ ;

ខ) គង់តែស្គាល់ចលនាអក្សរសាស្ត្រឲ្យបានជាមធ្យម (សម័យអង្គរ សម័យក្រោយអង្គររហូតតាមលំដាប់មកដល់ក្នុងរជ្ជកាលព្រះបាទអង្គឌួង សម័យអាណានិគមនិយម សម័យឯករាជ្យ) និងមានទស្សនៈមួយដ៏សត្យានុមតិ ក្នុងការស្គាល់សង្គមខ្មែរយើង (តាមលំដាប់ប្រវត្តិសាស្ត្រ) ដែលជាប្រភពបញ្ចេញអក្សរសាស្ត្រនេះ;(១)

គ) ចេះវែកញែកគន់ឥទ្ធិពលពុទ្ធនិយម ពីព្រាហ្មណ៍និយម ពីខេមរនិយម ពីបរទេសនិយម ពីមនុស្សនិយម ហើយចេះគោលធំៗនៃចលនាទាំងនេះ ;

ឃ) គង់តែមាននូវសញ្ញាណជាថ្មីនៃទស្សនវិជ្ជា (notions élémentaires de philosophie) នៃតក្កវិជ្ជា (logique) និងសីលវិជ្ជា (morale) ខ្លះៗ ;

ង) គង់តែចេះវិធីសាស្ត្រពិនិត្យ និងអត្ថាធិប្បាយអក្សរសាស្ត្រ ដោយយើងឧស្សាហ៍អានអក្សរសាស្ត្របរទេសថែមទៀត ;

ច) គង់តែមានវប្បធម៌ទូទៅឲ្យបានទូលំទូលាយដោយព្យាយាមអានសៀវភៅ ទស្សនាវដ្តី សារពត៌មានខ្មែរនិងបរទេស សិក្សាវប្បធម៌បរទេសបន្ថែម ដើម្បីមានទុនយកមកប្រៀបធៀបគ្នា យកមកធ្វើជាឧទាហរណ៍បញ្ជាក់ យកមកឆ្លុះមើលអក្សរសាស្ត្រយើង ;(២)

ខនេះ ជាខសំខាន់ហើយពិតណាស់ ៗ យើងជាសាស្ត្រាចារ្យ ដែលមានភារៈបំភ្លឺយុវជននោះយើងគង់តែភ្លឺខ្លួនឯងជាមុនសិន ៗ ហើយដើម្បីឲ្យមានពន្លឺ, យើងគង់តែសិក្សា គង់តែស្រឡាញ់សៀវភៅ ទុកសៀវភៅជាទ្រព្យធនជាកំណប់ដ៏ប្រសើរបំផុតរបស់យើង ហើយស្មុះស្មាញរកទិញសៀវ

(១) សូមអានសៀវភៅ ‹‹ប្រវត្តិអក្សរសាស្ត្រខ្មែរ›› និង ‹‹អត្ថាធិប្បាយរឿងព្រេងខ្មែរ›› របស់លោក អ៊ុម ឌុក

(២) សៀវភៅអក្សរសាស្ត្រ បារាំង នៅបណ្ណាគារ ហុង-ប៊ូ, ៤វិថីប៉ិចនូភាជា, ភ្នំពេញ

សៀវភៅអក្សរសាស្ត្រ ចិន ជាភាសាបារាំង, បណ្ណាគារ វ៉ង់សៃលី, ១៣០ វិថីព្រះបាទអង្គអេង, ភព

សៀវភៅអក្សរសាស្ត្រ វៀតណាម ជាភាសាបារាំង បណ្ណាគារ អ៊ីដេអាល ទល់មុខរោងភាពយន្តអេដែន , ភព

ភៅល្អៗដែលមានលក់ ព្រមទាំងជំរុញឲ្យទាន់ពេលវេលានូវការចេញសៀវភៅ ឬ សៀវភៅមកដល់ថ្មីៗ

ឆ) គួរតែលើកស្ទួយស្នេហាជាតិឲ្យខ្ពស់ ដើម្បីបណ្តុះវប្បធម៌ជាតិសំរាប់ខ្លួនយើងផ្ទាល់ ហើយដើម្បីមានអំណត់ក្នុងការពន្យល់យុវជនយើង ឲ្យបានយល់ ដោយរីករាយនិងដោយសុទ្ធចិត្ត; ហាក់ដូចជាបងនិងប្អូន

ជ) គួរតែមានអាកប្បកិរិយាសមរម្យ ជិតស្និទ្ធ យោគយល់យុវជនយើង ពីព្រោះយុវជន, តាមធម្មជាតិរបស់គេ, គេមិនស្រឡាញ់ មិនចូលចិត្តហើយស្អប់ណាស់អាកប្បកិរិយា „ធ្វើបុក„ ឬ „ផ្តាច់ការ“ ...។ល។

## ៤–សន្និដ្ឋាន

ហើយបើនិយាយរួមទៅ ដើម្បីឲ្យសិស្សយើងយកចិត្តទុកដាក់ ដល់ការបង្រៀន អក្សរសាស្ត្ររបស់យើង

❧សាស្ត្រាចារ្យយើងគួរតែខិតខំ កសាងសមត្ថភាពខ្លួន សំដៅទៅធ្វើឲ្យការបង្រៀនរបស់ខ្លួនមានខ្លឹមសារជ្រៅជ្រះទូលំទូលាយ មានសំរស់រស់រវើក ដោយគំនិតនិងពាក្យពេចន៍ដែលខ្លួនបញ្ចេញទៅ ទាំងប៉ុន្មាននេះនោះពុំ វែកញែកដឹកដំណើរវិភាគ ហើយបង្អិលមើលអត្ថបទនោះៗ ឬរឿងនោះៗ គ្រប់ជ្រុងជ្រោយ,កាត់ជ្រៅ,ក្នុងក្រៅ, (និយាយខ្លីពេករួមៗ នាំឲ្យមិនយល់, តែប្រយ័ត្នកុំបែកជាឆ្ងាយហួសជាស្ទើរតែក្បែរខ្លឹមនោះ នាំឲ្យខ្លួនឯងហត់ឥតប្រយោជន៍ ហើយនាំឲ្យតែសិស្សវង្វេង និយាយដោយមិនដើរតាមគោលសារៈ ពីមួយម៉ោងទៅមួយម៉ោងនាំឲ្យសិស្ស ទាន់ក្រោយទៀតណាយ, និយាយគ្មានគោលរាយរាយសោះក៏មិនកើត, គ្មានដៃគ្មានជើងពេក សំដីគ្មានខ្លឹមសារក៏មិនល្អ ។

❧ឯចំណុចមួយ ដែលយើងត្រូវចងចាំជានិច្ចនោះ គឺមុននឹងបង្រៀនអត្ថបទមួយ ឬរឿងមួយ យើងគប្បីសំរេចឧត្តមគតិរួម នៃអត្ថបទឬសៀវភៅនោះក្នុងចិត្តយើងឲ្យហើយទៅ ហើយយកអាកប្បកិរិយាមួយ ឲ្យជាក់លាក់ បន្ទាប់ពីបានធ្វើវិភាគអត្ថបទឬរឿងនោះ យ៉ាងសត្យានុមតិរួចហើយ ។ អាកប្បកិរិយានេះ យើងក៏នឹងនៅប្រែទៀត បើសិនជាការពិភាក្សាជាមួយសិស្សបានលេចពន្លឺថ្មីមក ។ តែជាដំបូង គ្រូត្រូវមានឥរិយាបថមួយឲ្យច្បាស់សិន ព្រោះពាក្យថា:លើកតម្លៃអក្សរសាស្ត្រ មិនមែនចេះតែពន្យល់សំរាប់ តាមតែអ្នកនិពន្ធឬលើកដំកើងឬការពារគុណសរសើរមតិណា ,អត្ថរូបណាដែលខុស

ផ្គង់ផ្ទុយពីវិចារណញ្ញាណ, ផ្ទុយពីតក្កវិជ្ជា(logique) ហើយមិនគួរលើកដំកើងនោះទេ ។ ក្នុងករណីនេះត្រូវតែរិះគន់រកញែកឲ្យជ្រៅជ្រះនូវរឿងនោះ ដោយយកមូលដ្ឋាន( base) ប្រាកដប្រជាមកផ្អែកលើ ទើបយើងលើកតម្កើងអក្សរសាស្ត្របានហើយ ទើបសិស្សចាប់ចិត្តកើត ។ តែក៏មិនមែនថា ត្រូវតែរិះគន់ការដែលមិនគួររិះគន់ដែរ ក្នុងករណីនេះ តោងតែសរសើរ ប៉ុន្តែក៏រកមូលដ្ឋាន,រកហេតុផល (raison )មកសំអាងប្រត្យក្សផង !

ហើយជាអវសាន ការវែកញែករបស់យើង តោងតែបិតជាប់នឹងការពិតជាក់ស្តែង ជាប់នឹងជីវភាពមនុស្សលោក ទើបសិស្សចាប់ចិត្ត ពីព្រោះបង្រៀនដូចនេះ គេអាចឃើញច្បាស់នូវខ្លឹមសារនូវប្រយោជន៍តិច ឬច្រើននៃអត្ថបទនោះ , នូវសមត្ថភាពនឹងសត្យានុមតិ (objectivité) នឹងសម្បជញ្ញៈនឹងមនសិការៈរបស់សាស្ត្រាចារ្យនោះ ។ ទាំងនេះថែមលើភាគបរិកិរិយាសមរម្យនឹងថ្ងៃថ្នូរ ព្រមទាំងជិតស្និទ្ធរបស់យើងទៅទៀត គឺជួយយើងឲ្យសំរេចជោគជ័យជាមិនខាន ។ បើមិត្តមិនជឿ សុំធ្វើពិសោធន៍ខ្លួនឯងមើលទៅ !

ថ្មី ៗ នេះ ដើម្បីប្រមូលអត្ថបទចុះទស្សនាវដ្តីលេខ ៦ របស់យើង យើងបានសរសេរអំពាវនាវដល់មិត្តយើងមួយចំនួន ។ មិត្តខ្លះបានឮ សេចក្ដីអំពាវនាវនោះ ហើយបានចាប់ផ្ដើម ផ្ញើយតបមកយើងមុនគេ ។ នៅប្រួបនេះ យើងមានសេចក្ដីរីករាយនឹងចុះផ្សាយនូវអត្ថបទ របស់មិត្តគិម ស៊ីយ៉ុង សាស្ត្រាចារ្យ ខាងប្រវត្តិសាស្ត្រ ។ គណៈកម្មាធិការនិពន្ធ សូមសំដែងនូវសេចក្ដីសរសើរ ដ៏ស្មោះស្ម័គ្រដល់មិត្តស៊ីយ៉ុងហើយហ៊ានសង្ឃឹមថា មិត្តឯទៀត ៗ ក៏មុខជាមិនសុខចិត្តបណ្ដោយឲ្យសេចក្ដីអំពាវនាវរបស់យើង នៅសាបសូន្យឡើយ ។ យើងរំលឹកម្ដងទៀតថា អត្ថបទងាយសរសេរជាងគេនោះ គឺអត្ថបទដែលស្ដីពីមុខវិជ្ជាដែលមិត្តបង្រៀន ។

# ការពិសោធន៍ពីប្រវត្តិសាស្ត្រ

ដោយ គិម ស៊ីយ៉ុង

សាស្ត្រាចារ្យ អនុវិទ្យាល័យព្រះសូមាព្រៃល្វា

## ១= ការពិសោធន៍

ដោយនៅខ្ញុំដែលខ្ញុំដើរពេក ក្នុងការធ្វើឲ្យសិស្សយល់មេរៀនប្រវត្តិសាស្ត្រ ខ្ញុំនៅខ្វះការពិសោធន៍ខាងគរុកោសល្យនោះច្រើនណាស់ៗ ដូចនេះ ក្នុងការបង្រៀនសិស្សនោះ មានការរអាក់រអួលក៏ច្រើនដែរ ក្នុងដំហានដំបូងៗ តែដោយការរិះរកនូវមធ្យោបាយផ្សេងៗនោះ ខ្ញុំក៏អាចនឹងដឹកនាំសិស្សខ្ញុំឲ្យបានយល់នូវមេរៀន ហើយបញ្ចប់កម្មវិធីសិក្សាសមទៅតាមកាលដ៏គួរផងៗ

មិត្តយើងសុទ្ធតែដឹងហើយថា កម្មវិធីបានតំរូវឲ្យការបង្រៀនប្រវត្តិសាស្ត្រ ធ្វើជាភាសាបារាំង លើកលែងតែថ្នាក់ទី ៦ ទំនើបចេញ ៗ ដូចនេះ មេរៀននៃកម្មវិធីថ្នាក់ទី ៣ ដែលខ្ញុំត្រូវបង្រៀននោះ ក៏ត្រូវធ្វើឡើងជាភាសាបរទេសដែរៗ ក្នុងការពន្យល់មេរៀន ដំបូងខ្ញុំយកភាសាបារាំងមកប្រើ ៗ និយាយឲ្យងាយស្តាប់ទៅទៀត គឺខ្ញុំនិយាយបារាំងក្នុងពេលពន្យល់សិស្ស ដោយបញ្ចូលភាសាជាតិម្តងៗ ៗ ពេលពន្យល់សិស្សនៅស្ងៀម ទំយកចិត្តទុកដាក់ស្តាប់ខ្ញុំ ; សិស្សមិនដែលឃើញលើកដៃក្រោកសួរខ្ញុំ ពីការឆ្ងល់ត្រង់ណាសោះ ... ៗ បើខ្ញុំហៅឲ្យមកសូត្រមេរៀនវិញ សិស្សសូត្រទៅរួចតាមមេរៀន ដែលមានតែបើសិនជាខ្ញុំសួរជាសំនួរគិតវិញ (question d'intelligence) សិស្សគ្មានចេះឆ្លើយម្នាក់សោះ ៗ ត្រង់ហ្នឹងហើយដែលបង្ហាញឲ្យខ្ញុំដឹងថា សិស្សខ្ញុំមិនយល់មេរៀនប្រវត្តិសាស្ត្រទេ ពិតមែនតែសិស្សទំទន្ទេញមេរៀន „បារាំង„ ចេះចាំមាត់យ៉ាងហ្នឹងក៏ដោយ ៗ

ឃើញដូចនេះ ខ្ញុំក៏បង្ខំចិត្តប្តូររបៀបបង្រៀនម្តងៗ គឺជាម្តងនេះ មេរៀនធ្វើភាសាបារាំងដដែល តែខ្ញុំពន្យល់ជាភាសាខ្មែរ ៗ ឃើញទេ! ម្តងនេះ សិស្សខ្ញុំចេះឆ្ងល់ សិស្សខ្ញុំហ៊ានសួរពីនេះពីនោះ, សិស្សខ្ញុំចេះឆ្លើយតបនឹងសំនួររបស់ខ្ញុំៗ ៗ សកម្មភាពថ្មីពីការពិសោធន៍លើកដំបូងនេះ បានបង្ហាញប្រាប់ខ្ញុំថា សិស្សយល់មេរៀនហើយ ៗ ដូចនេះ គឺតាមរបៀបនេះហើយ (មេរៀនជាភាសាបារាំងតែពន្យល់ជាភាសាខ្មែរ) ដែលខ្ញុំបានប្រើមករហូតដល់សព្វថ្ងៃនេះ ក្នុងការប្រកបរបរខ្ញុំ ៗ

## ២–គួរយកមកអនុវត្តដែរឬ?

ការពិសោធន៍ផ្ទាល់ខ្លួននេះ បានបង្ហាញនូវហេតុផលពីរយ៉ាង ។ មេរៀនជាភាសាបារាំងពន្យល់ទៀតក៏និយាយសុទ្ធតែបារាំងនោះ សិស្សមិនងាយយល់ផ្ដាសទេ តែបើមេរៀនជាភាសាបារាំង ហើយពន្យល់ដោយនិយាយភាសាខ្មែរនោះ ច្បាស់ជាសិស្សយល់គួរសម ។ លើសពីនេះទៅទៀត ការពិសោធន៍នេះបានបង្ហាញខ្ញុំនូវផ្លូវមួយទៀតដែលគួរតែលើកយកមកដោះស្រាយដូចខាងក្រោមនេះ ។

បើសិនជាយើងកាត់តែងមេរៀនប្រវត្តិសាស្ត្រជាភាសាខ្មែរតែម្ដងទៅវិញ ហើយពន្យល់ទៀតក៏ជាភាសាជាតិដែរនោះ តើមានទោសទាស់អ្វីត្រង់ណាទេ ? ធ្វើដូចនេះ តាមមតិផ្ទាល់របស់ខ្ញុំ មានតែសិស្សអាចយល់មេរៀនជាងពេលណាទាំងអស់ ។ ឯគ្រូវិញក៏គ្មានចេះធុញទ្រាន់ពីការដែលសិស្សមិនយល់ដែរ ហើយម្យ៉ាងទៀតអាចមានអំនួត (fierté) ក្នុងការបង្រៀនថែមទៀនផង ព្រោះតាមធម្មតា និយាយខ្មែរងាយជាងនិយាយបារាំងឆ្ងាយណាស់ ។

បើយើងនិយាយបានស្រួល បានច្បាស់លាស់កាលណា សិស្សយើងក៏ងាយចាប់សេចក្ដីបានកាលនោះ ។ តែបើយើងហើយ រវល់តែធ្វើថីបកប្រែគំនិតយើង រវល់តែនឹកពី „ករុបមិនករុប„ នោះពេលក៏ខាត អំនួតក៏គ្មាន ភាសាក៏មិនច្បាស់លាស់ ការពន្យល់ក៏ចង្អៀតចង្អល់ ហើយទាំងសិស្សទាំងគ្រូមុខតែនាំគ្នាពិបាកចិត្តខ្លាំងហើយ !

„មេរៀនជាភាសាជាតិ ពន្យល់ទៀតក៏ជាភាសាជាតិ„ ក៏មិនផុយអ្វីពីលក្ខណៈធម្មជាតិរបស់សិស្សដែរ ព្រោះសិស្សសុទ្ធតែជាខ្មែរស្រាប់ទៅហើយ ។ ម្យ៉ាងទៀត របៀបនេះក៏មិនទាស់អ្វីពិធីសាស្ត្រនៃប្រវត្តិសាស្ត្រដែរ, បើសិនជាគេយល់ថាប្រវត្តិសាស្ត្រមានភារៈ នឹងបង្ហាញនូវការទាក់ទងរវាងព្រឹត្តិការណ៍ទាំងឡាយដែលមានជាប់ទាក់ទាមនឹងសង្គមមនុស្សនេះឯង ។ យោងទៅលើគំនិតនេះ, បង្រៀនប្រវត្តិសាស្ត្រ គឺមិនមែនបង្រៀនអក្សរសាស្ត្រទេ, តែគឺបង្រៀនឲ្យសិស្សយល់នូវការវិវត្តន៍នៃសង្គមមនុស្ស និយាយដោយវែង ឬយល់មេរៀនប្រវត្តិសាស្ត្រតែប៉ុណ្ណោះ, និយាយដោយខ្លី ។ ដូចនេះ ឃើញថាចំពោះសិស្ស, ចំពោះគ្រូ, ចំពោះគរុកោសល្យប្រវត្តិសាស្ត្រ, ចំពោះជាតិ,... យកភាសាជាតិមកប្រើក្នុងប្រវត្តិសាស្ត្រមិនជាឧបសគ្គអ្វីសោះឡើយ ។

## ៣–តើដោះស្រាយរបៀបណា?

បើយល់ថាប្រវត្តិសាស្ត្រនៃកម្មវិធីសិក្សាជាតិត្រូវ

ធ្វើជាភាសាជាតិនោះ ប្រហែលមានមតិខ្លះគេជំទាស់ថាមិនទាន់ដោយការលេសថា «មានសៀវភៅសិក្សាឯណាជាភាសាជាតិ ដែលស្របទៅតាមកម្មវិធីបង្រៀននោះ ? អ្នកដែលនិយាយយ៉ាងហ្នឹងហាក់ដូចជាធ្វើមិនដឹងថាហេតុដែលជាឧបសគ្គនោះមិនមែនឋិតនៅត្រង់ថាខ្វះសៀវភៅសិក្សានោះឡើយតែផ្ទុយទៅវិញ គឺឋិតនៅត្រង់ដែលបេះទាញកម្មវិធីប្រវត្តិសាស្ត្រឲ្យមានលក្ខណៈជាតិពិតៗនោះវិញទេ ។ បានជានិយាយយ៉ាងនេះព្រោះដរាបណាតែយើងយកភាសាជាតិ មកអនុវត្តក្នុងកម្មវិធីប្រវត្តិសាស្ត្រ ច្បាស់ជាដរាបនោះសៀវភៅសិក្សាជាភាជាតិក៏លេចចេញឡើងយ៉ាងសន្ធឹក ។ តើលេចចេញពីណាមក ? ដើម្បីឆ្លើយតបទឹងសំនួរនេះមានតែមធ្យោបាយម្យ៉ាង គឺថាត្រូវតែបង្កើតឲ្យមានគណៈកម្មការនិពន្ធសៀវភៅសិក្សាប្រវត្តិសាស្ត្រឲ្យស្របទៅតាមកម្មវិធីជាតិទៀតផង ។ ក្នុងការនិពន្ធគណៈកម្មការមានការៈអំពាវនាវអ្នកប្រវត្តិសាស្ត្រ, បបួលសាស្ត្រាចារ្យបង្រៀនប្រវត្តិសាស្ត្រ អញ្ជើញជនទាំងឡាយណា ដែលមានសមានចិត្តចំពោះប្រវត្តិសាស្ត្រ ... ឲ្យចូលមករួបរួមគ្នា កសាងកម្មវិធីប្រវត្តិសាស្ត្រឲ្យមានលក្ខណៈជាតិ តាមការដែលគួរធ្វើទៅបាន (ឧបមាដូចជាក្នុងវិស្សមកាល) ។

និយាយរួមទៅ ខ្ញុំគាប់កត់សំគាល់ថា បើគេផ្អែកទៅលើគំនិត ដែលថាបង្រៀនប្រវត្តិសាស្ត្រមិនមែនបង្រៀនអក្សរសាស្ត្រទេនោះ កម្មវិធីជាតិខាងប្រវត្តិសាស្ត្រ ក៏មិនទាក់ទងអ្វីដល់ភាសាបរទេសដែរ ។ ដើម្បីឲ្យបានសៀវភៅសិក្សាស្របទៅតាមកម្មវិធីប្រវត្តិសាស្ត្រគួរតែឆ្លៀតតាំងគណៈកម្មការនិពន្ធសៀវភៅនេះឡើង ។ បើធ្វើបានយ៉ាងនេះមែន តាមមតិផ្ទាល់របស់ខ្ញុំ ឃើញថា អាចដោះស្រាយបាននូវឧបសគ្គទាំងអស់ដែលទាក់ទងដល់សិស្ស (ពីដើមដែលមិនយល់មេរៀន)ហើយទឹងដល់គ្រូដែលតែងតែត្អូញត្អែរ ពីការខ្វះខាតឯកសារសំរាប់បង្រៀន ។

សូមសង្ឃឹមថាទឹងមានការតិះដៀលឬមតិថ្មីៗពីអស់មិត្ត ដើម្បីជួយបំភ្លឺ !

តាំង-ស៊ុ-យ៉ុង
សាស្ត្រាចារ្យនៅអនុវិទ្យាល័យព្រះសោមា
ព្រៃល្វា-តាកែវ



# ជំងឺ„ប្រឡងនិយម„

ជំងឺប្រឡងនិយមនេះ បារាំងហៅថា bachotage ។ ជំងឺនេះជាជំងឺសាលារៀនសុទ្ធសាធ; វាធ្វើឲ្យយល់ ថារៀនដើម្បីប្រឡងជាប់ជាមុនសិន ត្រង់ឯរៀន ដើម្បីហាក់ពត់ប្រាជ្ញាស្មារតីឲ្យបែកល្អូតលាស់ គេមិនសូវគិតទេ ។ គេមិនបណ្ដុះខួរក្បាល គេញាត់ឲ្យណែនខួរក្បាលទៅវិញ ។

សិស្សដែលឈឺជំងឺប្រឡងនិយម គឺសិស្សដែល "រៀនចាក់" ដែលយកការទៅប្រឡងដូចជាការចាក់អាប៉ោង ។ ឲ្យតែប្រធានចេញចំ គេហោរគិល ហើយឆ្លុចក្អួកសរសេរទាំងសន្ទុក ។ ដូចបេះបិតក្នុងសៀវភៅ តាំងពីដើមដល់ចប់ ។

មេរៀនណាដែល „ចេញ„ រួចឆ្នាំមុនៗ ហើយគេមិនបាច់រៀនទៀតទេ ។ លុះ „អាប៉ោងចេញឈរ„, ដូចវិញ្ញាសាវិទ្យាសាស្ត្រធម្មជាតិ កាលប្រឡងសញ្ញាប័ត្រ(ឌីប្លូម)ឆ្នាំ៦១ គេក៏បញ្ច្រងប៉ាកកា ក្រឡាប់ក្អែកសំឡឹងពីតានៗ ពេលរៀនមេរៀនគេគ្មានអានសៀវភៅក្រាស់ៗដើម្បីពិចារណា ស្រាវជ្រាវទេ គេទិញតែសៀវភៅសង្ខេប (aide - mémoire) យកមកទន្ទេញឲ្យចាំមាត់ ។ ពីដើមឆ្នាំសិក្សា គេមិនខំរៀនបណ្ដើរៗទេ លុះដល់១ខែមុនប្រឡង បានគេខំ អត់ងងុយទាំងយប់ទាំងថ្ងៃ ផឹកកាហ្វេប្ដូរលេបថ្នាំ ម៉ាក់ស៊ីតុន កុំឲ្យងងុយដេក ដកបដល់ឈឺខ្លួន ស្មារតីទៅជាគ្រូចគ្រាំងអស់ ។ ពេលប្រឡង ខាងសួរ គេសួរដំណឹងពីមេប្រយោគតើ គាត់កាចឬស្លូត តើគាត់សួរអ្វីខ្លះ? ហើយគេកណ្ដៀតសៀវភៅទាំងគរ បើកមើលមួយ ទុកមួយ ដើរចុះដើរឡើង មិនដាច់ចិត្តប្រថុយចូលឲ្យគេសួរសោះ ។

គំនិតគេនៅរកវីតែនឹងរកស្នៀត ក្រឡិចក្រឡុចយ៉ាងម៉េចឲ្យតែបានជាប់ ។ តើខួរក្បាលបែបនេះ ទោះជាមានសញ្ញាប័ត្រមួយសន្ទឹកក៏ដោយ ប្រើការធ្វើអ្វីកើតដែរឬទេ? បើគ្រាន់តែប្រឡងហើយ ក្អួចចូលសៀវភៅវិញអស់ ហើយពុំមានការត្រិះរិះឈ្វេងយល់អ្វីសោះ?

សាស្ត្រាចារ្យដែល ឈឺជំងឺប្រឡងនិយមគឺសាស្ត្រាចារ្យដែលភ័យព្រឺកល្វាចខ្លាចតែមិនចប់កម្មវិធី ។ គេគិតឲ្យតែបំនួនភាគរយនៃសិស្សគេដែលប្រឡងជាប់ ផ្ដាច់ហួសថ្នាក់ឯទៀតឬ សាលាឯទៀត ។ អនុវិទ្យាល័យមួយនៅខេត្ត កាលដែលបារាំងនៅធ្វើជាចាងហ្វាងនៅឡើយ មានកូនសិស្សមិនសូវពូកែគេឲ្យមក ប្រឡងឌីប្លូមក្នុងឋានៈជាបេក្ខជនសេរី មិនឲ្យចេញជាបេក្ខជនសាលានោះទេ ដើម្បីកុំឲ្យខូច "ភាគរយ„ សាលាគេ ។ សាស្ត្រាចារ្យដែលលុះក្នុងជំងឺប្រឡងនិយម ច្រើនប្រាប់សិស្សខ្លួនថា „កន្លែងនេះ មេរៀននេះសំខាន់

ទៅប្រឡងច្រើនចេញញឹកជាងគេ ៗ សិស្សក៏ម្នាគូសទំព័រចំណាំ ហើយរៀនតែមេរៀននោះ ៗ គន់គាស្មើប្រធានប្រឡង សាស្ត្រាចារ្យនេះបានតែទៅលើចំណុចណា ដែលសិស្សអាចចាំមាត់ស្មូត្រមាត់ទទេបាន ហើយស្ទើរសំរាប់តែសិស្សខ្លួន ចំកន្ទុងដែលខ្លួនសំគាល់ថាងាយគេ មិនគិតដល់សិស្សសាសាឯទៀត គេធ្វើកើតឬមិនកើត មិនគិតរើសប្រធានណា ដែលនាំឲ្យសិស្សរិះគិតខ្លះផងឡើយ ៗ សាស្ត្រាចារ្យបែបនេះសិស្ស“ស្គាល់ចិត្ត,, ស្រេច ពេលប្រឡងផងមាសម្តង ១ សិស្ស“ចាក់ភ្នាក់បាន,, គាត់ពុំសូវខុសទេ ៗ រីឯរបៀបទំនុំខ្ទឹមសារដែលគាត់បង្រៀននៅតែដដែល ១ រាល់តែឆ្នាំ គ្មានចូលអ្វីថ្មែកសោះ មេរៀនគាត់ឲ្យយកទៅចម្លងក៏ដែន ១ អនែក ហើយគាត់ទាមទារឲ្យចាំដូចគាត់កុំឲ្យខុសមួយម៉ាត់ !

ចូលយើងកំចាត់ដំនើរប្រឡងនិយមអប្រិយ៍នេះឲ្យផុតពីមណ្ឌលសាលាយើង ៗ

## វចនានុក្រមនៃសំណើច

គ្រូ (ចង្អុលទៅ 0 ដែលសរសេរនៅក្ដារខៀនបែតង់ ហើយសួរ):

— នេះជាអ្វី? (សិស្សទាំងឡាយលើកដៃប្រវាស ហើយក្រោកឆ្លើយ):

ប័ន្ឌ— បាទ, នេះជាចិញ្ចៀនប្រុស ៗ

គារ— បើតាមខ្ញុំបាទ, នេះជាសូន្យ ៗ

ពុធ— ខ្ញុំបាទថា 0 នេះជាអក្សរទី១៥នៃព្យញ្ជនៈបារាំង ៗ

មាស— នេះជា Q ដែលទើបនឹងបាត់កន្ទុយឬជា 9 បាក់ជើងឬជា 6 បាក់ដៃ ៗ

សុខ— នេះគឺជាលោកខែ ពេញបូណ៌មី ៗ

គ្រូ— ឈប់, ឈប់! ហ៊ើយ, ស្អីចេះ សុទ្ធតែលេខ សុទ្ធតែអក្សរ សុទ្ធតែលោកខែ. សុទ្ធតែ...ខុសទាំងអស់ ៗ អ្នកពាល់គ្នាឆ្លើយនេះ រាំសមហើយ តែមុខឆ្លើយ. យើងត្រូវគិត...ឥឡូវនេះយើងរៀនពីអ្វី ?

សៅ— នេះជាវង់មូល !

គ្រូ— បាទ, ល្អ !

ប័ន្ឌ— បើចង់រៀនពីវង់មូល ម៉េចក៏គូរតូចម្ល៉េះ! លោកគ្រូ ?

# ម៉ោងគឺម៉ោង

ដោយ ច្រេង យា

និស្សិតសាស្ត្រាចារ្យ ឆ្នាំ ទី ២

ព្រឹកនេះជាព្រឹកថ្ងៃច័ន្ទ ។ ក្រោយពីការគោរពទង់ជាតិ សិស្សត្រូវចូលរៀនគ្រប់ថ្នាក់; មិត្តខ្ញុំនិងខ្ញុំមិនទាន់ចូលថ្នាក់ទេ ព្រោះលោកគ្រូពុំទាន់អញ្ជើញមកដល់ ។ ខ្លះពោលថាគ្រូយើងឈឺពោះ, ខ្លះថាគាត់ពុំបានមកព្រោះប្រពន្ធឆ្លងទន្លេ; ខ្លះថា គាត់ទើបនឹងក្រោកពីដំណេក ។ មិត្តខ្ញុំខ្លះឈរនៅមាត់ទ្វារអើតតាមបង្អួចចាំមើលផ្លូវគ្រូ, ខ្លះដើរដែកគាក់ក្នុងថ្នាក់ ។

បើគេឃើញពីចំងាយ គេនឹងដឹងថាគ្រូថ្នាក់ខ្ញុំពុំទាន់មកដល់; គេឃើញមិត្តខ្ញុំឈរចាំមើលផ្លូវគ្រូ ហាក់ដូចជាកូនឃ្លានចំណីចាំមើលផ្លូវម្តាយមកពីផ្សារ ឬពុំនោះសោត ហាក់ដូចជាសិស្សអស់នោះស្រេកឃ្លានចំណេះវិជ្ជាយ៉ាងខ្លាំង ហើយនឹកច្រណែនដោយឃើញសិស្សឯទៀតកំពុងជញ្ជក់យកវិជ្ជាដោយមានទុជារសដែលគ្រូគេកំពុងខ្ជាក់ចេញពីមាត់មក ។

បើសិនជាគេទៅចូលក្នុងចំណោមមិត្តខ្ញុំវិញនោះ គេនឹងឮពាក្យគ្រប់បែបយ៉ាង ។ សិស្ស ឈរនៅមាត់ទ្វារឬអើតតាមបង្អួចកំពុងអ៊ុតគ្រូគេ ដូចអ៊ុតអាប៉ោងក្នុងចាន; យូរៗគេឮសិស្សនោះពោលថា :

— "គាត់អញ្ជើញមកហើយ" រួចដើរយ៉ាងលឿនទៅកន្លែងខ្លួន ។

ដើម្បីបញ្ជាក់ថា មកឬមិនមក សិស្សម្នាក់ឆ្លើយថា :

— ចេះតែការអញ្ចឹងបានជាលោកគ្រូគាចអេះៗ

ខ្លះក៏ស្ទុះទៅអើតក្បាលល្ងោកតាមបង្អួចដើម្បីអ៊ុតមើលដែរ ។ ខ្លះទៀតមើលនាឡិកាដៃហើយស្រែកថា :

— តែប្រាំមីនុតទៀតទេ, បើពុំឃើញមកបានដៃគ្នាហើយវើយ ! ម្នាក់ទៀតថា :

— ប្រាំមីនុតទៀតស៊ីអន្សមអាំងហើយ !

ខ្លះទៀតមានគំនិតបបួលគ្នា ចេញពីថ្នាក់ឲ្យអស់ ។ អ្នកដែលចង់រៀនក៏នៅអង្គុយរៀនឬមើលសៀវភៅស្ងៀមៗទៅ ។ ដើម្បីកាត់សាញក្នុងរឿងនេះម្នាក់ឆ្លើយថា :

— គាត់មិនមកទេ, ដប់មីនុតទៅហើយព្រោះគាត់នឹកខ្មាសយើងដែរ ។ ម្នាក់ទៀត :

— ខ្មាសយើងផង ! មកដល់កិនកំពិតមុខឥឡូវមិនគិតទេ . . .

សិស្សដែលឈរអ៊ើតនៅមាត់ទ្វារឬ បង្អួច នឹកភ័យអរៗ –ភ័យព្រោះក្រែងលោកគ្រូមក, តែអរព្រោះនឹកថាគាត់មិនមក ។

សិស្សដែលបានកំណត់ពេលមុនគេ ក៏ដើរចេញប្រុងទឹងមិននៅរៀន, សិស្សឯទៀតៗក៏ចេញមកឈរមើលខាងក្រៅ ។ ពេលនោះស្រាប់តែឃើញលោកគ្រូកាន់កាតាបដើរយ៉ាងលឿនតំរង់មក សិស្សក៏នាំគ្នារត់ប្រញាប់ចូលអង្គុយក្នុងថ្នាក់ ; ម្នាក់ដែលក្តៅចិត្តស្រែកឡើងថា

–នែ, គ្នាយើង ចាំសួររក ‹‹ប័ណ្ណចូល ›› (billet d'entrée)គាត់ម្តង ។ ម្នាក់ឆ្លើយតបភ្លាម:

– ឯងទឹងហើយ ចាំចារគាត់ទៅ!

លោកគ្រូចូលដល់ក្នុងថ្នាក់ ដោយមានទឹកមុខពុំស្រួល, កូនសិស្សអង្គុយស្ងាត់ដូចកណ្តុរឃើញឆ្មា ។ កាលបើអង្គុយរួចមិនបានឯខ្លាក់វិជ្ជាឲ្យ គ្រូឡប់ថាខ្លាក់គាកស្លាមកវិញ ;

– យ៉ាងមេចបាននាំគ្នាចេញទៅឈរខាងក្រៅដូចនេះ, ដូចជាគ្មានរបៀបរបបសោះ ដូចនេះ; គ្រាន់តែអង្គុយចាំបន្តិចមិនបាន ធ្វើហ្នឹងជ្រុលពេកហើយ ។

កំពុងស្តីឲ្យប៉ាច់ៗ សិស្សខាងមុខអង្គុយស្ងៀម សិស្សក្រោយៗខ្សៀតពេលនិយាយគ្នាតិចៗ ខ្លះថា ·

–ទឹងប្រពន្ធមិនដាស់ឯផ្ទះ មកកនកូនសិស្សឯណេះវិញ ។ ម្នាក់ឆ្លើយភ្លាម:

–បានទឹងទឹងប្រពន្ធគ្រាន់បើហើយ ។ ម្នាក់សួរវិញ:

–យ៉ាងមេច ? -ប្រពន្ធដេរឯផ្ទះរកឆ្លើយមិនរួចទេទើបដកដៃរត់មកនេះទេតើ· ។

–ឯងចេះតែបន្ទាប់គាត់តែម្តងហើយ ថាហើយក៏លួចសើចទៅ ។ ម្នាក់ទៀត លាន់មាត់ថា– ហ៊ុះឲ្យអង្គុយក្នុងថ្នាក់ផង កំពុងតែចង់ចេញស៊ីអន្សមតាំងឲ្យអង្គុយស្ងៀមម៉េចកើត ។

ខ្លះទៀតថា–មកតុំទាន់ម៉ោងហើយ ធ្វើជាទឹងទៀតខ្លះ ។ ទៀតពោលថា :

–តែថាម៉ោងប៉ុន្មាន រាប៉ុណ្ណឹងហើយ; ប្រាំនាទីមុនម៉ោងឬក្រោយម៉ោងរាលែងម៉ោងទៅហើយ ។ ម្នាក់ទៀតសួរថា:

–ម៉េចក៏ឯងចឹង ? –ពីព្រោះរា... តែឯងចឹង ។





# នក្ខត្តសាស្ត្រ និង [illegible]

## ធម្មជាតិនៃផ្កាយ

ក្នុងពេលយប់ស្ងាត់ មេឃស្រឡះ កាលណាយើងក្រឡេកមើលឡើងអាកាសវេហាស៍នូវផ្កាយមីរដេរដាសយើងរមែងរំភើបចិត្តជ្រះថ្លាសួរថា «ចំណុចភ្លឺៗទាំងនោះជាពិតព អ្វីហ្ន៎? នៅចំងាយណាទៅ? ទីនោះមានអ្វីខ្លះ? ធ្វើម្ដេចនឹងទៅដល់?» ផ្កាយទាំងនោះ ថ្វីបើនៅឆ្ងាយសែនឆ្ងាយក៏មិនទាន់ផុតនិស្ស័យ មនុស្សស្គាល់នឹងដឹងបាននៅឡើយដែរ ។

### កុំប្រឡំផ្កាយនឹងបរិវារព្រះអាទិត្យ

ជនសាមញ្ញយល់ថា នៅលើមេឃ ក្រៅពីព្រះអាទិត្យនឹងព្រះចន្ទដែលមានមាឌធំៗ ហើយដែលចោលពន្លឺច្រើនមកលើដី ចំណុចភ្លឺៗឯទៀតសុទ្ធតែជាផ្កាយទាំងអស់ ។ ការពិតមិនដូចនោះទេ ដូចយ៉ាងផ្កាយព្រះសុក្រ (Vénus) ដែលយើងតែងហៅថា «ផ្កាយព្រឹក ឬផ្កាយចោរ» ព្រោះផ្កាយនេះរះ៣ ឬ ៤ម៉ោងមុនព្រះអាទិត្យរះ ។ ផ្កាយនេះមិនមែនជាផ្កាយពិតប្រាកដទេ វាគ្រាន់តែជាបរិវារព្រះអាទិត្យវិលជុំវិញព្រះអាទិត្យហើយទទួលពន្លឺពីព្រះអាទិត្យតែប៉ុណ្ណោះ មិនមែនភ្លឺខ្លួនឯងទេ ។

រីឯផ្កាយព្រះអង្គារ (Mars) ព្រះពុធ (Mercure) ព្រះព្រហស្បតិ៍ (Jupiter) ព្រះសៅរ៍ (Saturne) ក៏យ៉ាងដូចនោះដែរ ។ ដោយបរិវារព្រះអាទិត្យទាំងនេះនៅឆ្ងាយពេក យើងក៏ឃើញតូចដូចផ្កាយ ហើយច្រឡំថាផ្កាយទៅ ។ ក្នុងចំណោមផ្កាយនានា យើងឃើញបរិវារទាំងនេះ ផ្លាស់កន្លែងជានិច្ច ជួនកាលបាត់ពប់ខែ ព្រោះវាធ្វើដំណើរជុំវិញព្រះអាទិត្យ ។

ឯផ្កាយពិតៗនោះ ភ្លឺដោយខ្លួនឯង មិនទទួលពន្លឺពីគេទេ ។ ផ្កាយទាំងនេះក៏មានដំណើរផ្លាស់ទីកន្លែងដែរ ប៉ុន្តែដោយចំងាយឆ្ងាយពេក យើងមើលទៅឃើញផ្កាយនៅតែកន្លែងដដែល ៗ រាត្រីណា ក៏ដូចរាត្រីណា ចំងាយពីផ្កាយមួយទៅផ្កាយមួយ ហាក់ដូចជានៅតែដដែលៗ ។ គឺយ៉ាង

ដូចនេះហើយ បានជាយើងអាចគូសបន្ទាត់ភ្ជាប់ ផ្កាយមួយទៅផ្កាយមួយ បានជារូបផ្សេងៗហៅថា ផ្កាយក្រពើ ផ្កាយសេះ ផ្កាយយាមនង្គ័ល ផ្កាយកូនមាន់ ។ល។ ក្នុងមួយពាន់ មួយម៉ឺនឆ្នាំទៅមុខ រូបទាំងនេះនឹងប្រែប្រួលមិនខាន ពីព្រោះផ្កាយទាំងអស់សុទ្ធតែ "ដើរ" ។

## ផ្កាយនានាសុទ្ធតែជាព្រះអាទិត្យ ដែលនៅឆ្ងាយៗ

ផ្កាយនិមួយៗជាដុំភ្លើងភ្លឺដូចព្រះអាទិត្យ អណ្ដែតនៅក្នុងចក្រវាឡ ។ កាលណាគេមើលផ្ទៃមេឃក្នុងកែវយិតធំៗ គេឃើញផ្កាយច្រើនលើសយើងឃើញក្នុងទទេឆ្ងាយណាស់ ប៉ុន្តែកែវយិតពង្រីកមាឌផ្កាយពុំបានធំទេ ។ គេប្រមាណចំនួនផ្កាយក្នុងសាកលចក្រវាឡយើងនេះ ឃើញជាង ១៥០ កោដិ ។

ផ្កាយនៅឆ្ងាយៗពីគ្នា រហូសយើងធម្មតាពុំអាចវាស់ចំងាយពីផ្កាយមួយទៅផ្កាយមួយ បានទេ ។ គេវាស់ចំងាយនេះជាឆ្នាំ-ពន្លឺ (année - lumière) ។ ដែលហៅថាប្រវែងមួយឆ្នាំពន្លឺ គឺប្រវែងដែលពន្លឺរត់បានក្នុងមួយឆ្នាំ ដោយល្បឿន ៣ សែនគីឡូម៉ែត្រក្នុងមួយវិនាទី ។ ផ្កាយដែលនៅជិតព្រះអាទិត្យយើងជាងគេនៅចំងាយ ៤,៣ ឆ្នាំពន្លឺ គឺផ្កាយឈ្មោះ "សង់តូរ" ( Centaure ) ។ បានសេចក្ដីថាពន្លឺដែលបានមកដល់ភ្នែកយើងក្នុងពេលនេះ បានចេញដំណើរពីផ្កាយនោះតាំងពី ៤ ឆ្នាំ ៤ ខែកន្លងទៅម្ល៉េះ ! ផ្កាយនានា សុទ្ធតែនៅចំងាយច្រើនសិបច្រើនរយឆ្នាំពន្លឺពីព្រះអាទិត្យ ។

ផ្កាយមានមាឌខុសៗគ្នា ខ្លះក៏ធំជាងព្រះអាទិត្យ ខ្លះក៏តូចជាងព្រះអាទិត្យ ។ មកដល់ឥឡូវនេះ ផ្កាយដែលគេឃើញធំជាងគេបង្អស់ គឺផ្កាយ "សារថី" (Cocher) ។ ផ្កាយនេះមានទំហំធំជាងព្រះអាទិត្យ ៨ កោដិដង ។ ផ្កាយទាំងឡាយច្រើននៅផ្គុំគ្នា ២-៣-៤ ដែលយើងមើលពីចំងាយទៅដោយភ្នែកទទេ ស្មានតែផ្កាយតែមួយ ។ រីឯផ្កាយដែលនៅឯកោ ដូចព្រះអាទិត្យយើងមិនសូវមានទេ ។

ផ្កាយទាំងឡាយមានពន្លឺខ្លាំងខ្សោយ ខុសគ្នា ហើយមានពណ៌ក៏ខុសគ្នាទៀត ។ ផ្កាយដែលមានពន្លឺខ្លាំងគឺផ្កាយក្ដៅ មានសីតុណ្ហភាពច្រើនសិបលានអង្សា ។ ឯផ្កាយដែលមានពន្លឺខ្សោយទុកជាផ្កាយត្រជាក់ មានសីតុណ្ហភាពបីបួនលានអង្សា ។ វិធីដែលយកពន្លឺពណ៌នៃផ្កាយ មកធ្វើភាគបែងមើល

នាំឲ្យគេដឹងថា នៅក្នុងផ្កាយនីមួយៗមានធាតុអ្វីខ្លះៗ មានផ្កាយមួយពួកប្រែប្រួលពន្លឺជានិច្ច ម្ដងលេចភ្លឺសន្ធោ ម្ដងអ៊ុរទៅវិញ ៗ ផ្កាយខ្លះភ្លឺសន្ធោ ៥ ម៉ោងម្ដង ខ្លះ៣ថ្ងៃម្ដង ខ្លះ១ខែម្ដង ៗ បាតុភូតភ្លឺភ្លឹបភ្លែតម្ដងៗ របស់ផ្កាយនេះ អស្ចារ្យណាស់ វិទ្យាសាស្ត្រពុំទាន់រកឫសហេតុឃើញនៅឡើយទេៗ ពួកផ្កាយដែលគេហៅ „ណូវ៉ាអេ" (Novae) និង „ស៊ុពែរ-ណូវ៉ាអេ„ (Super-Novae) ជាផ្កាយអ៊ុរ មើលស្ទើរមិនឃើញក្នុងពេលធម្មតា ស្រាប់តែដល់កាលមួយភ្លឺសន្ធោជាងដើមរាប់សែនដង ភ្លឺលប់អស់ផ្កាយឯទៀតលើមេឃហើយលុះពីរបីថ្ងៃក្រោយមកក៏រលត់ទៅវិញ រាប់សតវត្សទើបភ្លឺសន្ធោម្ដងទៀត ៗ ពេលផ្កាយ Novae ភ្លឺម្ដងៗ មនុស្សផ្អើលគិតភ័យរកហោរ គន់គូរខ្លាចមានវិបរិតនៅលើផែនដី ដោយមានជំនឿផ្សេងៗ។

## ថាមពលនៅក្នុងផ្កាយនិងចេញពីផ្កាយ

បើចង់ដឹងហេតុភេទ ដែលកើតក្នុងផ្កាយ យើងពិនិត្យតែផ្កាយដែលនៅជិតយើងជាងគេ គឺព្រះអាទិត្យ ៗ ផ្កាយនេះជាដុំភ្លើងមួយដែលនៅក្នុងនោះ មានសីតុណ្ហភាពក្ដៅដល់ ២០ លានហ៊ង្សា! ក្នុងមួយវិនាទីផ្កាយនេះជះថាមពលជាកំដៅមកលើផែនដី និងទៅគ្រប់ទិសនៃចក្រវាឡច្រើនឥតគណនា ៗ តើថាមពលនេះ ព្រះអាទិត្យបានមកពីណា ? បើថាមពលនេះកើតដោយការឆេះដូចជាយើងដុតធ្យូងនោះ កំដៅដែលបានមកពុំមែនច្រើនឥតគណនាដូចយើងឃើញទេ ៗ ហើយបើសិនជាព្រះអាទិត្យ ធ្វើពីធ្យូងមែន ម៉្លេះឆេះសុះអស់ក្នុងរយៈមិនដល់មួយម៉ឺនឆ្នាំទេ មិនមែនស្ថិតនៅបានជាច្រើនកោដិឆ្នាំ មកដល់សព្វថ្ងៃនេះទេ ៗ

ថាមពលដែលកើតក្នុងព្រះអាទិត្យ គឺកើតអំពីប្រតិកម្មមួយបែបនេះហៅថា ប្រតិកម្មបណ្ដូល ( réaction nucléaire )ៗក្នុងប្រតិកម្មបែបនេះបើតាមទ្រឹស្ដីអ្នកប្រាជ្ញឈ្មោះ អាញស្តាញ (Einstein) មានធាតុរលាយបាត់រូបក្លាយទៅជាកំដៅនិងជាកាំរស្មីផ្សេង ៗ អ្នកប្រាជ្ញឈ្មោះ ប៊ីត្ត ( Bethe ) និងឈ្មោះ វ៉ាយសាក់គែរ ( Veisacker ) បានបញ្ជាក់ថា នៅក្នុងប្រតិកម្មបណ្ដូលដែលកើតក្នុងព្រះអាទិត្យនោះ មានបណ្ដូលអ៊ីដ្រូសែន ៤គ្រាប់ចូលគ្នា ទៅជាបណ្ដូលអេលីយ៉ូម១គ្រាប់ ដោយមានបាត់ទំងន់ ៗការបាត់ទំងន់នេះបណ្ដាលឲ្យកើតជាថាមពលខ្លាំងមហិមា ៗ គេធ្វើលេខឃើញថា ក្នុងមួយវិនាទី ព្រះអាទិត្យត្រូវរំលាយធាតុរបស់ខ្លួនអស់ ៤ លានតោន ដើម្បីផ្សាយថាមពលទៅក្នុងចក្រវាឡដូចយើងឃើញសព្វថ្ងៃៗ

គ្រាប់បែកបរមាណូ នឹងគ្រាប់បែកអ៊ីដ្រូហ្សែន ដែលមនុស្សធ្វើឲ្យផ្ទុះ គ្រាន់តែជាការចម្លងយ៉ាងតូចតាមគំរូប្រតិកម្ម ដែលមាននៅក្នុងព្រះអាទិត្យ នឹងក្នុងផ្កាយ ។

មានការឆ្ងល់ សួរថា បើអ៊ីដ្រូហ្សែននៅក្នុងព្រះអាទិត្យចេះតែក្លាយទៅជាអេលីយ៉ូម រាប់លានតោនរាល់តែវិនាទីយ៉ាងនេះ ថ្ងៃណាមួយនឹងអស់អ៊ីដ្រូហ្សែនពីព្រះអាទិត្យជាមិនខាន តើពេលនោះព្រះអាទិត្យរលត់ឬអ្វី ? ក្នុងពេលនោះ នឹងអស់ប្រតិកម្មបណ្ដាល នៅសល់តែផេះអេលីយ៉ូមព្រះអាទិត្យនឹងរលត់ ។ ប៉ុន្តែ បើតាមយើងស្គាល់ទំងន់ព្រះអាទិត្យ ទំរាំតែអស់ធាតុអ៊ីដ្រូហ្សែននោះនៅសល់ពេលច្រើនកោដិឆ្នាំទៅមុខទៀត ។ ដូចនេះសូមមិត្តអ្នកអានទាំងឡាយ កុំអាល់ភ័យ !


–បណ្ណាគារ ប៊ុត នាង, លេខ ១៧៦ វិថីខេមរភូមិន្ទ, ភ្នំពេញ

–បណ្ណាគារ ហុង យូ, លេខ ៤ វិថីចន្ទុពជា, ភ្នំពេញ នឹង

–បណ្ណាគារ ដួង ដួណារី លេខ ២២២ វិថីខេមរភូមិន្ទ, ភ្នំពេញ

មានសេចក្ដីរីករាយនឹងចុះថ្លៃ១០% ដល់បណ្ដាមិត្ត

**ដំណឹងអនុគ្រោះ**

សាស្ត្រាចារ្យយើង ដែលទៅទិញសៀវភៅសិក្សា នៅបណ្ណាគារទាំងនេះ ហើយដែលបានបង្ហាញប័ណ្ណសមាជិកសមាគមយើងផង ។

ម្យ៉ាងទៀត បើមិត្តត្រូវការបញ្ជាទិញសៀវភៅអ្វី តិចឬច្រើននៅបារាំង មិត្តក៏អាចនឹងទិញតាមរយៈបណ្ណាគារ ហុង យូរ បានដែរ ។

# ទស្សនា ភាពយន្ត

រឿង
"ក្បួន
ជីវិត"
ផលិតកម្ម
របស់សមាគម
"កងបក្រភាពយន្ត"

បើតាមមតិយើង ហ្វីលនេះបានចូលទៅក្នុងចំណោមហ្វីលខ្មែរទាំងឡាយ ដែលយើងចាត់ទុកថាល្អ សមរម្យ ជួយកសាងមនុស្ស ហើយជួយរួមចំណែកលំអសង្គមខ្មែរ ដែលយើងរាល់គ្នាកំពុងរស់នៅសព្វថ្ងៃនេះ ។

ដើម្បីនឹងឲ្យមិត្តអ្នកអាន ពិសេសអស់មិត្តនៅខេត្រដែលមិនទាន់បានឬមិនបានទស្សនារឿងនេះ **ងា**យយល់មតិរបស់យើង យើងដូចជាចេះតែចង់ចុះដំណើររឿងដោយសង្ខេប នៅខាងក្រោមនេះ ។

យាយចាស់មានកូនប្រុសបីនាក់: សារិត, សារិននិងសារុំ ។ សារិត ជានិស្សិតមហាវិទ្យាល័យច្បាប់ , សារិន ជាអ្នកបើកបររថយន្តឈ្នួល ហើយសារុំកម្មករ ។ ថ្ងៃមួយ សារិន មានទុក្ខជាទំងន់ ព្រោះរថយន្តគេបានបុកទង្គិចស្ត្រីម្នាក់ឈ្មោះមាលា ។ នៅឱកាសដែលសារិនទៅសួរសុខទុក្ខ ហើយសូមទោសនាង នៅមន្ទីរពេទ្យ នាងមាលាបានរៀបរាប់រឿងរ៉ាវរបស់នាងថា "នាងជាបុត្រីលោកសេដ្ឋីផលាសម្បត្តិ តែលោកសេដ្ឋីគ្មានរាប់រកទទួលស្គាល់ម្ដាយនាងនិងខ្លួននាងសោះ ព្រោះលោកមានប្រពន្ធថ្មី ហើយមានទាំងកូនស្រីម្នាក់ទៀតផងឈ្មោះសុរតី ។ ក្រោយដែលជីដូននាងនិងម្ដាយនាងបានធ្វើមរណៈកិច្ចទៅ នាងមាលាក៏សោតទៅតាមការផ្សងព្រេង ធ្លាក់ខ្លួន ជាក្មេងសុំទាន រួចជាអ្នកស៊ីឈ្នួលនៅផ្ទះឪពុកនាងរួច ត្រូវភរិយាសេដ្ឋីប្រច័ណ្ឌ ត្រូវកូនគេប្រទេណន គេសង្កត់សង្កិន ក៏លួចរត់ចេញទៅ ស្រាប់តែត្រូវរថយន្តសារិនបុកទង្គិចមានរបួសដូច្នេះ" ។

រឿងរ៉ាវទាំងនេះ បានធ្វើឲ្យសារិននិងមាលាដឹងខ្លួនថាគេជាមិត្តចាស់តាំងពីក្នុងកុមារភាព ដែលគេនៅជាក្មេងសុំទានទាំងពីរនាក់ម៉្លេះ ។ សារិ

សូមទទួលនាងមាលាទៅ នៅផ្ទះខ្លួនហើយមិនយូរប៉ុន្មាន, អ្នកទាំងពីរក៏ចងចិត្តប្រតិព័ទ្ធនឹងគ្នា ។ តែដោយសារិតយោរយៅសង្កត់សង្កិនខ្លួនពេក សារិ ក៏ដាច់ចិត្តធ្វើពលិកម្មលើកនាងទៅឲ្យបងប្រុសខ្លួនវិញ ។ សារិតជាមនុស្សនេរគុណ វង្វេងក្នុងបុណ្យស័ក្តិនឹងសម្បត្តិទ្រព្យ បានរត់ចោលនាងមាលាជាប្រពន្ធ ដើម្បីទៅទាក់ទងនាងសុរិតីជាកូនប្រពន្ធក្រោយលោកសេដ្ឋីផលាសម្បត្តិវិញ ។ ទទួលពេលនោះយាយចាន់ជាម្តាយ បានធ្លាក់ខ្លួនឈឺ ឯសារុំក៏ត្រូវភ្នាក់ងារប៉ូលីសចាប់ខ្លួន ព្រោះគេបានបង្ខំចិត្តប្រព្រឹត្តអំពើចោរកម្ម ដើម្បីរកលុយទិញថ្នាំព្យាបាលម្តាយ ។ នៅទីបំផុត យាយចាន់បានទទួលអនិច្ចកម្ម ។ លុះឃើញម្តាយដាច់ខ្យល់ស្លាប់ដោយទុក្ខវេទនាដូចនេះ សារុំ ឈឺចិត្តគេចខ្លួនពីកណ្តាប់ដៃប៉ូលីស ដើម្បីទៅបាញ់សម្លាប់ សារិតបងនេរគុណ តែភ្នាក់ងារប៉ូលីសមកទាន់ក៏បាញ់សម្លាប់សារុំទៅ ។ លោកសេដ្ឋីយល់ព្រមឲ្យសារិតទទួលមាលាជាភរិយាឡើងវិញ ។

១-ក្រៅពីការខ្វះខាតខ្លះ ដែលយើងនឹងឃើញទៅខាងក្រោយខ្សែភាពយន្តនេះ បានលើកឡើងនូវបញ្ហាបច្ចុប្បន្នភាពដ៏មានសារៈសំខាន់ច្រើនប្រកបទៅដោយប្រាកដនិយមនឹងគតិអប់រំជាបង្គួរ ៗ

## ក)តស៊ូដើម្បីរស់

"ក្បួនជីវិត" បានបង្ហាញយើង នូវការតស៊ូរបស់បងប្អូនប្រុសពីរនាក់ (បងបង្អស់ចោលម្សៀតតស៊ូប្រយុទ្ធនឹងសេចក្តីទាលក្រ ហើយនឹងមេបំណុលដែលមករួមរឹតគ្រួសារ ដើម្បីរស់កានមានជីវិតជាសម្ភារៈ ហើយនឹងរៀនសូត្រខ្លះៗនឹងគេ ៗ បើជីវិតនៃគ្រួសារនេះ បេះតែរក្សាដំណើរដូចនេះបានតរហូតទៅ ឃើញថា គេអាចនឹងស្គាល់ពន្លឺនៃសុភមង្គលជាអប្បបរមាបាន ជាពិសេសគឺនៅពេលដែលសារិតចេញធ្វើការ ។

បំណុចនេះបានជួយអប់រំយុវជនយើង ឲ្យចេះរកសេចក្តីសប្បាយសេចក្តីថ្លៃថ្នូរឃើញ មិនថាឡើយតែក្នុងការងារខាងប្រាជ្ញាទេ ទោះបីជាការងារហត្ថកម្មក៏ដោយ ។ ឯកិត្តិយសរបស់មនុស្សម្នាក់ៗ វិញរាប់តនៅត្រង់សភាពស្អាតស្អំ នៃឋានភាពរបស់យើងក្នុងការងារយើងតែប៉ុណ្ណោះ មិនថាយើងជាកម្មករឬជានាម៉ឺនឬជាបញ្ញវន្តទេ ។

## ខ)ស្រវឹង "ជំនិយម"

ក៏ប៉ុន្តែ "ក្បួនជីវិត" ក៏បានលាតត្រដាងម្យ៉ាងទៀត នូវផលវិបាកនៃមនុស្សដែលពោរពេញទៅដោយការស្រើបស្រាលពាលោ ពុករលួយ ៗ យ៉ាងណាមិញ សារិតដែលចេញពីសាលា មានដំ-

ភែកង់ខ្ពង់ខ្ពស់ហើយ បែរជាដាច់ចិត្តយ៉ាងផុយ ដើម្បីក្បត់កិរិយា ( ទុរគតតែមានខ្លឹមសារ ) ហើយទៅជំរុះកិត្តិណាយសរបស់ខ្លួនចោលបន្តិចម្តងៗ នឹងសុខចិត្តទៅរស់នៅក្រោមអាណាព្យាបាលភាព របស់នាយទុនម្នាក់ដែលមកទាក់លោកយ៉ាងចំហ ទាក់ដើម្បីសំរួលផ្លូវជំនួញរបស់គេផង ទាក់ដើម្បីក្រោបស្រង់កូនស្រីគេផង ៗ យ៉ាងនេះហើយ "ព្រះតេជព្រះគុណ" សារិត ដែលឈ្លក់នឹងរូបសម្បត្តិជាសំបករបស់នាងសុរភីផង( មែនទែន ល្អចាញ់នាងមាលាទេ ) ឈ្លក់នឹង"ធំនិយម ព្រះតេជព្រះគុណនិយម"ផងឈ្លក់នឹង"លុយនិយម" ផង ហើយឈ្លក់នឹងការសប្បាយភាំសែផង កំផឹងតំណងល់ វង្វេងវង្វាន់យកមាន់ជាលា ភ្លេចកិរិយា ភ្លេចទាំងមាតាអ្នកមានគុណ ជាន់ឈ្លីកិត្យានុភាព ហើយបំផ្លាញសុភមង្គលជាអប្សរមានៃគ្រួសារខ្លួន សុភមង្គលដែលប្អូនទាំងពីរ ព្រមទាំងនាងមាលា បានខំយកញើសឈាមជុសខាត់មកយ៉ាងអង់អាចជាយូរហើយ ៗ

ការផុងខ្លួននេះ បណ្តាលមកពីការរស់នៅរបស់សារិត ដែលផ្អែកលើការស្រើបស្រាលតាមគេឯង ខ្វះអប្បមាទចំពោះសកម្មភាពគួរទាញរបស់នាយទុនប្រតិកិរិយា ៗ ហើយព្រះតេជព្រះគុណ ទំរាំបានភ្ញាក់ខ្លួន ក្តីក្អក ក៏ទាល់តែបាត់បង់អស់ជីវិតម្តាយមួយ ប្អូនប្រុសមួយ ហើយនឹងទាល់តែភរិយាកើតទុក្ខស្គមរីងរៃសឹងស្លាប់ខ្លួន ៗ សារុំបើបានជាបាញ់ត្រូវដៃ "ព្រះតេជព្រះគុណ" ហើយម៉ែបក៏មិនបង្ហើយតែម្តងទៅ កុំទុកនៅនាំឲ្យប្រឡាក់បរិសុទ្ធភាពនៃយុវជនយើងពិតៗ ដែលចេះស្គាល់សិទ្ធិនឹងករណីយកិច្ចខ្លួន ?

## គ) សភាពពុករលួយ ជិះជាន់ស្ត្រី

ឯចំណោទប្រកាន់និយមមួយទៀតរបស់រឿង គឺការជិះជាន់ ការមើលងាយរបស់បុរសទៅលើស្ត្រីៗ គ្រាន់តែកូនពីរម៉ោងប៉ុណ្ណោះ "ក្បួនជីវិត" បានបង្ហាញឲ្យឃើញគ្រួសារបី ដែលភរិយាត្រូវរងទុក្ខវេទនា ដោយប្តីមានស្រី ដោះដៃចោលៗ

២– ឯការខ្វះខាតរបស់រឿងវិញ បើតាមយោបល់យើងនៅត្រង់

## ក) មនោសញ្ចេតនានិយម

របស់តួអង្គជាច្រើន ( លើកតែសារុំមួយចេញ ជាពិសេស ) ដែលចេះតែបណ្តោយខ្លួនឲ្យអណ្តែតអណ្តូងទៅតាមតែការបត់បែននៃជីវិត ដោយគ្មានអប្បមាទ គ្មានការរាវរកស្វែងអ្វីបន្តិចសោះចំពោះគំនិតកន្ទួចកន្ទុក ពុកត្បុត ការបោកប្រាស់របស់មនុស្សមួយប្រភេទ ដែលមើលងាយមនុស្ស ៗ

សភាពការណ៍នេះ ស្របទៅតាមចំណងជើងនៃរឿង ក៏មែនហើយ ប៉ុន្តែវាបន្ទាបតម្លៃនៃប្រាកដនិយម នៃការតស៊ូ នៃការទុកចិត្តលើខ្លួន ដែលជាលក្ខណៈសំខាន់នឹងចាំបាច់របស់ហ្វីលចំរើននិមួយៗ មនុស្សយើងដែលមានជីវិតមកហើយ គេនឹងតែមានគោលដៅមួយឲ្យច្បាស់ ដើម្បីសំរេចការតស៊ូរបស់ខ្លួន កែប្រែជីវភាពខ្លួន សំដៅគោលដៅនោះ ហើយក្នុងការតស៊ូនេះទៀត ក៏ត្រូវតែមានការជឿជាក់ទុកចិត្តសមត្ថភាពខ្លួនផង ។ ត្រង់នេះហើយជាសារៈសំខាន់របស់មនុស្សយើងម្នាក់ៗ ។

—ដូចនេះហើយបានជាគេឃើញសារិជ្រះថ្លាដល់ទៅលើក „បេះដូងខ្លួន„ គឺនាងមាលាដែលសុខចិត្តស្លាប់រស់ចំពោះតែខ្លួនម្នាក់ឲ្យទៅបង់ខ្លួន ដែលជាមនុស្សពាលទៅវិញ ។ តើមិនគួរឲ្យអស់សំណើចទេឬ សំដីសារិ " បើអូនស្នេហាបងដោយស្មោះស្ម័គ្រមែន សូមតែព្រមរៀបការជាមួយនឹងសារិតទៅ! " សេចក្តីស្នេហាជាតុខូដែលលើកដាក់ទៅណា បានតាមចិត្តឬ? ឱ, តក្កវិជ្ជាអ៊ីហ្ន៎! ហើយនិយាយពីនាងមាលានោះទៀត ក៏ចេះតែសុខចិត្តទៅកើតដែរ! ខនេះឃ្លាតឆ្ងាយពីប្រាកដនិយមខ្លាំងណាស់ ព្រោះនៅក្នុងជីវិតជាក់ស្តែងគេមិនអាចនឹងជួបលក្ខភាពបែបនេះបានឡើយ នៅទីណាក៏ដោយ លើកតែ ពីក្នុង „ក្បូនជីវិត" ចេញ ។

—ដូចនេះហើយ បានជានៅចំពោះមុខសពសារុំ ដែលត្រូវប៉ូលីសបាញ់ស្លាប់នៅក្បែរសារិត ភរិយាចុង នឹងសេដ្ឋីប្តីប្រពន្ធ សារិនិយាយទៅកាន់នាងមាលាថា „ មាលា សុភមង្គលអូនមកដល់ហើយ „ តើសុភមង្គលអ្វី?-សុភមង្គលផ្អែកលើនាយទុននោះឬ? ហើយគេក៏ឃើញសារិស្វែងរកសុភមង្គលនៅបរមសុខ លែងរវីរវល់ពីជីវភាពជំគ្រោតគ្រាតក្នុងលោកនេះទៀតហើយ ។ តើនៅលើផែនដីយើងនេះ សារិ ធ្វើដូចនេះបានដូចចិត្តចង់មែនឬ ?

## ៣–របៀបបញ្ចប់

ខ្សែភាពយន្តនេះនឹងល្អមែនទែន បើសិនជាគេឲ្យសារិតស្លាប់ទោះដោយគ្រាប់កាំភ្លើង សារុំក្តី គ្រាប់ប៉ូលីសក្តី ហើយឲ្យសារុំរស់វិញ ព្រោះក្នុងបណ្តាតួអង្គទាំងអស់ មានតែសារុំមួយទេដែលជាអ្នកជ្រួតជ្រាបយុត្តិធម៌ ការពារយុត្តិធម៌ មានគំនិតស្អាតស្អំ ហើយជាអ្នកកតញ្ញូជាងគេបង្អស់ ។

## ៤–និយាយពីរូបភាពវិញ

ទាំងការថត ទាំងពាក្យសំដី ទាំងភ្លេង គឺសមរម្យល្មមហើយ ។ ហើយបើសិនជា "ចៅកែនោះធ្វើឲ្យបានចាស់បន្តិចទៀត សារិមានសក់មានធំ-

ណើរទើនបុកពា ជាអ្នកបររថយន្តពិត ៗ នោះគ្រាន់បើមែនទែន ៗ ហើយបើនិយាយឲ្យពិតទៅ គ្រាន់នេះហើយជាការខូចខាតរូបរបស់ហ្វីលខ្មែរយើង ៗ

ឡូតែយុវជនក្នុងណាក៏មានសក់ គុងហ្គោ រលើបរលោងដែរ ៗ

–ត្លួណាក៏មាឌកំទូ្ល ខែងវែង ដើរចំកោង ដៃក្តាប់ដៃដែរ ៗ

–សំលៀកបំពាក់ ហាក់ដូចជាបេះ តែចង់មាញោញឲ្យគ្រប់ម៉ាកតែម្តង ឆាកក្នុកមួយម៉ាកឆាកក្នុកមួយម៉ាកគ្មានគិតពីសមតាមកាលៈទេសៈឬមិនសមសោះ ៗ ទៅជាមិនមែនភាពយន្ត វាចង់ក្លាយទៅរកពិព័រណ៍ម៉ូដសំលៀកបំពាក់ទៅវិញ ៗ

ឧទាហរណ៍មួយយ៉ាងជាក់ស្តែង គឺថ្មី ៗ នេះ„នាងរំសាយសក់„(សម័យនគរគោកធ្លក)ចេញក្លួតពីក្នុងផ្កាឈូកមក ស្រាប់តែសំពត់បង្អៀតក្តួន (jupe serrée) រត់ចង់មិនរួច ៗ

–តន្ត្រីកំដរបរិយាកាស ឬមួយមានមិនដាច់លាប់ ឬមួយពួយទ្រហឹងអឹងកងឮស្ទួរតែក្ហូងតែម្តង ហាក់ដូចជាទៅអង្គុយស្តាប់ភ្លេងសៀមពោរកថិន ឬទៅអង្គុយស្តាប់ នៅគោជនីយដ្ឋានដូចនោះ ៗ នរណាមិននឹកឃើញពីខ្លួយដែលគ្រលួចសឹងបែកក្រដាសត្រចៀកក្នុងរឿង "បង់បំណេញដាច់បំណាង„ ឬភ្លេងដ៏ទ្រហឹងអឹងកងអាប់ រកស្តាប់អ្វីមិនឮសោះ នៅក្នុងរឿង"នាងរំសាយសក់„ ?



# ដំណើរទស្សនកិច្ច

## នៃគណប្រតិភូសាស្ត្រាចារ្យខ្មែរ

## នៅសាធារណរដ្ឋ ចិនប្រជាមានិត

(តនិងចប់)

និពន្ធដោយលោក ឈឹម–គិមហុង
ចាងហ្វាងវិទ្យាល័យ ព្រះមុនីវង្សបាត់ដំបង

### ណាន់កាំង

ណាន់កាំងក៏ជាក្រុងវិសេសមួយនៃប្រទេសចិន ហើយធ្លាប់ធ្វើជារាជធានីផង ៗ ដូចជាក្រុងចាស់ៗឯទៀត ណាន់កាំងមានកំពែងយ៉ាងមាំព័ទ្ធជុំវិញ សំរាប់ការពារទ្រាំងសត្រូវ ៗ នៅទីនោះ គណៈប្រតិភូទស្សនា :

១– មហាវិទ្យាល័យ

មហាវិទ្យាល័យនេះ មានកំណើតតាំងពី គ-ស-១៩០៧ ៗ នៅគ្រឹះស្ថានសិក្សានេះគណៈប្រតិភូបានទស្សនា :

–បន្ទប់ដេកនៃសិស្សនារីដែលឃើញមានគ្រែជាពីរថ្នាក់;

–បន្ទប់រៀនរួមមួយដ៏ធំទូលាយហើយដែលសិស្សទាំងឡាយ អង្គុយរៀនយ៉ាងស្ងៀមស្ងាត់;

–បន្ទប់ពិសោធន៍ខាងផ្នែករូបសាស្ត្រនិងគីមី;

–បន្ទប់ខាងផ្នែកគារពសាស្ត្រដោយមាន កែវយិតមួយយ៉ាងធំ ៗ

២–សាលាមធ្យមសិក្សា

ដូចជានៅកន្លែងឯទៀត ៗ គេឃើញមានសម្ភារៈច្រើនសំរាប់ធ្វើការពិសោធន៍ ធ្វើការអនុវត្តន៍និងសំរាប់ធ្វើការហត្ថកម្ម ៗ នៅគ្រឹះស្ថាននេះ គណៈប្រតិភូបានទស្សនា :

– បន្ទប់ពិសោធន៍ខាងផ្នែករូបសាស្ត្រគីមីនិងវិទ្យាសាស្ត្រធម្មជាតិ ;

– រោងហត្ថកម្មខាងដែក សំរាប់ធ្វើសោរពន្លាក ៗលៗ ;

–រោងឈើសំរាប់ហាត់ធ្វើទូក កប៉ាល់ យន្តហោះតូចៗដោយមានតាមជញ្ជាំងនូវរូបទូកកប៉ាល់និងយន្តហោះផ្សេងៗទាំងឡាយ ;

–បន្ទប់គាំរើងសំរាប់សិស្សហ្វឹកហ្វឺន ខាង

វិជ្ជាបាញ់ ។

៣ –វិមានអនុស្សាវរីយ៍ចំពោះបុព្វបុរសតាំងឡាយដែលបានបង់ជីវិតក្នុងសង្គ្រាមបដិវត្តៈឃើញសិស្សមួយក្រុមយកកំរងផ្កាមកបូជា រួចមកក្រុមបានធ្វើសច្ចាប្រណិធានដោយសិស្ស ឯទៀតថាតាម ។

៤–ម៉ុងនៃលោក **ស៊ុន អ៊ាត សេន** (ដែលយើងច្រើនអាន ស៊ុន យ៉ាត សេន) ត្រង់កំពូលភ្នំតូចមួយដែលគេអាចឡើងទៅដល់តាម ជណ្ដើរស៊ីម៉ងត៍មានកាំយ៉ាងធំទូលាយ; សួនស្រស់យ៉ាងស្អាតបានលំអនាទីនេះ ។ តាមផ្លូវត្រឡប់មកសណ្ឋាគារវិញ ខ្ញុំបានឃើញព្រះវិហារ៩ជាន់និងម៉ុងនៃព្រះអធិរាជទី១ ខាងព្រះរាជវង្ស "មិញ"

៥– សួនសត្វដែលមានតាំង: ត្រីដ៏ស្អាតៗសំរាប់ដាក់លំអក្នុងកែវ ខ្លា សិង្ហ អូត ។ល។ នៅទីនោះមានដាំផ្កាដ៏ល្អៗដែរ ។ ចំពោះដើមមួយដែលមានផ្កាចំនួន ៤០០ គេក៏បានពត់ពេនផ្កានេះជាក្បាច់យ៉ាងប្រសើរ ។

នៅថ្ងៃ ១៣ វិច្ឆិកា ពេលម៉ោង ១១ គណៈប្រតិភូក៏ចាកចេញ ណាងកាំង ឆ្ពោះទៅក្រុង "ស៊ាំងហាយ" រយៈដំណើរតាមរថភ្លើងអស់កំណត់ពេល ៥ម៉ោង៣០ នាទី ។

## ស៊ាំង ហាយ



ស៊ាំងហាយជាទីក្រុងដ៏សំខាន់មួយ ដែលមានមនុស្សចំនួន ១០០០០០០០ នាក់មានគ្រឹះស្ថានស្ដុកស្ដម្ភច្រើន ហើយផ្ទះដែលខ្ពស់ជាងគេមាន ២៤ ជាន់

គណៈប្រតិភូបានទស្សនា :

១–វិទ្យាល័យ នារី

ដើមឡើយវិទ្យាល័យនេះជារបស់អាមេរិកាំង លោកស្រីជាំងកាយជៀក បានរៀនសូត្រនៅទីនេះលោកស្រីចាងហ្វាងបាននាំទស្សនា :

–ថ្នាក់ទី ៣ ទំនើបកំពុងសិក្សាផ្នែកគណិតសាស្ត្រ ផ្នែកវិជ្ជានេះមាន ៦ ម៉ោងក្នុង ១ សប្ដាហ៍:

– សិស្សកំពុងធ្វើការពិសោធន៍ខាងផ្នែកអគ្គិសនីដោយមានប្រដាប់មួយសំរាប់គ្នាពីរនាក់ ;

–២ គ្រឹះស្ថានដ៏ស្ដុកស្ដម្ភមួយសំរាប់ដាក់តាំងវត្ថុផ្សេងៗដែលក្រុងស៊ាំងហាយបានផលិត ។

៣–គ្រឹះស្ថានខាងវិចិត្រសិល្ប

នៅទីនេះមានជាងយ៉ាងចំណានៗ កំពុងប្រកបខាងផ្នែកផ្សេងៗនៃវិចិត្រសិល្បដូចជា :

-ដេរប៉ាក់,

-គូរឬចម្លាក់លើឫស្សី ក្អក ឈើ,

-ធ្វើផ្កា សត្វ ដោយប្រើក្រដាស សំពត់ លួស ឬ ម្សៅ ។

៤- កំដយុវជន

នៅទីក្រុងដទៃៗទៀត ច្រើនមានគ្រឹះស្ថានស្តុកស្តម្ភបែបនេះដែរ សំរាប់យុវជនមកហ្វឹកហ្វឺនខាងវិជ្ជាផ្សេងៗ ។ នៅក្រៅម៉ោងសាលា គេបែកជាវេនរាល់សាលាទទួលយុវជនអាយុពី ៧ ទៅ ១៧ ឆ្នាំ ។ នៅទីនោះយុវជនអាចប្រកបវិជ្ជាផ្សេងតាមនិស្ស័យដូចជា :

-គំនូរឬសិល្បខាងគូរផាត់ពណ៌

-ធ្វើគំរូក្បាល់ ឬ យន្តហោះតូចៗ ដោយគ្រឿងដែក ឬ ឈើ.

-ហ្វឹកហ្វឺនខាងសម្ភារៈអគ្គិសនី

-ភ្លេង មានក្មេងស្រីមួយអាយុ ៩ ឆ្នាំ លេងព្យាណូយ៉ាងចំណាប់

-ចម្រៀង

-របាំ ៖ នៅពេលនោះ យុវនារីបានសំដែងរបាំ ២ ជាកិត្តិយសដល់គណៈប្រតិភូ របាំទីមួយមានអត្ថន័យបង្ហាញសេចក្តីសក្តិសិទ្ធិ អំពីការរួមកម្លាំងៗ ដំណើររបាំមានដូចនេះ : ,,នារីម្នាក់តែងខ្លួនជាដៃថៅនៅកណ្តាលឆាក នារីម្នាក់បានចិតទំដក តែពុំរបើក រួចទើបមានបន្ថែម២-៣-៤-៥ នាក់ទើបដៃថៅរលើង,, ។



របាំទីពីរ បានរាំឡើងដោយនារី ៥ នាក់ៗ ក្នុងដំណើររបាំទាំងពីរនេះ មានភ្លេងព្យាណូសំរាប់បន្ទរ

-ហ្វឹកហ្វឺនខាងវិជ្ជាសៀក

៥- រោងតម្បាញ.

នេះជារោងតម្បាញលេខ១៩ ។ វិស្វករម្នាក់នៃរោងនេះបានមកបំពេញបេសកកម្ម នៅប្រទេសកម្ពុជា ។ និស្សិតខ្មែរ ២២ នាក់ដែលពេលនោះបានត្រឡប់មកមាតុប្រទេសរួចហើយបាននៅរៀនទីនោះដែរ ។ រោងនេះមានកម្មករចំនួន៥០០០នាក់ទីង មានម៉ាស៊ីនចាប់ពីស្រូបកប្បាសជាលំដាប់ រៀងដរាបដល់ជាក្រណាត់សំពត់ៗ ក្រោយពីមើលម៉ាស៊ីនរួចចាងហ្វាង នៃរោងតម្បាញបាននាំគណៈប្រតិភូទៅទស្សនាកន្លែងសង្គមកិច្ចផ្សេងៗ សំរាប់កម្មករ ដូចជា ៖

-ភោជនីយស្ថានរួម

–បន្ទប់សំរាប់ទារកដល់ពេលម៉ោងកម្មការិនីជាម្ដាយអាចឈប់សំរាកដើម្បីមកបំបៅទារក

–បន្ទប់សំរាប់ពិនិត្យនិងថែទាំជំងឺ

–គ្រឹះស្ថានរៀនសំរាប់មនុស្សធំនិងយុវជន

៦–ទទួលបដិសណ្ឋារកិច្ចនៃនិស្សិតខ្មែរ

នៅសណ្ឋាគារសំណាក់ និស្សិតខ្មែរ ៣ រូប ដែលមករៀនខាងបន្ទុះក្ដារនិងជ្រលក់ពណ៌បានមកជួបនឹងគណៈប្រតិភូ គេបានរៀបរាប់យ៉ាងត្រួសៗ អំពីជីវភាពគេនៅប្រទេសចិនដោយបញ្ជាក់ថា „គេទទួលទានអាហារបរិភោគប្លែកពីនិស្សិតចិន „ៗ

ថ្ងៃ ១៧ វិច្ឆិកា ម៉ោង ១៨ គណៈប្រតិភូក៏បានចាកចេញក្រុង ស៊ាំងហាយ ដើម្បីឆ្ពោះទៅ „ហាំង-ចូវ„ និងបានទៅដល់ទីក្រុងនេះ នៅពេលម៉ោង ២១ ៗ



## ហាំង-ចូវ

លោកសេនាប្រមុខប្រេគយ៉ឺទបនាយកនិងរដ្ឋមន្ត្រីខាងការបរទេស បានជំរាបគណៈប្រតិភូថា „តាមពាក្យបូរាណចិនតៗ មក គេបានថែងថា ហាំងចូវ ជាស្ថានសួគ៌នៃមនុស្សលោក„ៗ តាមពិតឃើញថាដូច្នោះមែនព្រោះមានលំអធម្មជាតិ បឹងទន្លេ ភ្នំ និងវត្តជាតិបានតុបតែងដំបន់នេះ ៗ នៅហាំងចូវ គណៈប្រតិភូបានទស្សនា:

–ភ្នំមួយដ៏មានព្រះពុទ្ធរូបចំនួន១០០០ដែលគេបានឆ្លាក់តាមជងចង្កេះម៉្យាងទៀតមានរូងព្នំពេនតាមដងចង្កេះភ្នំនេះគួរឲ្យជាទីចាប់អារម្មណ៍ ៗ នៅជិតនេះមានព្រះវិហារមួយដែលក្នុងនោះ មានព្រះពុទ្ធបដិមាករសាងអំពីឈើក្រឡុបដ៏មានកំពស់១៩មៗ នៅពេលនោះមានឃើញបណ្ដាជន មកកំសាន្តលេងយ៉ាងកុះករដែរ ជាពិសេសបានឃើញក្រុមកម្មករអគ្គិសនីអង្គុយជាវង់លើវាលស្មៅ ហើយមានកម្មការិនីមួយឈរច្រៀងកណ្ដាល ៗ ឆ្ងាយបន្តិចមានកម្មកររោងចក្រឡានអង្គុយជាវង់ដែរ ដោយមានទិទាននិងលេងឆាករឿងជាកំសាន្ត ៗ

–រោងតម្បាញ

នៅរោងចក្រនេះ គេមានតម្បាញក្រណាត់ផ្កា កម្រាលគុ ប្តជញ្ជាំង និងរូបភាពវិរបុរសខាងកុម្មុយនិស្តនិយម ៗ ថ្លៃក្រណាត់ផ្សេងៗ ជាការៈលើរដ្ឋកិច្ចបាលកំណត់ ៗ

–រោងអគ្គិសនីតូចដោយកម្លាំងទឹកព្រែក រោងនេះស្ថាបនាសំរាប់យុវជន ៗ ឱកាសនោះនារីមួយរូបអាយុចំនួន ១៣ ឆ្នាំ បានកាន់កាប់ម៉ាស៊ីននេះ និងបានធ្វើអត្ថាធិប្បាយដល់គណៈ

ប្រតិភូ ៗ

៤--ប្រជាសមាគមខាងដំណាំតែ

ចេញពីក្រុងហាំងចូវបន្តិចទៅ មានតំបន់ភ្នំជាច្រើន គឺនៅកន្លែងនោះហើយដែលមានដំណាំតែតាមចង្កេះភ្នំ ៗ ក្នុងមួយឆ្នាំ គេបេះយកផល៤លើក នៅទីនោះមានសម្ភារៈគ្រប់សព្វដើម្បីធ្វើស្ងួតតែ ឲ្យបានរហូតទៅជារបស់អាចដាក់ក្នុងកញ្ចប់ ឬកំប៉ុង ៗ នៅប្រជាសហគមនេះ គេមានចិញ្ចឹមជ្រូកផងដើម្បីបានផលសាច់និងជីសំរាប់ចំការ ៗ



៥– សួនឧទ្យាន

នៅទីក្រុងនិមួយ ៗ ដែលគណៈប្រតិភូបានទស្សនា ខ្ញុំតែងឃើញមានសួនឧទ្យានធំៗ សំរាប់លំអក្រុងនិងជាទីកំសាន្តនៃប្រជាជនៗនៅហាំងចូវ គេមានតាំងសម្ភិទិនផ្កាដែលកើតខែឆ្នាំ ១៩៥៨ ដូចគ្នាក្នុងក្រុងតែមួយ ៗ សូមជំរាបមិត្តថា ក្នុងរយៈទស្សនកិច្ច ខ្ញុំឥតបានឃើញផ្កាឬធ្លា នៅកន្លែងណាឡើយ ក្រៅពីក្នុងសួនសត្វ ៗ

នៅយប់ ២០ វិច្ឆិកា ពេលម៉ោង ២២ គណៈប្រតិភូ ក៏បានចាកចេញហាំងចូវឆ្ពោះទៅក្រុងក្វាំងចូវ ៗ ដំណើរតាមរថភ្លើងលើកនេះ វែងឆ្ងាយជាងសព្វដងព្រោះទាល់តែព្រឹកថ្ងៃ ២២ វិច្ឆិកា ពេលម៉ោង៦ទើបបានដល់ ៗ

– ក្វាង-ចូវ –

គណៈប្រតិភូបានមកឈប់សំណាក់ នៅសណ្ឋាគារដើមដដែលវិញ នឹងបានទស្សនា :

១ - មធ្យមសិក្សានារី

តាមសេចក្តីអត្ថាធិប្បាយ នៃលោកស្រីចាងហ្វាង សាលានេះមានសិស្ស ២០០០ នាក់ ដោយមានតែ ២០០ នាក់ទេរស់នៅក្រៅ ៗ ដោយនាទីដីមានទំហំធំទូលាយ សិស្សបានហ្វឹកហ្វឺនខាងដំណាំនិងចិញ្ចឹមសត្វ ៗ ការថែសំអាតទាំងប៉ុន្មានជាករណីយកិច្ចនៃសិស្ស ៗ សម្ភារៈខាងការពិសោធន៍ក៏មានគ្រប់គ្រាន់បរិបូណ៌ ៗ ក្នុងបរិវេណសាលាខ្ញុំបានប្រទះឃើញ គ្រឹះស្ថានសំរាប់សិស្សដេកគ្រឹះស្ថានសំរាប់សាស្ត្រាចារ្យលី គ្រឹះស្ថានតូចៗ សំរាប់សាស្ត្រាចារ្យមានគ្រួសារ និងគ្រឹះស្ថានសំរាប់ទារកនៃបុគ្គលិក ៗ

២– ក្រុង "ហ្វាយ-សាន"

ក្រុងនេះនៅចំងាយពីក្វាំងចូវចំនួន៣០គម ៗ តាមផ្លូវគណៈប្រតិភូបានឈប់ទស្សនាប្រជាសហគមមួយៗលោកចាងហ្វាងជំបន់នេះ បានជប់លៀង

ដោយស្ពី សណ្ដែកដីលីង ក្រូច លូងទឹងអំពៅ ដែលមានខុជាសេយ៉ាងឆ្ងាញ់ពិសា ។

នៅក្រុងហ្វូយសានចាងហ្វារងសិក្សាខាងផ្នែកដំបន់នេះបានទទួលគណៈប្រតិភូដោយរាក់ទាក់ទឹងបាន រៀបពិធីជប់លៀងពេលថ្ងៃត្រង់ជូនជាកិត្តិយស ។ ហ្វូយសាន ដើមឡើយជាទីក្រុងមួយធំស្មោកគ្រោកឥឡូវនេះបានជាប់លេខជាទីក្រុងស្អាត ។ គេបាននាំគណៈប្រតិភូដើរតាមផ្លូវតូចៗ ដែលក្រាលដោយស៊ីម៉ងទឹងបានប្រាប់ថា បណ្ដាជនបោសសំអាតផ្លូវទាំងនេះយ៉ាងតិចមួយដងក្នុងមួយថ្ងៃ ។ នៅហ្វូយសានគណៈប្រតិភូបានទស្សនាៈ

—ឡសំរាប់ធ្វើគ្រឿងផ្សេងៗដោយដីដុត ។ រោងឡនេះដែលមានចំងាយ ៦ គម ពីក្រុង ។ នៅតាមផ្លូវ ធ្លោះទៅផែមួយទល់មុខទឹងកោះ «ហៃ-ណាំ» ។

—រោងវិចិត្រសិល្បខាងផ្នែកក្រដាស ។ នៅទីនោះ គេមានធ្វើគោមទឹងកាត់គួរគំនូរផ្សេងៗ លើក្រដាសក្រហមសំរាប់លក់ទៅនាយសមុទ្រ ។

—នៅព្រឹកថ្ងៃ២៥វិច្ឆិកា ពេលម៉ោង៨គណៈប្រតិភូបានចាកចេញក្វាំងប៉ូវ ដើម្បីត្រឡប់មក ហុងកុងវិញ ។ មិត្តចិន ៤ រូបបានជូនដំណើររហូតដល់ព្រំប្រទល់ដែន ។ នៅពេលប្ដូររថភ្លើងគណៈប្រតិភូយើង មានសេចក្ដីអាឡោះអាល័យយ៉ាងខ្លាំងចំពោះមិត្តចិនទាំងឡាយ ដែលបានខិតខំទទួលគណៈប្រតិភូដោយមេត្រីភាព ទឹងដោយសេចក្ដីស្មោះស្ម័គ្រយ៉ាងក្រៃលែង ។ យើងបានមកដល់ហុងកុង វិញនៅថ្ងៃដដែលពេលម៉ោង ១៤ ។

ដំណើរទស្សនកិច្ចនេះធ្វើឡើងអស់រយៈពេលមួយខែគត់ ។ ចំពោះខ្ញុំ ប្រទេសចិនមានសភាពដំបូងក ដែលខ្ញុំពុំបានគិតយល់ថាដូច្នេះឡើយ ដោយធ្លាប់តែបានឃើញចរិយាទឹងជីវភាព នៃជនជាតិចិននាស្រុកយើង ។

ជាដំបូង ខ្ញុំមានសេចក្ដីស្ងើចសរសើរយ៉ាងខ្លាំងចំពោះអ្នកដឹកនាំគ្រប់ជាន់ថ្នាក់ ដែលបានខិតខំទាំងកម្លាំងកាយនិងទាំងកម្លាំងចិត្ត ដើម្បីសេចក្ដីចំរើនយ៉ាងឆាប់រហ័សនៃមាតុប្រទេសខ្លួន ។ មិត្តជ្រាបថា ដូចពីដើមប្រទេសចិនមានទុក្ខវេទនាគ្រប់របបគ្រប់យ៉ាងដូចជាៈ

—សេចក្ដីក្រលំបាកដែលនាំឲ្យពលរដ្ឋខ្លះ ចាកចេញមាតុប្រទេស ដើម្បី ទៅប្រកបជីវភាពឯបរទេស ។ សព្វថ្ងៃនេះ អាហារបរិភោគបានល្មមចំពោះ ពលរដ្ឋទូទៅ តែពុំទាន់ជាបរិបូណ៌ទឹងឆ្ងាញ់ណាស់ណាទៅឡើយដោយផលិតខាងក

សិកម្មច្រើនលក់ចេញទៅបរទេស ដើម្បីប្តូរយកគ្រឿងម៉ាស៊ីន សំរាប់ដំឡើងរោងចក្រផ្សេងៗ ។

—សេចក្តីជិះជាន់នៃប្រទេសនានា ៗ កាលជំនាន់ដើម ដែលសំខាន់ៗទាំងឡាយច្រើនមានបរទេសត្រួតត្រានឹងនៅនាកន្លែងកំសាន្តខ្លះ គេមានដាក់បំរាម ‹‹ហាមមិនឲ្យចិននឹងឆ្កែចូល,,

ចំបាំងរវាងជប៉ុននឹងចិន ដែលមានកើតឡើងអស់រយៈកាលជាច្រើនឆ្នាំ ។

—ចំបាំងរវាងគ្នាឯងក្នុងស្រុក ដូចមិត្តអាចបានដឹងខ្លះតាមពង្សាវតារថា ប្រទេសចិនដោយធំទូលាយពេកទៅការត្រួតត្រានៃរដ្ឋាភិបាលកណ្តាលច្រើនតែពុំសូវសក្តិសិទ្ធិ ម៉្លោះហើយរឿងចោរកម្ម ឬចំបាំងរវាងនាយទាហាន ច្រើនកើតមានជាញឹកញាប់ ៗ នៅថ្មីៗនេះ ចំបាំងក្នុងស្រុកទើបតែផុតរលត់នាឆ្នាំ១៩៤៩ គ្រាន់តែ១០ឆ្នាំប៉ុណ្ណោះប្រទេសចិនបានលោតផ្លោះ ទៅកាន់សេចក្តីចំរើនយ៉ាងអស្ចារ្យ ឯមហាប្រទេសទាំងឡាយក៏ពុំសូវហ៊ានឈ្លានពាននឹងមានតែសេចក្តីកោតញញើតវិញផងៗ

## តាមខ្ញុំយល់ប្រទេសចិនសព្វថ្ងៃយកចិត្តទុកដាក់ខាង២ផ្នែក: រោងចក្រនិងយុវជន

១—តាមផ្លូវដំណើរ ខ្ញុំតែងបានប្រទះឃើញបំពង់ផ្សែងនៃរោងចក្រទាំងឡាយជាច្រើន ឯគ្រឹះស្ថានថ្មីៗច្រើនសង់សំរាប់ជាទីលំនៅនៃកម្មករ ។

២—ចំពោះយុវជន រដ្ឋាភិបាលក៏បានខិតខំអប់រំយ៉ាងហ្មត់ចត់ដោយ ទាញចិត្តយុវជនឲ្យយល់ជាក់នូវគុណសម្បត្តិដ៏ប្រសើរនៃរបៀបគ្រប់គ្រងថ្មី ៗ ក្នុងវិទ្យាល័យមួយ ដោយបានបើកសៀវភៅអានគេសំរាប់សិស្ស ខ្ញុំបានប្រទះឃ្លាដូចជា :

"យើងជាអ្នកត្រាយផ្លូវ"

"យើងស្រឡាញ់មាតុប្រទេសយើង,,

‹‹មាតុប្រទេសយើងមានរោងចក្រ,,

‹‹យើងជាកូនសិស្សល្អនៃលោកប្រធានម៉ៅ,



តាមសេចក្តីសង្កេតខ្ញុំយល់ថា ការអប់រំដើម្បីឲ្យពលរដ្ឋចិនប្រែប្រួល ជំនឿចាស់ខ្លះចេញដូចជាបានទទួលសេចក្តីសក្តិសិទ្ធិច្រើន:

-យុវជននាបច្ចុប្បន្នកាល ឥតដឹងថាតើពិធីដំឡើង ឬហៅអ្នកតាជាយ៉ាងដូចម្តេច ព្រោះគេថាគ្មានត្រូវការបន់ស្រន់ឲ្យជំងឺសះស្បើយ ឬសូមទឹកភ្លៀងអ្វីឡើយ ដោយប្រទេសចិនថ្មីមានពេទ្យ សឹងតែគ្រប់គ្រាន់និងខិតខំ ស្ថាបនាទំនប់ទឹកជាលំដាប់ៗ

ឥឡូវនេះ ពេលអ្នកតាទៅជាសារមន្ទីរឬការិយាល័យផ្សេង ៗ ក្រដាសក្រហម ធ្វើនៅស្រុកចិនសំរាប់តែបញ្ជូនលក់ទៅឯខាងនាយសមុទ្រ ។

—ចិនភាគខ្លះចាប់បូជាសព ដោយគេយល់ថាចំណេញដីនិងត្រឹមត្រូវតាមក្បួនអនាម័យ ។ គេបានកាប់គាស់ទីផ្នូរច្រើនកន្លែង ដើម្បីយកដីធ្វើផលិតផល ។

—នារីចិនប្រកបការងារ ក្រៅផ្ទះដូចគ្នានឹងបុរស ។ ខ្ញុំបានសង្កេតថានារីដូចជាមានសេចក្ដីសាទរច្រើន ចំពោះរបៀបគ្រប់គ្រងថ្មី ព្រោះនៅបន្ទប់ដំណេកសិស្សនារីនៃវិទ្យាល័យ ខ្ញុំតែងបានប្រទះឃើញរូបលោកប្រធានម៉ៅនិងលោកឡេនីន ។ ម្យ៉ាងទៀត នៅគ្រប់គ្រឹះស្ថាន ពិពណ៌ផលិតនារី អ្នកបង្ហាញតែងមានទឹកមុខស្រស់និងរីករាយជាអនេក ដើម្បីណែនាំពន្យល់នូវវត្ថុផ្សេង ៗ ដែលប្រទេសចិនបានផលិត ។

ដើម្បីឲ្យប្រទេសចិនលោតផ្លោះ ទៅកាន់សេចក្ដីចំរើនយ៉ាងឆាប់រហ័ស និងបានស្មើមុខក្នុងចំណោមមហាប្រទេសទាំងឡាយ ពលរដ្ឋទូទៅបានខិតខំធ្វើការដោយអត់ធ្មត់និងគោរពវិន័យយ៉ាងពេញលេញ :

—ដូចមិត្តបានជ្រាបស្រាប់ថា នាបច្ចុប្បន្នកាលនេះ ពលរដ្ឋទូទៅគ្រាន់តែបរិភោគល្មមៗ ពុំទាន់ជាបរិបូរណ៍ និងឆ្ងាញ់ពិសានៅឡើយ ។ ដូចនេះហើយបានជានិស្សិតខ្មែរទទួលទានអាហារខុសពីនិស្សិតចិន បានជាអ្នកជូនដំណើរនៃគណៈប្រតិភូឥតមានទទួលទានបាយជាមួយ ។

—ឯកជនទូទៅ ច្រើនមានកង់ ។ ក្នុងដំណើរទស្សនកិច្ចនេះ ខ្ញុំឥតប្រទះអ្នកមានយានជំនិះជាគ្រឿងម៉ាស៊ីនឡើយ ក្រៅពីឡានផ្ទុកឥវ៉ាន់ផ្ទុកអ្នកដំណើរសំរាប់រដ្ឋាភិបាលឬគណៈប្រតិភូ និងម៉ូតូខ្លះសំរាប់ប៉ូលីសនិងទាហាន ។ នៅគ្រឹះស្ថានពិពណ៌មួយ ខ្ញុំឃើញមានតាំងកង់ម៉ូតូ តែដោយឥតប្រទះអ្នកជិះទាល់តែសោះ ប្រហែលជាគេផលិតសំរាប់តែលក់ទៅបរទេសសិន ។



—និស្សិតខ្មែរម្នាក់បានប្រាប់ខ្ញុំថា „ដើមឡើយមានឡានតាក់ស៊ីដែរ ។ តែក្នុងរវាងឆ្នាំនេះរដ្ឋាភិបាលបានប្រកាសនយោបាយសន្សំសាំង ។ ម្ល៉ោះហើយ ឡានតាក់ស៊ីក៏ឈប់លែងរត់អស់ទៅ ។

ឡានដឹកទំនិញឬដឹកអ្នកដំណើរក៏បានប្រើ ឧស្ម័នជំនួសទឹង អាចសំគាល់បាន ដោយស្បោងឧស្ម័ននៅលើដំបូល ។ ចំណែកឡានដាក់គណៈប្រតិភូក៏អនុវត្តនយោបាយនេះ ដោយពន្លត់ម៉ាស៊ីន នៅពេលបង្អង់ចាំចង្កៀងក្រហមផុត ឬនៅពេលល្បឿនឡានបានល្បឿនគ្រាន់បើ ។

—សំលៀកបំពាក់ ពុំទាន់ជាបាន ស្រស់នៅឡើយ ។ ទុកជានៅផ្សារ នៅរោងហ៊ី រោងល្ខោន រោងកុន ពលរដ្ឋទូទៅច្រើនស្លៀកពាក់សំលៀកបំពាក់ធ្វើការ ដែលមានពណ៌ខៀវដដែល ៗ គេគិតមានប្រើឡើយគ្រឿងដែលជាពុំចាំបាច់ៗ ក្នុងដំណើរទស្សនកិច្ច ខ្ញុំឥតប្រទះអ្នកពាក់វ៉ែនតាកែវពណ៌ដល់ម្នាក់ឡើយ នឹងបានជួបអ្នកបង់ក្រាវ៉ាត់តែ ២ នាក់ គឺអ្នកបំរើនៅសណ្ឋាគារនាក្រុងសាំងហាយ ។

— ដោយប្រទេសចិនពុំទាន់ជាសំបូរណ៍នៅឡើយ ខាងគ្រឿងម៉ាស៊ីនៗ ក្នុងទីក្រុង ឬជនបទគេតែងជួបប្រទះក្រុមមនុស្សរហូតដល់ចំនួន ៣០ ឬ ៤០ នាក់ ទាញអូសដោយខ្សែពួរនូវឡានចាស់ឬវត្ថុអ្វីផ្សេងៗ ។

— សេចក្ដីបញ្ញើផ្សេងៗពីរដ្ឋាភិបាលច្រើនបានទទួលការអនុវត្តន៍ដោយហ្មត់ចត់អំពីពលរដ្ឋទូទៅៗ ដូចមិត្តជ្រាបស្រាប់ថា ឆ្កែ ឬ ឆ្មា សព្វថ្ងៃនេះពាយអស់ពីស្រុកចិន ។ ចំណែករុយ ការចំបាំងនេះតែនៅមានត ៗ អ្នកបើកឡានខ្ញុំ ឲ្យតែឃើញរុយ គាត់ដេញទាល់តែជួនកាលឡានបង្ខូក ។

ដោយជួបប្រទះនឹងលទ្ធផលដ៏ជាក់ស្ដែង ពលរដ្ឋចិនទូទៅ បានសំដែងសេចក្ដីអង់អាចយ៉ាងក្រៃលែង ក្នុងការបំពេញករណីយកិច្ចរបស់ខ្លួនរៀងរាល់ថ្ងៃ ។

ខ្ញុំសូមស្មេះនឹងសូមមិត្តអ្នកអានមេត្តាអនុគ្រោះបើមានលើសខ្វះឬខុសឆ្គង ។

ឈួរ-គិម-ហុង
នាយកវិទ្យាល័យ ព្រះមុនីវង្ស



# ដំណើររបស់ខ្ញុំ ទៅកាន់ប្រទេសជប៉ុន

ដោយ
លោក ម៉ៃ-លន់ សាស្ត្រាចារ្យ

ដូចមិត្តខ្លះជ្រាបស្រាប់ ក្រសួងសិក្សាធិការជាតិបានចាត់ខ្ញុំឲ្យទៅចូលរួមក្នុងសន្និសីទស្តីពីស្ថិតិសិក្សានៅប្រទេសជប៉ុន ចាប់ពីថ្ងៃទី ១៥ កញ្ញា ដល់ថ្ងៃទី ២៨ កញ្ញា ឆ្នាំ ១៩៦១ ។

ដោយមានសេចក្តីស្នើពីគណៈកម្មាធិការនិពន្ធទស្សនាវដ្តី ខ្ញុំសូមជូននូវសេចក្តីចាប់អារម្មណ៍របស់ខ្ញុំ តាមទំព័រទស្សនាវដ្តីសាស្ត្រាចារ្យយើងដូចតទៅនេះ ។

## ពីភ្នំពេញទៅព្រៃនគរ

នៅព្រឹកថ្ងៃ ១៤ ខែ កញ្ញា វេលាម៉ោង ៩ និង ១៥ នាទី ខ្ញុំត្រូវចេញដំណើរពីចំណតអាកាសចរ ពោធិចិនតុង តាមអាកាសយាន អ៊ែរវៀតណាម ។ ៤៥ នាទីក្រោយមកខ្ញុំបានទៅដល់ចំណតអាកាសចរ តាំងសឺងញឹក (ព្រៃនគរ) ។ អ្នកដំណាងខ្មែរម្នាក់នៅប្រតិភូខ្មែរប្រចាំក្រុង ព្រៃនគរ បានមកចាំទទួលខ្ញុំដោយរាក់ទាក់រីករាយ ។ ក្រោយពីបំពេញទំរង់ការផ្សេងៗ នៅចំណត អាកាសចរ លោកដំណាងនោះក៏នាំខ្ញុំឆ្ពោះទៅកាន់សណ្ឋាគារដើម្បីសំរាកមួយយប់ ។ លុះស្អែកឡើងទើបខ្ញុំត្រូវបន្តដំណើរទៅទៀត ។

សូមជំរាបថា ក្នុងចំណោមអ្នកធ្វើដំណើរតាមអាកាសយានជាមួយខ្ញុំក្នុងថ្ងៃនោះ មានខ្មែរប្រាំនាក់ទៀត ដែលសុទ្ធតែជានាយទាហានទីង នាយទាហានរង ។ ខេមរជនទាំង ៥ នាក់ ត្រូវធ្វើដំណើរទៅកាន់ សហរដ្ឋអាមេរិក ក្នុងថ្ងៃនោះតែម្តង ដោយគ្រាន់តែចុះពី អ៊ែរវៀតណាម

ហើយមួយម៉ោងក្រោយមក ត្រូវជិះកប៉ាល់ហោះ ប៉េអាអា ដែលត្រូវចេញនៅម៉ោង ១១ និង ៣០ នាទី ។ តែផ្ទុយពីការគ្រោងទុកជាមុននេះ អ្នកដំណើរខាងលើ ពេលដែលចុះពីយន្តហោះពុំឃើញមានគណៈបេសកកម្មអាមេរិកមកចាំទទួល ឯអាកាសយានដែលខ្លួនត្រូវបន្តដំណើរក្នុងថ្ងៃនេះ ក៏ជាគ្មានកន្លែង ព្រោះពេញគ្រប់ចំនួនទៅហើយ ។ ឯអ្នកដំណាងដែលមកទទួលខ្ញុំ លោកថាគ្មានដឹងថាមានអ្នកដំណើរខ្មែរ ៥ នាក់ ក្រៅពីខ្ញុំឡើយ ព្រោះលោកបានទទួលដំណឹងជាផ្លូវការថាមានតែខ្ញុំម្នាក់ប៉ុណ្ណោះ ។ គណៈប្រតិភូយើងប្រចាំក្រុងព្រៃនគរក៏ពុំបានដឹង គណៈបេសកកម្មអាមេរិកាំងក៏ពុំបានមកទទួល កប៉ាល់ហោះក៏គ្មានកន្លែងទៀត ទាំងនេះជាហេតុបណ្ដាលឲ្យមានការពិបាកជាច្រើនដល់អ្នកដំណើរខាងលើនេះ ។ ទោះបីជាយ៉ាងណាក៏ដោយ លោក ញៀមវ៉ាង បានជួយជ្រោមជ្រែង ពុះពារនឹងការលំបាកនេះ ដោយលោកស្គាល់ភ្នាក់ងាររដ្ឋការ វៀតណាមច្រើនដែលធ្វើការនៅអាកាសស្ថាន ដូចជាខាងគយ ខាងនគរបាល ខាងសន្តិសុខជាតិ ។ល។

ក្រោយពីបំពេញទំរង់សព្វគ្រប់ហើយយើងទាំងអស់គ្នា ក៏ឡើងជិះរថយន្តប្រតិភូយើងប្រចាំប្រទេសវៀតណាម ចេញឆ្ពោះទៅកាន់រដ្ឋធានីព្រៃនគរតែម្ដង ដែលមានចំងាយប្រមាណ ១០ គ-ម ។ នៅក្នុងឡាន អ្នកដំណើរខាងលើនេះរអ៊ូ ខឹងនឹងអាមេរិកាំង ។ ខ្លះពោលថា : “កាលនៅភ្នំពេញស្រួលណាស់ វា (អាមេរិកាំង) រត់ឲ្យយើងទាំងអស់ វាធ្វើសំណុំរឿង វាធ្វើលិខិត



ឆ្លងដែន វាធ្វើនេះ វាធ្វើនោះ ឯងជាសាមីខ្លួនដេកចាំតែពេលចេញដំណើរតែម្ដង ។ ដល់ឡើងផុតលើកប៉ាល់ហោះ វាលែងចោលតែម្ដង សូម្បីតែគណៈបេសកកម្មវាព្រៃនគរ ក៏មិនឲ្យដឹងផង ។ ឯប្រតិភូយើង ក៏មិនបានដឹងដែរ ។ ចៃដន្យបានលោកនេះមក បើគ្មានទេ នោះយើងមិនពិបាកស្លាប់ហើយ ?” ។ ម្នាក់ទៀតឆ្លើយតបវិញថា : “មែនហើយ វាប្រហែសណាស់ វាដោះក្រលុសយើងលែងចោលតែម្ដង អញសឹងតែស្បថហើយក្រោយៗទៀត” ។ មិនយូរប៉ុន្មានរថយន្ត

បានចូលដល់ទីក្រុងព្រៃនគរ ខ្ញុំត្រូវចុះនៅសណ្ឋាគារ ការ៉ាវ៉ែល ឯអ្នកដំណើរ ឯទៀតក៏ទៅសំណាក់នៅសណ្ឋាគារ ផ្សេងទៀតដែរ ។

## នៅសណ្ឋាគារការ៉ាវ៉ែល

សូមជំរាបថា សណ្ឋាគារការ៉ាវ៉ែល ជាសណ្ឋាគារមួយយ៉ាងទំនើបនៅអាស៊ីប៉ែកអគ្នេយ៍ ។ ស្ថាបនាហើយក្នុងរយៈពីរបីឆ្នាំ សណ្ឋាគារ ការ៉ាវ៉ែលសង់ខ្ពស់ត្រដែត មានប្រាំបីជាន់ ទាំងមានចំនួនពីររយបន្ទប់ផ្កាយ ស្អាតសមរម្យ គាក់តែងប្រណិតភាព ។ ម្ចាស់សណ្ឋាគារនេះ បើតាមពត៌មានថា ជាជនជាតិបារាំងម្នាក់ដែលជាអតីតអនុសេនីយឯកកងទ័ពអាណានិគមបារាំង ។

ខ្ញុំសូមអភ័យទោសដោយមិនបានបរិយាយឲ្យបានវែងឆ្ងាយអំពីសណ្ឋាគារដ៏វិចិត្រនេះតែសូមបញ្ជាក់ថា កន្លែងនេះជាទីប្រជុំជននៃមហាសេដ្ឋី



នៃអ្នកនយោបាយ ឬនៃអ្នកយកការណ៍ទាំងអ្នកឆ្លើយឆ្លងខាងពត៌មានអន្តរជាតិ ។ អ្នកទាំងនេះមកដល់ព្រៃនគរ គេមិនទៅណាឆ្ងាយឲ្យផុតពីទីក្រុងទេ ។ គេដេកស៊ី រាំ កំសាន្តតែទៅក្នុងសណ្ឋាគារនេះ ហើយផ្ញើពត៌មានតែផ្ដេសផ្ដាសទៅឲ្យចៅកៃគេ ។ ដេកពួនតែក្នុងសណ្ឋាគារ គេដឹងអស់នូវព្រឹត្តិការណ៍ ដែលមានកើតឡើងក្នុងអាស៊ីប៉ែកអគ្នេយ៍យើងទាំងមូល ។ រឿងនេះមិត្តខ្លះក៏បានជ្រាបស្រាប់ហើយ ។

សូមបញ្ជាក់ទៀតថា អ្នករស់នៅព្រៃនគរ មិនអាចចេញចូលបានឡើយ ពីព្រោះតម្លៃបន្ទប់ក្ដី តម្លៃបរិភោគក្ដី សុទ្ធតែហួសនិស្ស័យគ្នាទាំងអស់ ។

ពេលល្ងាចម៉ោងប្រមាណ ៧ ទឹង ៣០ នាទី ខ្ញុំឡើងទៅទទួលទានបាយនៅជាន់លើបង្អស់ ។ អ្នកបំរើម្នាក់បាននាំខ្ញុំទៅអង្គុយតុមួយម្នាក់ឯង ។ គួរឲ្យភ្ញាក់ខ្លួន–ទៅដល់ទីនោះភ្លាម កន្លែងទទួលទានអាហារនេះស្អាត សមរម្យចេនាទៅវាយពន្លឺភ្លើងទៀនប្រេង លាយឡំទឹងអំពូលតូចៗដាំតាមពិតានគួរឲ្យទស្សនា ។ គេតែងតាមរបៀបសម័យបន្តិច តាមរបៀបយុគកណ្ដាលបន្តិចៗ វង់តន្ត្រីភ្លាំងបានបន្លឺនូវស័ព្ទពិរោះកំដរភ្ញៀវ ។

ថែរមកគៀវវិញ គេឃើញមានសុទ្ធតែជនជាតិអាមេរិកាំង មានចិនតែពីរនាក់និងខ្មែរយើងមួយនាក់(គឺខ្ញុំ) ។ គេអាចនិយាយបានថាដូចជាសហរដ្ឋអាមេរិក បានលើកមកតាំងទី នៅកន្លែងនោះ ។ អ្នកបំរើស្លៀកពាក់តាមរបៀប បានសួរខ្ញុំជាភាសាអង់គ្លេស ឯបញ្ជីរាយឈ្មោះម្ហូប ក៏សរសេរជាភាសាអង់លេះដែរ ។ ខ្ញុំធ្វើហាក់ដូចជាមិនយល់ ស្តាប់មិនបាន ហើយក៏សុំឲ្យយកបញ្ជីម្ហូបសរសេរជាភាសាបារាំង ។ គេក៏យកមកឲ្យខ្ញុំភ្លាម ។ សូមជំរាបថាមិនយូរប៉ុន្មាន ខ្ញុំបានស្គាល់អ្នកបំរើពីរនាក់ ។ គេក៏ដូចជាស្គាល់ចិត្តថ្លើមខ្ញុំភ្លាមៗ ចរន្តទុកចិត្តគ្នាទៅវិញទៅមក ក៏ដូចជាកើតមានឡើងនៅពេលនោះដែរៗគេបាននិយាយ រឿងរ៉ាវរបស់គេប្រាប់ខ្ញុំថា "គេពីដើមរស់នៅប្រទេសខ្មែរដែរ ជាគ្រួសារញាតិសាច់របស់គេសព្វថ្ងៃនៅឯកំពង់ជ្រៃ (ខេត្តតាកែវ) " ។ ម្នាក់ទៀតថា "នៅកំពង់ត្រាំ(ខេត្តកំពត)ថាគេចង់វិលត្រឡប់មករកស៊ីនៅប្រទេសខ្មែរវិញណាស់ ដោយនៅឯវៀតណាមចង្អៀតចង្អល់ណាស់ ថាខ្លួនមិនអាចវិលមកវិញបាន ដោយរដ្ឋការលោក ង៉ោ ឌិញយៀម មិនអនុញ្ញាត ព្រោះគេទាំងនេះមានអាយុត្រូវធ្វើទាហានផង " ។



និយាយពីស្ថានការណ៍នយោបាយ ពួកបំរើទាំងនេះបែបដូចជាអ្នកចេះដឹង អ្នកចេះតាមស្ថានការណ៍របស់ស្រុកទេសខ្លួន ។ គេនិយាយប្រាប់ខ្ញុំអំពីស្ថានការណ៍សឹក អំពីរបបផ្តាច់ការរបស់ប្រធានាធិបតី ង៉ោ ឌិញយៀម ។ គេនិយាយថា "សព្វថ្ងៃទុក្ខវេទនារបស់ប្រជារាស្ត្រទូទៅ មានសភាពរឹតតែខ្លាំងឡើងៗ ដែលជាលទ្ធផលនៃរបបផ្តាច់ការរបស់លោកង៉ោ ឌិញយៀម ។ គេថា គ្រប់អំណាចរដ្ឋត្រូវប្រមូលមកនៅតែដៃលោក ង៉ោ និងញាតិសាច់គេ ដែលសព្វថ្ងៃបានដឹកនាំប្រទេសឲ្យចូលដល់សភាពពាល់ប្រេក ដែលមិនអាចងើបរួចឡើយ ។ កម្លាំងលោក ង៉ោ គឺផ្អែកតែទៅលើកងទ័ពនិងជនកៀសខ្លួនពីខាងជើងមក ។ ឯពួកនេះទៀតសោត គេទុកដូចជាទេវតា គ្មាននរណា

ហ៊ានរករឿងបៀតបៀនបានឡើយ ។ នរណាហ៊ានចោទប្រកាន់ជនកៀសខ្លួននេះ ត្រូវទុកជាអ្នកក្បត់ជាតិ ជាវៀតកុងហើយទទួលទុក្ខយ៉ាងធ្ងន់„ ។ គេថា“សព្វថ្ងៃនេះ ពស្ត្រប្រជាមានសេចក្តីក្តៅក្រហាយនឹងរដ្ឋបាល លោក ង៉ោ ឌិញយៀម ណាស់ ។ កាលរដ្ឋប្រហារខែមេសា ១៩៦១ នេះ គេថាប្រជាជនគ្រប់ជាន់ថ្នាក់នៅព្រៃនគរ បានចេញធ្វើបាតុកម្មប្រឆាំង នឹងរបបផ្តាច់ការរបស់ប្រធានាធិបតី ង៉ោ ហើយគាំទ្រយ៉ាងពេញទំហឹងដល់កម្លាំងបដិវត្តន៍ខាងលើ ។ ប៉ុន្តែសម្រែកស្រេកឃ្លានសិទ្ធិសេរីនេះ បានផ្ទុះចេញតែមួយរយៈយ៉ាងខ្លី ហើយត្រូវគ្រប់សង្កត់សាបសូន្យទៅវិញ ដោយបរាជ័យនៃរដ្ឋប្រហារ„ ដូចមិត្តជ្រាបស្រាប់ ។

អំពីស្ថានការណ៍សឹក អ្នកបំរើដែល បាននិយាយដោយកំហឹងថា : “ពេលថ្ងៃ កងទ័ពង៉ោ ឌិញយៀម ត្រូវប្រជាជនស្នេហាជាតិប្រទេចផ្ដាសា បាញ់សម្លាប់ពប់រយនាក់ ។ ខ្លះទៀតភ្ញាក់សតិសម្បជញ្ញៈ បានរត់ចូលខាងទ័ពរំដោះជាតិ ។ គេនិយាយថា ថ្វីបើទ័ពលោក ង៉ោមានអាវុធពាក់ដល់ធ្មេញគ្រប់បែប គ្រប់ផុន មានកប៉ាល់ហោះ កប៉ាល់សមុទ្រយ៉ាងណាក៏ដោយ ក៏មិនអាចឈ្នះទ័ពប្រជាជនដែលគេតាំងអស់គ្នា ក្រោកឡើងឈរដូចតែមនុស្សម្នាក់ ដើម្បីរំដោះជាតិខ្លួនបានឡើយ ។ គេនិយាយអំពីការប្រតិបត្តិខាងសឹកនៅតំបន់ខ្ពស់ តំបន់រាប កណ្តាល នៅតំបន់ដីសណ្តរមេគង្គ ។ល។”គេនិយាយក្តាប់ដៃមុខឡើងក្រហមដូចជាមានកំហឹងយ៉ាងខ្លាំងៗឃើញដូចនោះខ្ញុំក៏និយាយថា:„កុំនិយាយខ្លាំងពេក តែគេឮ ក្រែងគេចោទថា អ្នកឯងប្រឆាំងនឹងរដ្ឋ„ ។ គាត់ក៏ឆ្លើយមកវិញភ្លាមថា: „កុំភ័យឲ្យសោះលោក ក្នុងចំណោមអ្នកបំរើជិតពីររយនាក់ដែលធ្វើការជាមួយខ្ញុំនៅក្នុងសណ្ឋាគារនេះ សុទ្ធតែប្រឆាំងនឹងរបបផ្តាច់ការនៃអ្នកកាន់អំណាចតាំងអស់” ។ សូមជ្រាបថាអ្នកដែលជូនពត៌មានខ្ញុំខាងលើនេះ គេនិយាយជាភាសាខ្មែរយ៉ាងច្បាស់លាស់ ព្រោះធ្លាប់នៅស្រុកខ្មែរស្រាប់ ។ ឯគ្រួសារគេសព្វថ្ងៃក៏រស់នៅឯកំពង់ជ្រៃ ក្នុងខេត្តតាកែវយើងដែរ ។ ក្រោយពីបរិភោគបាយ ខ្ញុំក៏ចុះមកបន្ទប់ទទួលទានដំណេក ឥតមានចេញទៅណាទៀតឡើយ ។

លុះព្រឹកឡើង ក្រោយពីស្រស់ស្រូបហើយ ខ្ញុំក៏ចុះដើរលេងតាមវិថីធំៗនៅព្រៃនគរ ។ ព្រៃនគរជាទីក្រុងមួយធំ មានប្រជាជនចំនួន ១ លាន

កន្ទុះ មានគ្រឹះស្ថានធំៗ មានវិថីខ្វាត់ខ្វែង បារបរ មានសភាពអ៊ូអរ ។ មានរថក្រុងធំ ទឹងរថតាក់ស៊ីដូចក្តាម ដែលជាការងាយដល់អ្នកធ្វើដំណើរ ។ តែទោះជាយ៉ាងណាក៏ដោយ ក្រៀងគរ គ្មានរម-ណីយភាពដូចរាជធានីភ្នំពេញយើងឡើយ ។ ភ្នំពេញយើងតូចពិតមែន បើប្រៀបធៀបទៅនឹងក្រុងព្រៃនគរ តែភ្នំពេញយើងស្អាតស្អំ ហើយអ្នកដើរកំសាន្តក៏គ្មានការភ័យបារម្ភអ្វីសោះ ។ គេ



អាចនិយាយបានថា ភ្នំពេញជាដុំគុជមួយប្រណិតប្រកបទៅដោយសេចក្តីសុខក្សេមក្សាន្តក្នុងចំណោមកោះទាំងឡាយដែលទើបប្រទះ នឹងការរបះរបើងមិនទាន់ឯក្នុងតំបន់កករល្អក់នេះ ។ ខ្ញុំដើរបណ្តើរមើលទេសភាពបណ្តើរ តែម្នាក់ឯងតាមផ្លូវវិថី ។ មិនយូរប៉ុន្មាន ខ្ញុំឃើញចំណាំងផ្ទាំងនៃភាពយន្តអចិន្ត្រៃយ៍មួយសរសេរជាភាសាអង់គ្លេស ដោយអក្សរធំៗថា BATLTEIN SPACE (ការប្រយុទ្ធក្នុងចក្រវាឡ) ។ ដោយមិនដឹងដើរទៅណាទៀត ខ្ញុំក៏ទិញសំបុត្រចូលមើលនឹងគេ ។ ក្នុងរោងមានមនុស្សកកកុញ ទាំងស្រីទាំងប្រុសទាំងក្មេង ទាំងចាស់ អង្គុយពេញស្ទើរតែគ្មានសល់កៅអីណាមួយឡើយ ។

## រឿង"ប្រយុទ្ធក្នុងចក្រវាឡ,,

ក្នុងរឿងភាពយន្តនេះ គេស្តែងអំពីការប្រយុទ្ធរវាងគ្នាយ៉ាងសំបើមនៅលើព្រះច័ន្ទផង នៅក្នុងចក្រវាឡផង រវាងជនជាតិមួយ ដែលមានឈ្មោះថា ជនជាតិ ណាតាល់ (NATAL) ។ ជនជាតិនេះមានមហិទ្ធិរិទ្ធិខ្លាំងពូកែណាស់ មានមូលដ្ឋានទ័ពនៅលើព្រះច័ន្ទ ហើយមានសុទ្ធតែកាជន៍ហោះ (Soucoupes volantes) ។ តាមផ្ទៃរឿងគេថា ជនជាតិនេះសាហាវណាស់ហើយចង់បង្ក្រាបមនុស្សលោកយើងទាំងមូលដែលរស់នៅ លើដីនេះឲ្យទៅជាទាសារបស់គេ ។ ដើម្បីប្រឆាំងនឹងអំពើវាងលើនេះ មនុស្សលោកយើងទាំងអស់ត្រូវតែរួបរួមគ្នាបង្កើតជារណៈសិរ្សមួយ តទល់វិញយ៉ាងមធ្យ័តទើបគេរួចខ្លួនឲ្យផុតពីទាសភាព របស់សាសន៍ណាតាល់បាន ។

ប្រទេសជប៉ុនជាអ្នកផ្តើមគំនិត បានបង្កើតអាវុធទំនើបៗ ដើម្បីបាញ់កាជន៍ហោះពីព្រោះអាវុធធម្មតា ទោះជាមានលក្ខណៈយ៉ាងណាក៏ដោយ

ក៏ពុំអាចបាញ់ភាជន៍ហោះនេះធ្លុះដែរ ។ គេឃើញមានមហាសន្និបាត មួយយ៉ាងធំសំបើម ដែលនៅក្នុងនោះមានតំណាងគ្រប់ប្រទេស ក្នុងលោកមកចូលប្រជុំ ដើម្បីចាត់វិធានការបង្ការទល់នឹងពួក ណាតាល់ ។



ក្នុងការជួបជុំនេះ ប្រទេសជប៉ុនជាមេ បាននាំអ្នកតំណាងពល់ប្រទេស ឲ្យដើរមើលកាណុង សម្រាប់បាញ់ភាជន៍ហោះ កាំជ្រួចសម្រាប់ហោះឡើងទៅព្រះច័ន្ទ ដើម្បីបំផ្លាញមូលដ្ឋានភាជន៍ហោះ របស់បច្ចាមិត្ត ។ តំណាងគ្រប់ប្រទេស គោតសរសើរអ្នកប្រាជ្ញជប៉ុន លើកដៃ ងក់ក្បាលយល់ស្របតាមគំរោងការណ៍របស់ជប៉ុន ។

សូមជ្រាបថា មិនដឹងជាកលល្បិចក្រលុកក្រលៀតរឿងគេយ៉ាងដូចម្ដេចទេ ស្រាប់តែឃើញពលស៊ីបេរី (SIBE RIE)(សហភាពសូវៀត) ហើយនឹងតិចហ្សាស (TFXAS) (សហរដ្ឋអាមេរិក) ។ នៅលើដំបន់តាំងពីរខាងលើនេះ គេឃើញសុទ្ធតែមូលដ្ឋានភាជន៍ហោះ (នៅស៊ីបេរី) នឹងមូលដ្ឋាននៃកាំជ្រួច (នៅតិចហ្សាស) ។

ឯការប្រយុទ្ធគ្នាក៏កើតមានឡើង រវាងភាជន៍ហោះនឹងកាំជ្រួចហោះ ។ តោះបីភាជន៍ហោះពូកែស័ក្តិសិទ្ធិយ៉ាងណាក៏ដោយ ទីចុងក្រោយបំផុត គេឃើញពួកខាងកាំជ្រួច ហោះឈ្នះក្នុងការប្រយុទ្ធនេះ តែទីក្រុងតាំងឡាយ មានទីក្រុងញូវយ៉កជាដើម ហិនហោចអស់ ។

ក្នុងផ្ទៃរឿងតាំងមូល គេឃើញយ៉ាងច្បាស់ថា ជាការឃោសនាបំពាក់អាវុធប្រឆាំងនឹងកុម្មុនីសទៅវិញ ។ ខ្ញុំគិតហើយចេះតែងល់ក្នុងចិត្តថា ប្រទេសជប៉ុនដែលទទួលរងគ្រោះយ៉ាងសំបើមមុនគេអំពីគ្រាប់បែកបរមាណូ ដែលបំផ្លាញទីក្រុង ហេរ៉ូស៊ីម៉ា កាលថ្ងៃទី ៦ សីហា ១៩៤៥ បែរធ្វើជាអ្នកដើមគំនិតប្រណាំងប្រជែងបំពាក់អាវុធ ដើម្បីនាំលោកឲ្យចូលក្នុងសង្គ្រាមទី ៣ទៅវិញ ។ ខ្សែភាពយន្តតាំងមូលធ្វើឲ្យខ្ញុំចាប់

អារម្មណ៍ជាច្រើន ៗ ឯមនុស្សមើលដូចគ្នា ខ្ញុំពុំឃើញមានទឹកមុខរីករាយសប្បាយកំសាន្តនឹងរឿងខាងលើនេះទេ ពិសេសព្រោះគេទាំងនោះសុទ្ធតែបានស្គាល់សង្គ្រាមពីឆ្នាំ ១៩៤២ រហូតមកដល់សព្វថ្ងៃនេះ ហើយសង្គ្រាមនេះក៏ពុំទាន់ចប់ផង ៗ

ចេញពីរោងភាពយន្ត ខ្ញុំសំដៅទៅផ្ទះសំណាក់ ទទួលទានបាយ ហើយរៀបចំហិបស្បៀកពាក់ ដើម្បីធ្វើដំណើរតទៅទៀត ៗ

ពីរម៉ោងក្រោយមក យន្តអាកាស អ៊ែហ្វ្រង់ បាននាំខ្ញុំនិងអ្នកដំណើរឆ្ពោះទៅប្រទេសហ្វីលីពីន ៗ មិនយូរប៉ុន្មានខ្ញុំទៅដល់អាកាសយានដ្ឋានអន្តរជាតិនៅម៉ានីលនៅម៉ោង ១៦ និង ៣០ នាទី (ម៉ោងភ្នំពេញ) ៗ យន្តហោះនេះត្រូវសំចតតែមួយម៉ោងទេ ហើយត្រូវបន្តដំណើរតទៅទៀត ៗ ខ្ញុំត្រូវទៅដល់តូក្យូនៅថ្ងៃ១៥កញ្ញា ៗ ព្រោះការបើកសម័យប្រជុំត្រូវធ្វើនៅថ្ងៃទី ១៦ កញ្ញា ៗ ឯគណៈប្រតិភូប្រទេសឯទៀត មានគណៈប្រតិភូប្រទេសអៀរឡង់ ប្រទេសបៃជាដើម ក៏ធ្វើដំណើរជាមួយខ្ញុំដែរ ៗ

បន្តិចក្រោយមក យើងទាំងអស់គ្នា (អ្នកធ្វើដំណើរទាំងអស់) បានទទួលដំណឹងថា កប៉ាល់ហោះមិនអាចធ្វើដំណើរទៅទៀតបានទេ ព្រោះមានខ្យល់ព្យុះយ៉ាងធំ ៗ ខ្ញុំស្មានថាការខកខានតែពីរឬបីម៉ោងប៉ុណ្ណោះទេ តែផ្ទុយទៅវិញ ខ្ញុំត្រូវដេកនៅម៉ានីលអស់ពីរយប់ ដោយម្យ៉ាងកប៉ាល់ហោះដែលខ្ញុំជិះនោះត្រូវវិលត្រឡប់ថយក្រោយវិញ ហើយដោយម្យ៉ាងទៀតត្រូវចាំដើងកប៉ាល់ហោះមួយទៀតដែលត្រូវចេញពីអាកាសយានដ្ឋាន ម៉ានីល នៅយប់ថ្ងៃអាទិត្យពេលម៉ោងមួយនិង ៣០ នាទីភ្លឺ ៗ ខ្ញុំត្រូវទៅសំណាក់ នៅសណ្ឋាគារម៉ានីឡា ជាមួយនឹងអ្នកដំណើរទាំងអស់ ៗ ជាឱកាសមួយល្អដែរ ព្រោះខ្ញុំអាចស្គាល់ទីក្រុង ម៉ានីល ខ្លះៗ តែគួរឲ្យបារម្ភដែរ ព្រោះណាមួយខ្ញុំគ្មានលុយមួយសេន (មានតែឆែក chèque ចាយមិនបាន) ណាមួយខ្ញុំពុំបានទៅឲ្យទាន់នៅពេល ដែលគេបើកសម័យប្រជុំ ៗ តែទោះចង់ឬមិនចង់ក្តី ខ្ញុំត្រូវតែសំណាក់នៅម៉ានីលអស់ជិតពីរថ្ងៃ ៗ

(នៅមានត)




សមាគមសាស្ត្រាចារ្យខ្មែរ

---

លេខ១៣

---

# ញត្តិសមាគមសាស្ត្រាចារ្យ

សូមព្រះតេជៈជំកល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលថ្វាយសម្ដេចព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ,

ដោយបានឮតាមវិទ្យុជាតិ នូវសេចក្ដីសំបុត្រអនាមិកមួយ ដែលថ្វាយចំពោះព្រះអង្គដើម្បីសើរើពីរឿងបោះប្រជាមតិឡើងវិញ, ដោយសំបុត្រនេះសំអាងទៅលើអ្នកបច្ចេកទេសខាងសិក្សាដែលជាហេតុនាំឲ្យប៉ះពាល់ដល់គ្រូនឹងសាស្ត្រាចារ្យទូទៅ ,

ទូលព្រះបង្គំទាំងឡាយជាសមាជិកសមាគមសាស្ត្រាចារ្យ សូមបញ្ជាក់ថ្វាយសម្ដេចជាទីគោរពនឹងជាទីស្នេហាថា ពិតមែនតែទូលព្រះបង្គំទាំងឡាយស្រឡាញ់វិស្សមកាលរបៀបថ្មីក៏ដោយ ទូលព្រះបង្គំទទួលសារភាពគោរពមតិភាគច្រើន ដែលចេញពីប្រជាជាតិយើងជានិច្ច សមទៅតាមលទ្ធិប្រជាធិបតេយ្យៗ ម្យ៉ាងទៀត តាំងពីសមាជជាតិរួបមក ទូលព្រះបង្គំទាំងឡាយមិន

ដែលកើតកាយរឿងប្រជាមតិមកចោទឡើងវិញទេ ព្រោះគោរព
តាមដំបូន្មានព្រះបិតាជាតិ ដែលទ្រង់បានហាមប្រាមក្នុងសមាជ
ជាតិថាឲ្យបញ្ចប់រឿងវិស្សមកាល ត្រឹមនោះចុះ កុំឲ្យមានការ
ជជែកបែកខ្ញែកគ្នាតទៅទៀត ។

អាស្រ័យហេតុនេះ ទូលព្រះបង្គំទាំងឡាយឈឺចាប់ឥត
ឧបមាទីជនទុច្ចរិតដែលធ្វើសំបុត្រអនាមិកនេះ ក្នុងគោលបំណង
តែម្យ៉ាង គឺបង្កើតអធិករណ៍ឲ្យមានបរិយាកាសឆោឡោបែក
បាក់សាមគ្គីគ្នា ក្នុងរឿងមួយដែលចប់ទៅហើយ ។

សូមសម្តេចព្រះបិតាជាតិ ទ្រង់បដិសេធចោលសំបុត្រ
អនាមិកដ៏កំសាកនោះទុកជាអសារឥតការ ហើយសូមទ្រង់
កុំលែងនាវាកម្ពុជាចោលទៅតាមយថាកម្មឲ្យសោះ ដោយ
ព្រះទ័យសន្តោសដល់អនាគតប្រជាជាតិខ្មែរ ។ ទូលព្រះបង្គំ
ទាំងឡាយជាសាស្ត្រាចារ្យ សូមប្តេជ្ញាដង្ហែព្រះអង្គជានិច្ច
ក្នុងពេលលំបាកក៏ដូចក្នុងពេលសប្បាយ ដោយរក្សាស្វាមីភក្តិ
យ៉ាងជ្រាលជ្រៅចំពោះព្រះអង្គ ។

សូមក្រាបបង្គំទូលថ្វាយនៅថ្ងៃ ទី ១៨ មករា ១៩៦២

គណៈកម្មាធិការនាយកសមាគមសាស្ត្រាចារ្យ

## ជុំវិញការផ្លាស់លោក ទីវ អុល

យើងទើបនឹងបានទទួលសំបុត្រមួយច្បាប់ របស់លោក ទីវ អុល ដែលសុំឲ្យយើងចុះផ្សាយជូនក្នុងទស្សនាវដ្ដីលេខនេះ ។ តបនឹងសេចក្ដីស្នើសុំរបស់លោក យើងមានសេចក្ដីរីករាយនឹងចុះផ្សាយនូវសំបុត្រនោះ ដែលគេអាចអានអត្ថបទទាំងស្រុង នៅខាងក្រោមនេះ ៖

ភ្នំពេញ, ថ្ងៃ ១៥ មករា ១៩៦២

សូមគោរពលោកប្រធាន,

សូមលោកមេត្តាចុះផ្សាយសំបុត្ររបស់ខ្ញុំទាំងស្រុង ក្នុងទស្សនាវដ្ដីសាស្ត្រាចារ្យលេខនេះ ដើម្បីខ្ញុំអាចសំដែងអំណរគុណរបស់ខ្ញុំ ចំពោះបណ្ដាមិត្ត ដែលបានឈឺចាប់ចំពោះរឿងខ្ញុំ ។

មកដល់អស់មិត្ត,

តាមរយៈទស្សនាវដ្ដីដ៏រមទមរបស់យើងនេះ ខ្ញុំសូមស្រែកថ្លែងដោយអស់ពីដួងចិត្ត នូវអំណរគុណយ៉ាងខ្លាំងក្លានិងកតញ្ញូតាយ៉ាងជ្រាលជ្រៅរបស់ខ្ញុំ ចំពោះអស់មិត្តជាទីស្នេហានិងជាទីគោរពទាំងឡាយ ដែលទើបនឹងបានបង្ហាញភស្តុតាង នៃការឈឺចាប់របស់ខ្លួនចំពោះរូបខ្ញុំ ។ ស្មារតីឈឺចាប់ជាសាច់មួយនេះ ក៏ដូចជាកាយវិការដ៏ថ្លៃថ្លារបស់កល្យាណមិត្ត ជាវិភាគទានមួយយ៉ាងសំខាន់បំផុត ដល់ការរំលាយសេចក្ដីសៅហ្មងចិត្តរបស់ខ្ញុំអស់មួយភាគធំ ហើយថែមទាំងលើកទឹកចិត្តខ្ញុំ បានមួយកំរិតខ្ពស់ទៀតផង ។ ដូចនេះហើយ បានជាមនោសញ្ចេតនាដ៏ឧត្តុង្គឧត្តម និងកាយវិការជាភាតរភាពនេះរបស់មិត្ត បានធ្វើឲ្យខ្ញុំមានសេចក្ដីរំភើប ហើយព្រឺព្រួចយ៉ាងក្រៃលែង ។ ឯអំណរគុណ និងបដិការគុណរបស់ខ្ញុំចំពោះអស់មិត្តវិញ, និយាយម្ដងហើយម្ដងទៀត, នោះមិនអាចនឹងរកគុណនាមឯណា មកដាក់ឲ្យសមបានឡើយ ។

កតញ្ញូតាហើយនិងអំណរគុណរបស់ខ្ញុំនេះ ខ្ញុំសូមបញ្ជូនទៅដល់បណ្ដាមិត្តទាំងអស់ ដែលបានសរសេរសំបុត្រជាឯកជនមកខ្ញុំក្ដី ដែលបានមកសួរសុខទុក្ខខ្ញុំដោយផ្ទាល់មាត់ក្ដី, ឬដែលបានសំដែងសមានចិត្តនិងសាមគ្គីភាពតាមផ្លូវចិត្តក្ដី ហើយជាពិសេស គឺទៅដល់បណ្ដាមិត្តសាស្ត្រាចារ្យ ទាំង ១៤ រូបនៅវិទ្យាល័យព្រះស៊ីហនុ, ២៥រូបនៅអនុវិទ្យាល័យស្ទឹង (កំពង់ចាម), ១៣រូបនៅវិទ្យាល័យសុរិយាវង្សទី២ (សៀមរាប) ៩រូបនៅអនុវិទ្យាល័យព្រះអង្គឌួង (ព្រៃវែង) និង២២រូបនៅអនុវិទ្យាល័យព្រះសោមា (ព្រៃល្វា) ដែលបានមូលមតិគ្នាសំដែងការឈឺចាប់របស់ខ្លួន តាមលិខិតរួម ផ្ញើមកគណៈកម្មាធិការនាយកនៃសមាគម ។

មិត្តជាទីស្នេហានិងជាទីគោរព,

ក្នុងឱកាសនេះ ដែលខ្ញុំបានធូរចិត្តបន្តិចដោយការឧបត្ថម្ភ យ៉ាងមុឹងមាំនិងយ៉ាងខ្ជាប់ខ្ជួនរបស់មិត្ត ខ្ញុំក៏អាចសង្កេតឃើញមួយចំណែកទៀតថា គ្រួសារសាស្ត្រាចារ្យខ្មែរយើង ដែលពីមុននេះមានសមាជិកតែមួយក្ដាប់ ថ្ងៃនេះបានកើនឡើងជាខ្លាំង ទាំងខាងបរិមាណ ទាំងខាងគុណភាព ហើយពោរពេញទៅដោយស្មារតីជួយសង្គ្រោះគ្នា ស្មារតីមិត្តភាព សាមគ្គីភាព និងភាតរភាព ។ តទៅអនាគត ខ្ញុំហ៊ានសង្ឃឹមថាសមាគមរបស់យើង និងនៅតែរីកលូតលាស់ដូចនេះជាស្ថាពរដរាបរៀងទៅ ហើយកាន់តែបានរឹងប៉ឹងឡើងៗថែមទៀតជាលំដាប់ ។

ជាថ្មីម្ដងទៀត សូមមិត្តទទួលដោយរីករាយក្នុងទីនេះ នូវអំណរគុណដ៏ខ្លាំងក្លា និងកតញ្ញូធម៌ដ៏ស្មោះស្ម័គ្រពីសហសេវិកម្នាក់ ដែលគ្មានមួយវេលាណាអាចនឹងភ្លេចកាយវិការដ៏ថ្លៃថ្លារបស់អស់មិត្តបានឡើយ ។

ដោយមេត្រីភាព

ឌីវ អុល

# សេចក្តីថ្លែងអំណរគុណ

បន្ទាប់ពីបានដំណឹងថា មិត្ត លាង ហាប់អាន នឹងគ្រួសារបានរងទុក្ខជាទំងន់ ដោយគេហស្ថានព្រមទាំងទ្រព្យសម្បត្តិ បានធ្លាក់ជាចំណីភ្លើងអស់ហើយ គណកម្មាធិការនាយកបានសំរេចជួយឧបត្ថម្ភនូវវិភាគទានពីរពាន់រៀល ។ ខាងក្រោមនេះ ជាសំបុត្រអំណរគុណរបស់មិត្ត លាង ហាប់អាន ។

*សូមជំរាបលោកប្រធាន សមាគមសាស្ត្រាចារ្យខ្មែរ*

*សូមជ្រាប*

លោកប្រធាន ,

*ខ្ញុំព្រមទាំងគ្រួសារ សូមថ្លែងនូវសេចក្តីអំណរដ៏រំភើប ចំពោះសប្បុរសធម៌ដែលលោកប្រធានតំណាងក្រុមអភិបាលនិងសមាជិកទាំងអស់នៃសមាគមសាស្ត្រាចារ្យខ្មែរ ដែលបានសំរេចធ្វើអំណោយជាប្រាក់ចំនួនពីរពាន់រៀល (២០០០៛០០) ដល់គ្រួសារខ្ញុំ នៅពេលទទួលរងគ្រោះថ្នាក់ភ្លើងឆេះផ្ទះព្រមទាំងទ្រព្យសម្បត្តិ នៅភូមិឃុំវាំងវែងសង្កាត់លេខ ៣– ក្រុង កាលពីរាត្រីថ្ងៃអាទិត្យទី ៤ខែកុម្ភៈ ១៩៦១ នេះ ។*

*អំណោយជាសង្គហទានដ៏វិសេសបែបនេះ ព្រមទាំងទឹកចិត្តឈឺឆ្អាលដែលលោកប្រធាន លោកអគ្គលេខាធិការនិងអស់លោក-អ្នកជាមិត្ត បានអញ្ជើញមកសាកសួរសុខទុក្ខផ្ទាល់របស់ខ្ញុំដល់ទីកន្លែងរងគ្រោះនោះ គឺជាភាគទានយ៉ាងសំខាន់រកគ្មាន ក្នុងការជួយសំរាលក្តីសោកស្តាយនិងការអស់សង្ឃឹមរបស់ខ្ញុំនិងគ្រួសារ ធ្វើឲ្យមានកម្លាំងកាយនិងចិត្តកសាងជីវភាពថ្មីឡើងវិញ ហើយម្យ៉ាងទៀតឧត្តមកិច្ចបែបនេះបញ្ជាក់ជាថ្មីថែមទៀត នូវនិមិត្តរូបនៃសាមគ្គីភាពជាធ្លុងមួយ និងសេចក្តីសន្តោសយោគយល់គ្នានិងមិត្តភាពដែលពុំអាចបំភ្លេចបាន ។*

ដើម្បីតបស្នងសងគុណលោកប្រធាន អស់លោកអ្នកទាំងអស់ ខ្ញុំព្រមទាំងគ្រួសារ សូមប្រសិទ្ធិពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងសូមជូនកុសលពសី តាមសេចក្តីប្រាថ្នារបស់លោក-អ្នក ឲ្យសម្រេចតាមការអធិដ្ឋានផ្ទាល់ៗខ្លួន ៗ

សូមលោកប្រធានទទួលនូវសេចក្តីគោរព និងនូវអំណរជាថ្មីរបស់ខ្ញុំនិងគ្រួសារ ហើយសូមមេត្តាផ្សាយសេចក្តីថ្លែងអំណរគុណនេះ ជូនចំពោះអស់ លោក-អ្នក ជាកល្យាណមិត្តឲ្យបានដោយអនុគ្រោះ ៗ

ភ្នំពេញ , ថ្ងៃទី ៨ កុម្ភៈ ១៩៦២

លាង-ហាប់អាន

សាស្ត្រាចារ្យខាងភាសាខ្មែរ

## សេចក្តីអំពាវនាវ

មិត្តទាំងឡាយ,

គិតមកត្រឹមពេលនេះ ទស្សនាវដ្តីយើងចេញបានប្រាំមួយលេខហើយ ៗ ប៉ុន្តែមុននឹងចេញបានមួយលេខៗ យើងមានការលំបាកច្រើន ដោយខ្វះខាតអត្ថបទ ៗ

ដូចនេះ ដើម្បីសំរួលដំណើរទស្សនាវដ្តីយើង យើងសូមអំពាវនាវឲ្យមិត្តជួយសរសេរឲ្យបានកុះករបន្តិចឡើង ៗ ធ្លៀតឱកាសនេះ យើងសូមថ្លែងអំណរគុណដល់អស់មិត្ត ឈ័រ គិមហុង ម៉ៃ លន់ និង គិម ស៊ីយ៉ង់ ដែលបានផ្ញើអត្ថបទមកយើងមុនគេ ដោយវិជ្ជមាន ។

យើងសូមរង់ចាំកាយវិការរបស់មិត្តឯទៀតៗ ដោយសង្ឃឹម!

គណៈកម្មាធិការ និពន្ធ

# កីឡា & ល្បែង

## ខ្មែរយើងចូលប្រកួតកីឡាអន្តរជាតិ លើកទី ១

ដូចជាអង្គការកីឡាអន្តរជាតិនានា កីឡាសំរាប់ឧបទ្វីបអាស៊ីភាគអាគ្នេយ៍ឈ្មោះ "ស៊ីបគេម" (SEAP GAMES) ក៏មានគោលបំណងចង់បង្រួបបង្រួមមនុស្សដែលមានសញ្ជាតិ និងពណ៌សំបុរខុសគ្នាឲ្យចេះយោគយល់អាធ្យាស្រ័យគ្នា ដើម្បីកសាងសន្តិភាពសាកលលោកផង ។

អង្គការកីឡានេះ មានសមាជិកទាំងអស់ ៧ប្រទេសគឺ ភូមា កម្ពុជា លាវ ម៉ាឡាយូ សិង្ហបូរី ថៃ និងវៀតណាម កីឡានេះបានចាប់បើកឆាកដំបូងបង្អស់ នៅក្រុងបាងកកនាប្រទេសថៃ ។ ក៏ប៉ុន្តែកាលនោះ យើងនៅចាំបាននៅឡើយ ថាប្រទេសកម្ពុជាយើងពុំបានចូលរួមទេ ដោយសារគ្មានការធានារ៉ាប់រងចំពោះសន្តិសុខ ពីរដ្ឋាភិបាលលោកសារិតថាណារ៉ាត់តែប៉ុណ្ណោះ ។ ហេតុនេះ ទើបត្រូវតែនៅទីក្រុងរ៉ង់គូនជាការរៀបចំ "កីឡាស៊ីបគេម" លើកទី២ ក៏ប៉ុន្តែជាការចូលរួមលើកទី១ របស់អ្នកកីឡាខ្មែរយើង ។ គឺជាការគួរឲ្យស្តាយមួយដែរ ព្រោះខកមួយលើក ខ្មែរយើងត្រូវខាតការពិសោធន៍អស់មិនតិចទេ ។

កីឡា "ស៊ីបគេម" (SEAP GAMES) លើកទី២បានឧប្បត្តិកកើតឡើងនៅទីក្រុងរ៉ង់គូន នៃប្រទេសភូមា ចាប់ពីថ្ងៃ ១១ ដល់ ១៦ ធ្នូ ១៩៦១ ។ ក្នុងចំណោមកីឡា ១៥មុខដែលត្រូវបើកឲ្យប្រកួត ខ្មែរយើងបានចូលប្រឡង ១១មុខ គឺនៅខ្វះតែប្រឡងបាញ់ វាយបាល់ហុកគេ ( Hockey ) លើកទំងន់ និងទូកក្តោងទេ ដែលខ្មែរយើងពុំមាន ។

លទ្ធផលរបស់អ្នកកីឡាខ្មែរយើង មានដូចតទៅនេះ

១- អត្តពលកម្ម

( ខ្មែរយើងបានលទ្ធផលខ្សោយ--ហាត់ស្បើយ )

ក-លោក លុកឃិន បានលេខ ៤ ក្នុងការរត់ផ្លោះរបងចំងាយ៤០០ម

ខ-លោក ប៉ែន-សិត បានលេខ៥ ខាងបោល

ទម្ងន់

គ- លោក ប៉ែន សិត បានលេខ ៦ ខាងរបាលថាស

២- វាយសី

-លោក ស្វែម៉ាន់ (វាយម្នាក់) បានមេដៃប្រាក់

៣- បាល់បោះ

-បានលេខផ្តាច់ព្រ័ត្រជាមួយថៃ (ចាញ់ថៃ ១២ពិន្ទុ)

៤- ប្រដាល់

- លោក យូជិនហុង លេខ១ (មេដៃមាស)
- លោក សុន-សាពត់លេខ២ (មេដៃប្រាក់)
- លោកលួន-ង៉ួន លេខ២ (មេដៃប្រាក់)
- លោកសុខ-ថៃលលេខ៣ (មេដៃសំរិត)

៥-ប្រណាំងកង់

- លោក ប៊ុន-ជីយ លេខ២ (មេដៃប្រាក់)

៦- បាល់ទាត់

ចាញ់ដើមទី (ត្រូវលេងជាមួយពួកដើងឯក គឺភូមាម៉ាឡាយូ)

៧-ប្រណាំងទូកអុំ

មួយក្រុមបានលេខ២ (មេដៃប្រាក់)

-មួយក្រុមទៀតលេខ៣ (មេដៃសំរិត)

៨- ប្រណាំងហែលទឹក

(អត់បានមេដៃ-ក្រុមអ្នកហែលទឹកយើងក្មេងៗពេក ហើយហាត់ស៊ើយផង)



៩- តីង់ប៉ុង

- បានលេខ៣ (មេដៃសំរិត)

១០- វាយបាល់តិចនីស

- បានលេខ៤

១១- បាល់ទះ

ចាញ់សៀមតែ២គ្រាប់ទេ

តាមការចាប់ថ្នាក់ខ្លះៗយើងឃើញៈ

ក-) ផ្នែកបាល់បោះ

លេខ១- ថៃ

លេខ២- ខ្មែរ

ខ-) ផ្នែកប្រណាំងកង់

លេខ១- វៀតណាម

លេខ២- ខ្មែរ

លេខ៣- ថៃ

គ-) ផ្នែកបាល់ទះ

លេខ១- ភូមា

លេខ២- ថៃ

លេខ៣- ខ្មែរ

ឃ–) ផ្នែកពីងប៉ុង

លេខ១- វៀតណាម

លេខ២- សិង្ហបូរី

លេខ៣- ខ្មែរ

តាមលទ្ធផលខាងលើនេះ ឃើញថាសមត្ថភាពរបស់អ្នកកីឡាខ្មែរយើង មានកំរិតគួរសមដែរ ព្រោះក្នុងកីឡា ១១ មុខ ដែលយើងចូលប្រកួត មានកីឡា៧ មុខដែលបានជាប់ក្នុងការចាប់ថ្នាក់ ។ ម្យ៉ាងទៀត ចំពោះជំហានទី១បានលទ្ធផលប៉ុណ្ណឹងក៏ល្មមជាការពេញចិត្តដែរ ។

ដោយជាតិខ្មែរជាជាតិធ្លាប់ តស៊ូស៊ុតស៊ាញមួយដែរ យើងសង្ឃឹមថា អ្នកកីឡាខ្មែរយើងនឹងខំប្រឹងប្រែងព្យាយាមតស៊ូយ៉ាងអត់ធ្មត់បំផុត ដើម្បីនឹងលើកតម្កើងជាតិរបស់ខ្លួន បង្ហាញសាកលលោកក្នុងឱកាសពិធីសម្ពោធ កីឡាស៊ុបគេម (SAEP GAMES) លើកទី៣ ដែលនឹងបើកធ្វើនៅឆ្នាំ១៩៦៣ ក្នុងប្រទេសកម្ពុជាយើងនេះ ។

ខែក-ប៊ុន

និស្សិត-សាស្ត្រាចារ្យ-



## ល្បែងៈ ពាក្យបណ្តាំ

បើមិត្តប្រែរូបនិមួយៗក្នុងក្រឡានេះ ជាពាក្យទៅវិញ មិត្តនឹងបានជាសេចក្តីមួយឃ្លានៅក្នុងច្បាប់កូនចៅ ។

ចម្លើយនៅទំព័រ៥២



# ជីវភាពមិត្តយើង

## ដំណឹងខ្លីៗ

កាលពីយប់ថ្ងៃ ៤ កុម្ភៈ ១៩៦២ នេះមិត្ត **លាង ហាប់អាន** នឹងគ្រួសារ បានទទួលរងគ្រោះថ្នាក់មួយជាទំនងបណ្ដាលមកពីអគ្គីភ័យដែលមកឆេះឆាបកំទេចអស់គេហដ្ឋានរបស់ខ្លួនព្រមទាំងគ្រឿងសម្ភារៈទាំងអស់ដែលមាននៅក្នុងនោះ ។

ចំពោះព្រឹត្តិការណ៍ដ៏ឈឺចាប់ខ្លោចផ្សារនេះ យើងបានដំណឹងថា គណៈកម្មាធិការនាយករបស់យើងបានសំរេចធ្វើវិភាគទានផ្ទាល់ចំនួន២០០០រៀល ព្រមទាំងបានអំពាវនាវដល់សមាជិកសមាគម ឲ្យជួយឧបត្ថម្ភថែមទៀតហើយ ។ គណៈកម្មាធិការនិពន្ធសូមចូលរំលែកទុក្ខ នឹងសេចក្ដីឈឺចាប់ពីមិត្ត លាង ហាប់អាន នឹងគ្រួសារ ។

★

លោក **តុង តុន** បានធ្វើដំណើរទៅប្រទេសបារាំង ដើម្បីនឹងប្រឡងមហាបរិញ្ញាប័ត្រខាងច្បាប់ ។ យើងសូមប្រសិទ្ធពរជូនលោក សូមឲ្យលោកបានសំរេចជោគជ័យជាអតិបរមា ក្នុងការប្រឡងនេះ ដើម្បីឲ្យលោកបានជួយការសិក្សាជាតិយើងឲ្យរឹតតែវិសេសវិសាលថែមទៀត ។

★

មិត្ត **អ៊ុង គីមសេង** បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងនាងកញ្ញា **តាន់ ហុងម៉េង** កាលពីខែ តុលា ១៩៥១ នៅភ្នំពេញ ។ នៅឱកាសដ៏រីករាយនោះ យើងបានសង្កេតឃើញមិត្តសាស្ត្រាចារ្យមួយចំនួនធំ មកពីខេត្រក្រៅនឹងក្នុងរាជធានីបានទៅរួបរួមយ៉ាងសកម្មនឹងដោយសោមនស្សចេតនា ។

★

កាលពីថ្ងៃ ១០ កុម្ភៈ ១៩៦២ នេះ មិត្ត **ព្រហ្ម នួនថុល** បានរៀបអាពាហ៍ជាមួយនឹងកញ្ញា **ឃឹម សារាត** (បង្រៀននៅវិទ្យាល័យព្រះស៊ីហនុ) នៅកំពង់ចាម ។

ចំពោះគូស្វាមីភរិយាថ្មីទាំងពីរខាងលើនេះ យើងសូមប្រសិទ្ធិពរជូន សូមបានប្រកបតែដោយសេចក្ដីសុខចំរើនជាដរាបរៀងទៅ ។

ចម្លើយនៃល្បែង ទំព័រ ៥១

លោកជាភ្ញើងក្ដី មែនពិតមោះឬ ពុំស្ទុំស៊ុំយា

# អំពីសៀវភៅ

ដើម្បីផ្តល់វិភាគទាន ដល់ការពង្រីកព្រំដែនវប្បធម៌ទូទៅ និងវប្បធម៌វិជ្ជាជីវៈរបស់មិត្ត មិត្តគួរអានសៀវភៅនិងទស្សនាវដ្តី ដែលយើងបានជ្រើសរើសសំរាប់មិត្ត ដូចតទៅនេះ៖

## ទស្សនាវដ្តីគ្រូបង្រៀន

របស់សមាគមបុគ្គលិកសិក្សាខ្មែរ

ទស្សនាវដ្តីនេះបានចេញ៤លេខហើយ ។

ទស្សនាវដ្តីនេះ ក្រៅពីចោទបញ្ហា ជាក់ស្តែងដ៏មានខ្លឹមសារសំខាន់ៗ មួយចំនួន ក្នុងវិស័យចិត្តសាស្ត្រ និងគរុកោសល្យ នៅបានបង្ហាញទៀតនូវស្ថានភាពជីវភាព នៃសហសេវិកគ្រូរបស់យើង ហើយនិងការទាមទាររបស់គេ ។ ឯបញ្ហាសិទ្ធិសេរីភាពគ្រូ ក្នុងការធានាអះអាងសន្តិសុខរបស់ខ្លួន ព្រមទាំងវប្បធម៌ទូទៅ និងបញ្ហាផ្សេងៗ ដទៃទៀត ក៏មានចោទដែរ ។

ទស្សនាវដ្តីផ្សាយចេញរាល់ខែមាស ១លេខ ៨រ០០

សមាជិកទទួលលក់ៈលឹម លាងដិន វិទ្យាស្ថានជាតិគរុកោសល្យ

★

## ថាមពលបរមាណូ

ដោយលោក គាត ឈន់

វិស្វករ ទេពកោសល្យខាងសមុទ្រនិង
វិស្វករទេពកោសល្យបរមាណូ

នៅក្នុងសតវត្សបរមាណូដែលយើងកំពុងរស់នៅសព្វថ្ងៃនេះ បញ្ហាបរមាណូបានរលាយចូលជាសាច់មួយក្នុងបញ្ហាសុភមង្គល និងបញ្ហាមហាវិនាសកម្មរបស់មនុស្សជាតិទៅហើយ ! ហើយបញ្ហានេះបានឋិតនៅជាបញ្ហាបច្ចុប្បន្នភាពជាដរាប ដែលអ្នកប្រាជ្ញនិងអ្នកនយោបាយសាកលលោកកំពុងខ្វាយខ្វល់ជាពិសេសគ្រប់ៗគ្នា ។

ដូចនេះ បើមិត្តចង់ដឹងថាអ្វីទៅដែលហៅថាអាតូម? វាមានសមាសភាពយ៉ាងណា? តើណ្យូយ៉ូវាយ៉ាងណាដែរ? ចុះអ្វីទៅជាគេទនៃវិទ្យុសកម្ម? ហើយអ្វីដែលហៅថាអ៊ីសូតូប? ថាមពល (énergie) និងរូបធាតុ (matière) យ៉ាងណា? – សមីការ

(équation) នៃអ្នកប្រាជ្ញ អាញស្តាញ និងឡង់ហ្សឺវ៉ាំង ។ តើគេរំដោះថាមពលនៃអាតូមតាមយន្តនិយម (mécanisme) ណា ? អាតូមមានផលប្រយោជន៍យ៉ាងណាខ្លះទៅ ? ហើយមហន្តរាយរបស់វា (គ្រាប់បែកអាតូមិក, ហ៊ីដ្រូសែន) យ៉ាងណាដែរ ?

បញ្ហាអស់ទាំងនេះ លោកវិសូករ គាត ឈន់ នឹងដោះស្រាយជូនមិត្តយ៉ាងក្បោះក្បាយ ហើយវិចិត្រទៅដោយគំនូសពន្យល់ទៀតផង នៅក្នុងសៀវភៅ ថាមពលបរមាណូ ។

មួយក្បាល ១៥៛០០

មានលក់នៅ ទីស្នាក់ការ នៃសមាគមសិស្សចាស់វិទ្យាល័យស៊ីសុវត្ថិ ខាងជើងជាប់នឹងវិទ្យាស្ថានជាតិគរុកោសល្យ, ភ្នំពេញ

★

## វិប្បធម៌និងគ្រូបង្រៀន

ដោយលោក ទីវ អុល

ដែលយើងបានដកស្រង់ផ្សាយខ្លះៗមកហើយ ក្នុងទស្សនាវដ្ដីលេខ១, ២, ៣, របស់យើងនេះ ហើយដែលអធិប្បាយពីបេសកកម្ម នឹងការទទួលខុសត្រូវរបស់អ្នកអប់រំពីវប្បធម៌ទូទៅរបស់គ្រូបង្រៀន ពីវប្បធម៌វិជ្ជាជីវៈនិងមនសិការវិជ្ជាជីវៈរបស់គេ ។

មានបន្ថែមនិងរៀបចំជាថ្មី ។

មួយក្បាល ២៤៛០០

–បណ្ណាគារ សារវិត្តី, ៩២ជ្រុងវិថីព្រះច័ន្ទភានិងឧកញ៉ាផ្លុង,
–បណ្ណាការប៊ុតនាង, ១៧៦វិថីខេមរភូមិន្ទ, ភ្នំពេញ

★

## យើងត្រូវអប់រំកូនយើងរបៀបណា?

ដូចឈ្មោះវាបានបង្ហាញស្រាប់ នេះជាសៀវភៅប្រតិបត្តិមួយខាងចិត្តសាស្ត្រ និងគរុកោសល្យ ដែលបានយកកូនខ្មែរយើង មកធ្វើជាកម្មវត្ថុ ហើយដោះស្រាយដោយសមរម្យ ទៅតាមលក្ខណសម្បត្តិនៃប្រទេសយើង សន្តិភាព នឹងឯករាជ ។

មួយក្បាល ១០៛០០

មានលក់គ្រប់បណ្ណាគារ, ភ្នំពេញ

★

## ទិព្វសង្វារ

(សិក្សា-អត្ថាធិប្បាយ-ពន្យល់)

ដោយនិស្សិត.សាស្ត្រាចារ្យផ្នែកភាសាខ្មែរ នៃ វិទ្យាស្ថានជាតិគរុកោសល្យ នឹងមានចេញផ្សាយក្នុងអនាគតឆាប់ៗនេះ ។

# ក្នុងឱកាសឆ្នាំថ្មីនេះ

## សព្ទសាធុការ

នៅក្នុងឱកាសបុណ្យចូលឆ្នាំ ដែលនឹងមកដល់ ក្នុងប្រមាណមួយខែទៀតនេះ គណកម្មាធិការនាយក **នៃសមាគមសាស្ត្រាចារ្យខ្មែរ** នឹងគណៈកម្មាធិការនិពន្ធ **នៃទស្សនាវដ្ដីសាស្ត្រាចារ្យ**សូមប្រសិទ្ធិពរដ៏វិសេសវិសាលបំផុត ជូនដល់អស់មិត្តជិតឆ្ងាយ ព្រមទាំងគ្រួសារ សូមប្រកបទៅដោយសុខភាព ដ៏បរិបូរណ៍ សេចក្ដីចំរុងចំរើន ជាអនេកប្បការ ហើយនឹងមហាជោគជ័យគ្រប់បញ្ហា ។

★★


ទស្សនាវដ្ដីសាស្ត្រាចារ្យ

*មានផ្ញើលក់នៅ :*

–បណ្ណាគារ ប៊ុតឆាន់

176 រុក្ខវិថីខេមរភូមិន្ទ, ភ្នំពេញ

–បណ្ណាគារ សារវត្ដី

92 ជ្រុងវិថីព្រះច័ន្ទរាជា នឹងឧកញ៉ាផ្លុង, ភ្នំពេញ

តម្លៃ 12,00